ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Mar-2017, 13:38
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៣៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វត៍ *(Ms. Robynne CROFT)*

កញ្ញា ម៉ាដាលេណា ចេស៊ី *(Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ស្រ៊ា រតនះ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក សួន វិសាល | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី ជាំង ស្រីមុំ (2-TCW-834) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ជាំង ស្រីមុំ** (2-TCW-834)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៥

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ........ ទំព័រ ៨

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........ ទំព័រ ២៨

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី ........ ទំព័រ ៤១

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៤៧

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី ........ ទំព័រ ៥២

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៥៦

សួរដោយលោក សួន វិសាល ផ្តើមពី ........ ទំព័រ ៥៨

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........ ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-834។ ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការក្នុងថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះគឺសាក្សីដែលមានរហស្សនាម 2-TCW-834។ សាក្សីបានបញ្ជាក់ថាតាមសមត្ថ-ភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមាននៅបន្ទប់រង់ចាំ ១ការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះដែរយើងមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:០៤:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ឥឡូវនេះមុននឹងកោះអញ្ជើញសាក្សីចូលមកកាន់បន្ទប់សវនាការ អង្គជំនុំជម្រះសម្រេចលើសំណើ សុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានឃើញ -- ទទួលលិខិតសុំលះបង់សិទ្ធិចូលរួម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សវនាការដោយផ្ទាល់របស់ជនជាប់ នួន ជា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាពេលខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយៗយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៦:០០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យថែទាំព្យាបាលសុខភាពរបស់ជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ បានកត់សម្គាល់ថាស្ថានភាពសុខភាពរបស់ នួន ជា មានអាការៈឈឺចង្កេះ វិលមុខពេលអង្គុយយូរ ជាហេតុធ្វើឲ្យគាត់មិនអាច -- ពិបាកអង្គុយតាមដានសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ហើយបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ និងបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោត-ទស្សន៍សម្រាប់ជនជាប់ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលសវនាការពេញមួយថ្ងៃនេះ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:០៧:៣២]

**លោក នីកូឡាស គូមជែន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ យើងមានបញ្ហាមួយដែលយើងចង់

លើកឡើងមុនពេលសាក្សីចូលមកដល់។ នេះជាបញ្ហានៃនីតិវិធីសវនាការដែលអាចប៉ះពាល់ទៅនឹងសាក្សីនេះ និងអ្នកផ្សេងទៀត។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបនៅក្នុងសេចក្តីសង្ខេបនៃខ្លឹមសារសង្ខេបនៃសក្ខីកម្មសាក្សី។ បញ្ហាទាំងអស់អាចនឹងទាក់ទងទៅនឹង<ការព្រួយបារម្ភ>ផ្ទាល់ខ្លួន<>របស់សាក្សីរូបនេះ ដែលសាក្សីអាចនឹងជម្រាបជូនទៅតុលាការនៅក្នុងសក្ខីកម្មរបស់គាត់។

នៅក្នុងតុលាការផ្សេងទៀតដែលខ្ញុំបានធ្វើ <>ភាគីដែលអញ្ជើញសាក្សីអាចនឹងបានពិភាក្សាជាមួយនឹងសាក្សីរួចហើយ ដើម្បីកំណត់ថាតើសាក្សីមានការព្រួយបារម្ភអំពី<ការ>ផ្តល់សក្ខីកម្មជាសាធារណៈដែរ ឬអត់អំពីបញ្ហានេះ? ថាតើជាបញ្ហានឹងត្រូវតែលើកឡើងជម្រាបតុលាការអំពី<លទ្ធភាពធ្វើ> សវនាការជាអសាធារណៈ។ <ជាការពិត នៅក្នុងប្រព័ន្ធនេះយើងមិនមានឱកាស>ពិភាក្សាជាមួយសាក្សីជាមុនទេ ហើយបើក្នុងលក្ខណៈជាដើមបណ្តឹងរដ្ឋប្បវេណីវិញ គឺថាគាត់មិនមានមេធាវីតំណាងផលប្រយោជន៍គាត់ទេ អ៊ីចឹងសាក្សីរូបនេះ គឺស្ថិតក្នុងស្ថានភាពនេះ។ នៅពេលដែលសាក្សីត្រូវបានអញ្ជើញមកទីនេះ <អាចថា>ចៅក្រម <ឬក៏ភាគីដែលកោះហៅសាក្សីមក> ជូនដំណឹងទៅសាក្សីថាតើសាក្សីមានការព្រួយបារម្ភអំពីការសម្ងាត់ផ្ទាល់ខ្លួននៅក្នុងការជជែកពីបញ្ហា<ខ្លះ>នៅក្នុង<សវនាការ> សាធារណៈដែរឬទេ? <បន្ទាប់មក គេជូនដំណឹងនោះទៅអង្គជំនុំជម្រះ> ហើយបើតុលាការយល់ស្របទៅតាមហ្នឹង គឺថាយើងនឹងអាច<ដោះស្រាយបញ្ហានោះ ជាមួយភាគីផ្សេងៗទៀត និង>អង្គជំនុំជម្រះ<>។ ហើយដូច្នេះខ្ញុំសូមជម្រាបជូនតុលាការ<ថា ដោយសារ> ខ្ញុំមាន<ការណាត់ជួបមួយនៅម៉ោង ១០ ខ្ញុំសូមអភ័យទោស> ហើយខ្ញុំអាចនឹងសម្រាក ឬក៏សុំការអនុញ្ញាតសម្រាកមុនពេលកំណត់នៅថ្ងៃនេះ។ សូមជម្រាបជាមុនផងដែរ។

[០៩:០៩:៤៩]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីឆ្លើយបញ្ជាក់ទៅនឹងការលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិអំម្បាញ់មិញនេះ អំពីការស្នើសុំឲ្យពិចារណាលើលទ្ធភាពនៃការធ្វើសវនាការជាសម្ងាត់ចំពោះសាក្សី។ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**អ្នកបកប្រែ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកប្រធានមីក្រូហ្វូនមិនទាន់បើក ពីអ្នកបកប្រែបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តាមអ្វីដែលយើងដឹង គឺថាយើងមាននីតិវិធីដែល<មាន>ជាធរមាន<។ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ*(WESU)* ដែលមានទំនាក់ទំនងជាមួយសាក្សីទាំងអស់ ធ្វើការ>ជូនដំណឹងទៅសាក្សី <ហើយអង្គភាពនេះបានជួយ>យើង<ជាយូរមកហើយ ឲ្យ>យើងអាច<ប្រតិបត្តិការតាមមាត្រាត្រឹមត្រូវ សូម>ពិនិត្យមើលនៅក្នុងវិធានផ្ទៃក្នុង២៩ <ដែល>មានរយៈពេលកំណត់អំពី<>វិធានការការពារ ប៉ុន្តែប្រសិនបើសាក្សីលើកឡើងពីបញ្ហានៅក្នុងសវនាការ យើងនឹងសម្រេចទៅតាមករណីនោះ។

**លោក នីកូឡាស គូមជែន៖**

ហើយយើងមិនបានទទួលការចង្អុលបង្ហាញអ្វីពីផ្នែកសាក្សីនិងអ្នកជំនាញទេ។ <ប្រហែលជាលោកប្រធានបានទទួលមើលទៅ ប៉ុន្តែ>ថាតើ<យើងដឹងថា>ពួកគេបានពិភាក្សាជាមួយសាក្សី ហើយសាក្សីប្រកាន់គោលជំហរយ៉ាងដូចម៉េច? យើងមិនបានទទួលព័ត៌មានអ្វីទេ ហើយ<តើ>យើង<គួរតែសន្មត>ថា<សាក្សី>បានទទួល<ការបញ្ជាក់អំពី>សិទ្ធិដើម្បីសុំឲ្យមានសវនាការជាអសាធារណៈ ហើយត្រូវបានបដិសេធ ឬដូចម្តេច។

[០៩:១៣:៣៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយដូចដែលខ្ញុំជម្រាប គឺយើងមានទម្លាប់អនុវត្តនីតិវិធី ហើយយើងយល់ថាអង្គភាពគាំពារសាក្សីនិងអ្នកជំនាញបានជូនដំណឹងទៅសាក្សីរួចហើយ។ ហើយនិយាយអំពីខ្លឹមសារលម្អិត យើងនឹងពិនិត្យមើល។ <ប៉ុន្តែដូចដែលខ្ញុំបាននិយាយអ៊ីចឹង> <>ប្រសិនបើសាក្សីមានសំណើជាក់លាក់នៅក្នុងវគ្គសវនាការ ហើយវាហាក់ដូចជាយឺតបន្តិចក្នុងការអនុវត្តវិធានការការពារនៅពេលនេះ <ប៉ុន្តែយើងត្រូវតែដោះស្រាយទៅលើបញ្ហាបច្ចេកទេស ហើយនេះជាមូលហេតុ ដែលជាទូទៅយើងតែងតែព្យាយាម> ទទួលព័ត៌មានឆាប់ជាងនេះ<។ នៅពេលនេះគ្មានអ្វីត្រូវបន្ថែមទៀតទេ>។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ <ខ្ញុំគ្រាន់តែសុំលើកឡើងថា> ភាគី<>កោះអញ្ជើញសាក្សី <ឬស្នើសុំសាក្សីក្នុងករណីនេះ><>សហព្រះរាជអាជ្ញាមិនមានឱកាសនឹងដាក់សំណើទាក់ទងទៅនឹងចេតនារបស់សាក្សីទេ ពីព្រោះយើងមិនបានដឹងជាមុន យើងមិនអាចគោរពទៅតាមពេលកំណត់នៅក្នុងវិធានផ្ទៃក្នុងទាក់ទង

ទៅវិធានការការពារ។ ប៉ុន្តែនេះវាទាក់ទងទៅនឹងការសម្ងាត់របស់សាក្សី ប៉ុន្តែសូមអរគុណដែលលោកស្រីចៅក្រមបានបញ្ជាក់ជូននេះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៦:៣១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួ<>ស្តីលោកស្រី! តើលោកស្រីឈ្មោះ ជាំង ស្រីមុំ អ៊ីចឹងពិតមែនដែរទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ ជាំង ស្រីមុំ។

**ស៖** លោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ១៩៥៥។

**ស៖** អរគុណ។ តើលោកស្រីមានទីលំនៅបច្ចុប្បន្ននេះនៅទីកន្លែងណា?

**ឆ៖** ចាស បច្ចុប្បន្ននៅឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** អរគុណ ហើយលោកស្រីប្រកបមុខរបរអ្វី ហើយអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ចាស ជាកសិករ។

**ស៖** បាទ អរគុណ។ តើឪពុករបស់លោកស្រីឈ្មោះអ្វី?

**ឆ៖** ចាស ឪពុកនាងខ្ញុំឈ្មោះ ជាំង យ័ន្ត។

[០៩:១៧:៥៣]

**ស៖** អរគុណ ចុះម្តាយរបស់លោកស្រី គាត់ឈ្មោះអ្វី?

**ឆ៖** ម្តាយនាងខ្ញុំ សៅ នន។

**ស៖** ចុះប្តីរបស់លោកស្រី គាត់ឈ្មោះអ្វី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្តីរបស់នាងខ្ញុំឈ្មោះ ទ្រី ទូច មានកូនបីនាក់។

**ស៖** អរគុណ ហើយលោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថា ចាប់ពីខែមេសា ឆ្នាំ

១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តើលោកស្រីធ្វើអ្វី ហើយនៅទីកន្លែងណា?

**ឆ៖** ចាស នាងខ្ញុំ កាលពីឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅឃុំញ៉ែងញ៉ង ភូមិឫស្សីស្រុក។ ចាស លោកប្រធានអំមិញ ស្ដាប់សំណួរមិនសូវទាន់។

**ស៖** បាទ អរគុណ ហើយលោកស្រីធ្វើអ្វីដែរជំនាន់នុ៎ង?

**ឆ៖** នៅក្នុងជំនាន់នោះ នាងខ្ញុំជាប្រជាជនរស់នៅក្នុងកងសហគមន៍ ក្នុងកង៧ប៉ុល ពត ចាស។

**ស៖** អរគុណលោកស្រី ជាំង ស្រីមុំ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹង គឺថាលោកស្រីមិនមានឪពុកម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្ដីត្រូវបានទទួលស្គាល់យកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ចាស ពិតមែនហើយលោកប្រធាន អត់មានទេ ចាស ពាក់ព័ន្ធសាច់ញាតិ។

**ស៖** អរគុណ។ ហើយក្រឡាបញ្ជីបានរាយការណ៍ផងដែរ ថាលោកស្រីបានស្បថរួចហើយ មុននឹងចូលមកកាន់បន្ទប់សវនាការ ដើម្បីផ្ដល់សក្ខីកម្មនាពេលនេះ។ តើពិតមែនដែរទេ?

**ឆ៖** ចាស ពិតមែនហើយលោកប្រធាន អម្បាញ់មិញនេះ នាងខ្ញុំបានស្បថនៅមុខលោកតារួចហើយ ចាស។

[០៩:២០:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយលោកស្រី ឥឡូវនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកស្រីក្នុងនាមលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះអំពីសិទ្ធិ លោកស្រី ជាំង ស្រីមុំ ក្នុងនាមលោកស្រីជាសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សុំឲ្យលោកស្រីធ្វើអំណះអំណាងណាមួយ ឬក៏ច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ចក្នុងនាមលោក -- លោកស្រីជាសាក្សីត្រូវផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។ លើកលែងតែសំណួរដែលនាំឲ្យឆ្លើយតបរបស់លោកស្រី ឬការធ្វើអត្ថាធិប្បាយណាមួយ ឬក៏ច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់សិទ្ធិអំពី -- រួចហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមលោកស្រីជា

សាក្សីត្រូវតែឲ្យការណ៍ណាដែលពិតដែលលោកស្រីបានដឹង បានឮ បានឃើញ បានចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬក៏ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោកស្រី។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី ជាំង ស្រីមុំ តើលោកស្រីដែលបានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនមាន តើធ្វើប៉ុន្មានដង? ហើយធ្វើនោះនៅកន្លែងណា? ពីពេលណាដែរ?

[០៩:២២:៣៧]

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស លោកប្រធាន នាងខ្ញុំបានចូលរួមនឹងការស៊ើបអង្កេតអស់លោកបានម្តង ហើយមិនបានចូលរួម ទើបតែលើកទី១ហ្នឹងទេ។ សូមទោសលោកប្រធាន ខ្ញុំស្តាប់មិនសូវទាន់ ចាស។

**ស៖** លោកស្រីចាំទេថា តើកាលដែលស្តាប់សក្ខីកម្មរបស់លោកស្រីពេលនោះ តើគេធ្វើនៅកន្លែងណា?

**ឆ៖** ចាស ធ្វើនៅឃុំញ៉ែងញ៉ង ភូមិឫស្សីស្រុក។

**ស៖** អរគុណ ហើយពីពេលណាដែរ លោកស្រីចាំទេ?

**ឆ៖** ពេលវេលាកំណត់ហេតុវាភ្លេចទៅហើយលោកប្រធាន អត់សូវមានការចងចាំឥឡូវចាស។

**ស៖** លោកស្រី ជាំង ស្រីមុំ នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យ ឬក៏បានអាននូវកំណត់ហេតុដែលលោកស្រីបានផ្តល់សក្ខីកម្មកាលពីលើកមុននោះដែរឬទេ ដើម្បីរំឭកការចងចាំនោះ?

**ឆ៖** ចាស បានអាន បានអានគ្រួសៗ ចាស។

**ស៖** អរគុណ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងអាចចងចាំ ថាតើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវ ឬស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកស្រីបានធ្វើសម្ភាសជាមួយអ្នកស៊ើបអង្កេត កាលពីពេលមុននោះដែរឬទេ?

[០៩:២៤:៤៨]

**ឆ៖** ចាស ពិតមែន នេះជាការត្រឹមត្រូវហើយលោកប្រធាន ចាស វាសមស្របនឹងកំណត់ហេតុ និងការដឹងត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ជាំង ស្រីមុំ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ គឺមួយព្រឹកនេះក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[០៩:២៥:៣៦]

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រី សូមគោរពភាគីនៅក្នុងរឿងក្ដី និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកស្រី ជាំង ស្រីមុំ ចាសជម្រាបសួរ។ ថ្ងៃនេះខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរទៅលោកស្រី ហើយសូមឲ្យលោកស្រីជួយសហការក្នុងការឆ្លើយសំណួរ។ ប្រសិនបើមានសំណួរណាដែលខ្ញុំសួរទៅលោកស្រី លោកស្រីមិនយល់ ឬក៏មិនអាចចាំបាន លោកស្រីអាចឲ្យខ្ញុំសួរលោកស្រីឡើងវិញម្ដងទៀត។ ហើយបើប្រសិនបើមានសំណួរណាដែលខ្ញុំសួរទៅ លោកស្រីគិតថាលោកស្រីពិបាកក្នុងការឆ្លើយ ប៉ះពាល់នឹងអារម្មណ៍របស់លោកស្រី លោកស្រីមានសិទ្ធិស្នើសុំទៅតុលាការ ដើម្បីឲ្យធ្វើសវនាការជាអសាធារណៈ។ មានន័យថា មានតែមនុស្សនៅក្នុងសវនាការនេះទេដែលដឹងអំពីចម្លើយដែលលោកស្រីឆ្លើយ គ្មានសាធារណជនណាអាចដឹងអំពីចម្លើយដែលលោកស្រីឆ្លើយនោះឡើយ។ តើលោកស្រីយល់អ្វីដែលខ្ញុំនិយាយដែរឬទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ស្ដាប់បានយល់។

**ស៖** ចាស អរគុណ។ អ៊ីចឹងសំណួរទី១ ដែលខ្ញុំចង់សួរលោកស្រី ចង់សួរថា តើនៅពេលណាដែលខ្មែរក្រហមចូលមកកាន់កាប់ ឬក៏ចូលមកគ្រប់គ្រងនៅក្នុងឃុំញ៉ែងញ៉ងរបស់លោកស្រី?

**ផ៖** ចាស នៅឆ្នាំ១៩៧០ចាស។

[០៩:២៧:០៩]

**ស៖** ចាសអរគុណ។ ហើយនៅក្នុងចម្លើយដែលលោកស្រីធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតគឺនៅត្រង់ឯកសារ D232/58 នៅត្រង់ចម្លើយលេខ១ លោកស្រីបានប្រាប់អ្នកស៊ើបអង្កេតថា៖ "ដំបូងយើងរស់ផ្ទះរបស់យើង ប៉ុន្តែខ្មែរក្រហមបានលុបបំបាត់កម្មសិទ្ធិទាំងអស់"។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើនៅឆ្នាំណាដែលខ្មែរក្រហមលុបបំបាត់កម្មសិទ្ធិ?

**ផ៖** ចាស ចាប់តាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥រហូតចាស។

**ស៖** សូមឱ្យលោកស្រីជួយបញ្ជាក់ថា ពេលដែលចាប់ផ្តើមលុបបំបាត់កម្មសិទ្ធិ តើលុបបំបាត់ពីឆ្នាំណា? ហើយបញ្ចប់នៅឆ្នាំណា ប្រសិនបើលោកស្រីអាចចាំបាននោះ?

**ផ៖** ចាស ចាប់តាំងពីឆ្នាំ១៩៧០ ការបញ្ចប់នៅឆ្នាំ១៩៧៩។

**ស៖** ចាស សូមអរគុណ។ ចុះនៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងកាន់កាប់អំណាចនៅក្នុងរបបខ្មែរក្រហមហ្នឹង តើប្រជាពលរដ្ឋនៅក្នុងភូមិឃុំលោកស្រីហ្នឹងត្រូវបានគេបែងចែកវណ្ណៈ ឬក៏ចាត់ប្រភេទដែរឬទេ?

**ផ៖** ចាស ចាប់តាំងពីរបបខ្មែរក្រហមគ្រប់គ្រង គេបែងចែកវណ្ណៈនិងប្រភេទជាពីរប្រភេទ ប្រភេទទី១, ទី២, ទី៣ ចាស និងហៅថា ពេញសិទ្ធិ និងត្រៀម ចាស។

[០៩:២៩:៣៧]

**ស៖** ចាស អរគុណ។ តើខ្ញុំយល់ជាការត្រឹមត្រូវទេ មានន័យថាគេបែងចែកប្រភេទមនុស្សជាពីរប្រភេទ ប្រជាជនពេញសិទ្ធិ និងប្រជាជនត្រៀម។ តើអ៊ីចឹងមែនទេ?

**ផ៖** ចាស ត្រឹមត្រូវហើយ គេបែងចែកជាពេញសិទ្ធិ និងត្រៀម។

**ស៖** ចុះលោកស្រីស្ថិតនៅក្នុងប្រភេទប្រជាជនណាដែរ?

**ផ៖** នាងខ្ញុំស្ថិតនៅក្នុងប្រជាជនត្រៀម។

**ស៖** លោកស្រីដឹងទេថា ហេតុអ្វីបានជាគេចាត់លោកស្រីឱ្យក្លាយ ឬក៏ចូលទៅក្នុងប្រភេទជាប្រជាជនត្រៀមនៅពេលនោះ?

**ឆ៖** ចាស បានជាគេចាត់ជាប្រជាជនត្រៀម គេពិនិត្យទៅលើប្រវត្តិរូប គេដាក់ជាប្រវត្តិរូបចាស។ ប្រវត្តិរូបនាងខ្ញុំវា -- គេចាត់ទុកជាគ្រួសារពាក់ព័ន្ធ ៗដូចថា គ្រួសារពាក់ព័ន្ធអ៊ីចឹង ពីសង្គមឡើយ ពីគ្រួសារនាងខ្ញុំអ៊ីចឹងដូចជាមានខ្សែហោរអី ជីដូនជីតាអីអ៊ីចឹងជាអាណិកជនចិនអី ក្រោយមកដូចថាកូនចៅអីអ៊ីចឹងគេដាក់ថាជាអាណិកជនចិន ពាក់ព័ន្ធជាជនជាតិភាគតិចអ៊ីចឹងទៅ។ អ៊ីចឹងគេជ្រើសរើសគេដាក់បែងចែកជាៗត្រៀមចាស ដាក់ជាត្រៀមអ៊ីចឹង ព្រោះអីវាមានការថាពាក់ព័ន្ធជាអាណិកជនចិនអ៊ីចឹង។ ប៉ុន្តែវា ជីដូនជីតាជាប់ ដូចថាយើងធ្លាប់សែនកុងម៉ាអ៊ីចឹង។ ហើយម្យ៉ាងឪពុកម្ដាយខ្ញុំរកស៊ីតិចតួចអី គាត់ដឹកអំបិល ដឹកស្រូវអង្ករអ៊ីចឹងទៅ គេថាអាណិកជនអ៊ីចឹងទៅ។ អ៊ីចឹងគេដាក់ជាត្រៀមអ៊ីចឹង។

[០៩:៣២:២៦]

**ស៖** ចាសសូមអរគុណ។ នៅត្រង់ចម្លើយ -- ត្រង់សំណួរ-ចម្លើយលេខ២ ដែលលោកស្រីបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកស្រីបានរំឭកដល់ពាក្យ “ការហូបចុកជាសមូហភាព”។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថាតើពេលណាដែលគេចាប់ផ្ដើមឲ្យមានការហូបចុកជាសមូហភាព?

**ឆ៖** ចាស ចាប់តាំងពីឆ្នាំ១៩៧០ រហូតមកគេរៀបចំជាសហករណ៍ដើម្បីប្រមូលផ្ដុំប្រជាពល--ប្រជាជនហ្នឹង ហូបបាយជាសមូហភាព។ ចាស នៅចាប់តាំងពីឆ្នាំហ្នឹងរហូតមក។

**ស៖** ហើយបញ្ចប់ការហូបចុកជាសមូហភាពហ្នឹងនៅពេលណាដែរ? ក្នុងឆ្នាំណា?

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតប! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។ ចាំៗឃើញភ្លើងក្រហមសឹមឆ្លើយបាទ លោកស្រី ជាំង ស្រីមុំ។

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស បញ្ចប់នៅឆ្នាំ១៩៧៩ ចាស ដែលរំដោះរួចនោះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស អរគុណ។ នៅត្រង់ចម្លើយដែលលោកស្រីបានឆ្លើយនៅត្រង់ឯកសារដដែល គឺនៅត្រង់ចម្លើយលេខ១១ លោកស្រីបាននិយាយថា ខ្ញុំដកស្រង់៖ “មានអ្នកខ្លះស្លាប់ដោយសារការហូបច្រើនពេក អ្នកខ្លះឈឺដោយសារការខ្វះជីវជាតិ”។ តើលោកស្រីចង់បានន័យយ៉ាងដូចម្ដេចដែរ នៅពេលដែលលោកស្រីនិយាយដូច្នេះ?

[០៩:៣៤:២២]

**ឆ៖** ចាស បានន័យថា អ្នកខ្លះស្លាប់ច្រើន -- ស្លាប់ដោយសារការហូបចុកច្រើនពេក អ្នកខ្លះ -- ដូចថាការហូបចុកច្រើនពេក បានន័យថាស្លាប់ហ្នឹង ពេលនោះអាហារប្រចាំថ្ងៃហ្នឹងវាមិនដែលគ្រប់គ្រាន់ ចាស អត់ដែលបានគ្រប់គ្រាន់ទេ។ ដល់តែពេលកម្ម -- មានកម្មវិធីថ្ងៃសាម -- ថ្ងៃ២០ ថ្ងៃ១០ ថ្ងៃ៣០ ហ្នឹង គេធ្វើកម្មវិធីម្តងៗហ្នឹង ឲ្យហូបសេរី។ ដល់ពេលនោះវាអាហារប្រចាំថ្ងៃហ្នឹងវាមិនដែលបានហូបគ្រប់គ្រាន់ ដល់ទៅពេលហ្នឹងបានថ្ងៃ១០ហ្នឹងបានហូបគ្រប់គ្រាន់មួយពេលហ្នឹងទៅ ដូចថាវាការអត់ខ្លាំងពេកអ៊ីចឹងទៅ ដល់ពេលជួបប្រទះអាហារហ្នឹងចេះតែហូប។ ដល់តែហូបទៅវាដូចថាឆ្អាញ់ហួសហេតុ ពេកអ្នកខ្លះទៅស្ទះជាខ្យល់ ឬមួយបែកក្រពះស្លាប់នៅពេលហ្នឹងចាស នេះជាការពិតចាស។

**ស៖** ចាស អរគុណលោកស្រី។ ចុះមានប្រជាជនឧស្សាហ៍ឈឺ ឬក៏មានប្រជាជនច្រើនឈឺទេ នៅក្នុងភូមិឃុំលោកស្រីនោះ? មានឈឺញឹកញាប់ទេ?

**ឆ៖** ចាស ធម្មតាឈឺគឺជាអចិន្ត្រៃយ៍ គឺរាល់ថ្ងៃ ប៉ុន្តែដូចថាឈឺល្មមៗអាចទៅធ្វើការកើតចេះតែជម្នះទៅ។ អ្នកខ្លះឈឺខ្លាំងពេកទៅរហូតដល់ទៅអត់ធ្វើការកើតទៅ ហ្នឹងវាប៉ះពាល់ដល់អ្នកដឹកនាំគេថាយើងសតិអារម្មណ៍ ម៉្លោះហើយអ្នកឈឺល្មមៗហ្នឹងចេះតែទៅធ្វើការដោយមានះអ៊ីចឹងណាអ្នកគ្រូ ចាស។

**ស៖** ចុះប្រសិនបើមានប្រជាជនឈឺ តើមានថ្នាំសង្កូវ ឬមានការព្យាបាលអ្នកជំងឺដែលឈឺទេ?

[០៩:៣៦:៤៤]

**ឆ៖** ចាស មានពេទ្យព្យាបាល។ ប៉ុន្តែវាដូចថាគ្រាន់--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវីការពារក្តី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយសារជាប្រភេទសំណួរសន្និដ្ឋានដែលតំណាងសហព្រះរាជអាជ្ញាតាំងសំណួរឲ្យសាក្សីស្មាន បញ្ជាក់ថា "ប្រសិនបើ"។ ដូច្នេះអ្វីដែលជាចម្លើយវាមិនមែនជាការពិតទេបាទ។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមឆ្លើយតបដោយសង្ខេបលោកប្រធាន។ លោកស្រីបានឆ្លើយបញ្ជាក់ថាពិតជាមានអ្នកជំងឺឈឺ

អ៊ីចឹងខ្ញុំសួរថាប្រសិនបើឈឺហ្នឹងមានថ្នាំព្យាបាលឬអត់? ថាតើមានសំណួរនាំមុខ ឬក៏ជាការសន្និដ្ឋានអី ខ្ញុំគិតថាមិនមែនទេ ប៉ុន្តែខ្ញុំអាចរៀបចំសំណួរដើម្បីឲ្យសួរច្បាស់ជាងនេះ។

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**សៈ** លោកស្រីបាននិយាយថា "មានអ្នកជំងឺឈឺ" តើអ្នកជំងឺទាំងនោះបានទទួលថ្នាំព្យាបាល ឬក៏មានពេទ្យព្យាបាលពួកគាត់ទេ នៅពេលដែលគាត់ឈឺ?

[០៩:៣៨:០៤]

**លោកស្រី ជាំង ស្រីមុំៈ**

**ឆៈ** ចាស ការឈឺនោះគឺអចិន្ត្រៃយ៍ គឺរាល់ថ្ងៃអ៊ីចឹង ប៉ុន្តែពេទ្យព្យាបាលក៏ព្យាបាលប៉ុន្តែមិនមានការដិតដល់។

**សៈ** សូមលោកស្រីបញ្ជាក់ថាតើ មិនដិតដល់ហ្នឹងយ៉ាងម៉េចដែរ ហើយស្ថានភាពពេលនោះយ៉ាងម៉េច?

**ឆៈ** ចាស ពេទ្យមានការរើសអើង។ ដូចថាបក្សពួកនិយម ពេលខ្លះគេមិនសូវពេញចិត្តយើង គេព្យាបាលទាំងកំហឹងកំហល់។

**សៈ** មានការរើសអើងក្នុងការព្យាបាល សូមលោកស្រីជួយបញ្ជាក់ឲ្យច្បាស់ ថាតើរើសអើងយ៉ាងម៉េច? ហើយគាត់ព្យាបាលហ្នឹង ព្យាបាលដោយកំហឹងដោយរបៀបណាដែរ?

**ឆៈ** ចាស មានការរើសអើង ដូចជាយើងជាសមាជិកធម្មតា ឬមួយការព្យាបាលដោយដិតដល់នោះដូចថាគេសាច់ញាតិអី បក្សពួក ប្រធានកង ប្រធានក្រុមអីអ៊ីចឹងមាន -- ខាងសាច់ញាតិគេរបស់គេទៅ ហ្នឹងគេយកចិត្តទុកដាក់។ ដូចថាចំពោះប្រជាពលរដ្ឋអ៊ីចឹងវាមិនសូវមាន ធម្មតាអ៊ីចឹង គេមិនសូវយកចិត្តទុកដាក់ទេ។ បើកាលណាគេចាក់ថ្នាំ ខ្ញុំនិយាយជាការពិតណាស់ ប្អូនស្រីខ្ញុំមួយវាធ្វើពេទ្យ តែដូចដល់ៗពេលសមាជិកក្នុងក្រុមវាឈឺអ៊ីចឹង វាចុកពោះ ដល់ចុកពោះ វាស្រែកខ្លាំង។ ដល់ពេលស្រែកខ្លាំងអ៊ីចឹង វាថាមីហ្នឹងបែបសតិអារម្មណ៍ៗហ្នង មើលអញយកវីតាមីនសេយកមកចាក់តែម្តង។ ហ្នឹងជាការពិតណាស់ ហ្នឹងប្អូនស្រីជីដូនមួយខ្ញុំហ្នឹងវាធ្វើពេទ្យ ដល់វាមិនពេញចិត្តបុគ្គលហ្នឹងទៅ វាឈឺ វាៗចុកពោះផ្សេង វាថាអញយកថ្នាំវីតាមីនសេចាក់ឲ្យចុក។ វាឆ្លើយថាអ៊ីចឹង។ អ៊ីចឹងបានថាពេទ្យនៅក្នុងនោះក៏អត់សីលធម៌ដែរ។

[០៩:៤០:៣៣]

**ស៖** ចាស សូមអរគុណ។ ខ្ញុំចូលមកដល់ប្រធានបទមួយផ្សេងទៀត ទាក់ទងទៅនឹងការបាត់ខ្លួនឪពុករបស់លោកស្រី។ លោកស្រីអាចប្រាប់អង្គសវនាការបានទេ ថាតើមានសមាជិកនៅក្នុងគ្រួសាររបស់លោកស្រីត្រូវបានចាប់ខ្លួន ឬក៏បាត់ខ្លួននៅក្នុងរបបខ្មែរក្រហមដែរឬទេ?

**ឆ៖** ចាស សាច់ញាតិខ្ញុំច្រើនណាស់ដែលបាត់ខ្លួន ដែលពេលខ្មែរក្រហមយកទៅសម្លាប់ហ្នឹង ជាពិសេសឪពុករបស់ខ្ញុំ ចាស។ ខ្ញុំសូមបញ្ជាក់ថានៅម៉ោងប្រាំពីរយប់ គឺម្ដាយខ្ញុំ គឺចំពោះខ្ញុំ បងប្អូនខ្ញុំគឺនៅកងទាំងអស់គ្នា។ តែឪពុកខ្ញុំនិងម្ដាយខ្ញុំនៅផ្ទះតែពីរនាក់ទេ ប៉ុន្តែម៉ោងប្រាំពីរយប់មានប្រធានភូមិប្រធានកង ទៅហៅឪពុកខ្ញុំចេញពីក្រោមផ្ទះ តែពេលនោះបាត់ឪពុកខ្ញុំទៅ ម្ដាយខ្ញុំខំស្រែកហៅក៏គាត់អត់ដឹងថាឪពុកទៅណាមកណាដែរ។ ហើយក៏ម្ដាយខ្ញុំក៏គាត់នឹងឃើញថា អំមិញឮមាត់ខ្សឹបខ្សៀវនៅក្រោមផ្ទះ មានអ្នកមកហៅ អ៊ីចឹងមានគេហៅទៅណា គាត់ -- អ៊ីចឹងបាត់មួយយប់ទៅ បានចាប់អារម្មណ៍ថាប្រហែលជាគេចាប់ខ្លួនបាត់ហើយចាស។ អ៊ីចឹង ឪពុកខ្ញុំត្រូវគេយកសម្លាប់នៅឆ្នាំ១៩៧៧ចាស។ គឺខ្ញុំនិយាយមានភស្តុតាងចាស មានភស្តុតាង ពេលនោះខ្ញុំមានឃើញកំណត់ហេតុនៅសារមន្ទីរមួយនៅក្រាំងតាចាន់។ កន្លែងហ្នឹងកន្លែងគេវៃមនុស្សចោល ហើយគេធ្វើសារមន្ទីរមួយតម្កល់ឆ្អឹងនៅកន្លែងហ្នឹង។ ពេលនោះ ខ្ញុំចេះទៅធ្វើបុណ្យហ្នឹង ចេះតែធ្វើដោយព្រាវៗទេ ដូចថា នៅក្នុងស្រុកភូមិហ្នឹងដែលយកមនុស្សមកសម្លាប់ៗនៅកន្លែងហ្នឹងហើយ។ អ៊ីចឹង ខ្ញុំចេះតែធ្វើបុណ្យព្រាវៗ ពេលនោះខ្ញុំឃើញ កំណត់ហេតុឪពុកខ្ញុំជាច្បាស់ណាស់ ដាក់ថាឪពុកឈ្មោះ ជាំង យ័ន្ត ប្រពន្ធឈ្មោះ សៅ នន អ៊ីចឹង បានស្លាប់នៅឆ្នាំ១៩៧៧ទៅ ដោយមូលហេតុនិយាយពីការខុសនឹងសង្គមគេដឹកនាំអ៊ីចឹងចាស។ ខ្ញុំឃើញពិត។

[០៩:៤៣:១៧]

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់សួរលោកស្រីបញ្ជាក់ថា លោកស្រីដឹងថាគេយកឪពុកលោកស្រីទៅសម្លាប់ហ្នឹង នៅពេលណាដែរ ពេលវេលាពិតប្រាកដដែលលោកស្រីបានដឹងដោយខ្លួនឯង?

**ឆ៖** ចាស ពេលវេលានោះម៉ោងប្រាំពីរយប់ ដែលយកចេញពីផ្ទះ១ម៉ោងប្រាំពីរយប់។ ប៉ុន្តែសម្លាប់ម៉ោងប៉ុន្មាន ខ្ញុំអត់បានដឹងដែរ។

**ស៖** តើឪពុករបស់លោកស្រីរស់នៅក្នុងឃុំញ៉ៀងញ៉ង់មែនទេ នៅពេលដែលគេយកគាត់ទៅហ្នឹង?

**ឆ៖** ចាស ឪពុករបស់នាងខ្ញុំនៅឃុំញ៉ៀងញ៉ង់ នៅភូមិឫស្សីស្រុក ចាស។

**ស៖** មុននេះ លោកស្រីបានរំឭកដល់មន្ទីរក្រាំងតាចាន់ លោកស្រីដឹងទេថាមន្ទីរក្រាំងតាចាន់ហ្នឹងស្ថិតក្នុងឃុំណាដែរ? ហើយវានៅពីខាងណា ទិសខាងណានៃភូមិឃុំឫស្សីស្រុក ឃុំញ៉ៀងញ៉ង់របស់

លោកស្រី ខាងកើត ខាងជើង ខាងត្បូង ឬខាងលិចពីឃុំហ្នឹង?

**ឆ៖** ចាស ឪពុកខ្ញុំដែលគេយកសម្លាប់នៅភូមិក្រាំងតាចាន់ហ្នឹងស្ថិតនៅក្នុងឃុំគុស ភូមិក្រាំងតាចាន់ស្ថិតនៅក្នុងឃុំគុស ទិសខាងលិចឆៀងទៅខាងជើងពីផ្ទះនាងខ្ញុំ។

**ស៖** ចាស អរគុណ។ មុននេះលោកស្រីរំឭកដល់ម៉ោងប្រាំពីរ ដែលគេមកយកឪពុករបស់លោកចេញទៅ។ តើនៅពេលដែលគេចូលមកយកឪពុកលោកស្រីហ្នឹង លោកស្រីនៅកន្លែងណាដែរពេលហ្នឹង?

**ឆ៖** ចាស ខ្ញុំនៅក្នុងកងនារី នៅវត្តគុស។

[០៩:៤៥:៥០]

**ស៖** ប្រសិនបើលោកស្រីនៅក្នុងកង ហេតុអ្វីបានជាលោកស្រីដឹងថា គេយកឪពុកលោកស្រីចេញទៅនៅម៉ោងប្រាំពីរ?

**ឆ៖** ពេលនោះ ប្អូនស្រីរបស់ខ្ញុំ វាមកលេងផ្ទះ រួចវាទៅខ្សឹបប្រាប់ខ្ញុំនៅក្រៅកងហ្នឹង វាខ្សឹបហើយវាយំប្រាប់ថា ឪពុកយើងគេយកទៅសម្លាប់ចោលហើយ បាត់ពីល្ងាចម្សិល មកហៅ -- ប្រធានភូមិមកហៅចេញពីម៉ោងប្រាំពីរ។ អាហ្នឹងម្ដាយខ្ញុំប្រាប់ថា ប្រធានភូមិគេមកហៅចេញពីម៉ោងប្រាំពីរចេញពីក្រោមផ្ទះ អ៊ីចឹងកំណត់ថា ឪពុកខ្ញុំចេញពីម៉ោងប្រាំពីរហ្នឹង។

**ស៖** សូមលោកស្រីជួយប្រាប់ដល់អង្គជំនុំជម្រះថា តើប្អូនស្រីលោកស្រីមានឈ្មោះអ្វី?

**ឆ៖** ចាស ប្អូនស្រីនាងខ្ញុំឈ្មោះ ជាំង អេង នៅកងនារីដូចគ្នា។

**ស៖** ចាស អរគុណ។ ខ្ញុំនឹងចូលដល់ប្រធានបទថ្មីមួយទៀតទាក់ទងទៅនឹងការរៀបការ តើលោកស្រីបានរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបខ្មែរក្រហមមែនទេ?

**ឆ៖** ចាស ខ្ញុំរៀបការនៅជំនាន់ខ្មែរក្រហមហ្នឹង នៅឆ្នាំ១៩៧៧។

**ស៖** សូមឱ្យលោកស្រីប្រាប់ដល់សវនាការថា តើហេតុអ្វីបានជាលោកស្រីត្រូវរៀបការនៅក្នុងរបបខ្មែរក្រហម?

[០៩:៤៨:០២]

**ឆ៖** ចាស ពេលនោះដែលខ្ញុំរៀបការនៅជំនាន់ខ្មែរក្រហម ពេលនោះខ្ញុំនៅក្នុងកងនារីហ្នឹងគឺមានតួនាទីមើលកុមារ។ អ៊ីចឹងចំពោះខ្លួនខ្ញុំផ្ទាល់ហ្នឹង គេចាត់ទុកថា ខ្ញុំហ្នឹងមាននិន្នាការពាក់ព័ន្ធពីឪពុកខ្ញុំដែលគេយកទៅសម្លាប់។ អ៊ីចឹងគេត្រូវដកខ្ញុំចេញពីប្រធាន -- ពីកង ដើម្បីរៀបការជាមួយប្ដីរបស់ខ្ញុំហ្នឹង

ឈ្មោះ ទ្រី ទូច ដើម្បីគេដកយកពីកងឲ្យលែងមានសិទ្ធិ និងការដឹកនាំ។ អ៊ីចឹងគេធ្វើវិធីហ្នឹង រៀបចំនិងការប្ដេជ្ញា។

**ស៖** តើអ្នកណាជាអ្នកប្រាប់លោកស្រីថា លោកស្រីត្រូវរៀបការ ឬក៏លោកស្រីសម្រេចចិត្តដោយខ្លួនឯង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោក! សួរម្ដងទៀត!

[០៩:៤៩:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់ជំទាស់ទៅលើការសួរ ដែលបានសួរពីមុននេះ ប៉ុន្តែគាត់បានបន្ថែមនូវសំណួរទី២ គឺជាជម្រើសដ៏ល្អ។ ដូច្នេះហើយ គឺថាឥឡូវនេះ ខ្ញុំឃើញថា សាក្សីហាក់ដូចជាយឺតក្នុងការឆ្លើយតប ហើយក៏មិនទាន់បាននិយាយអ្វីទេ។ ដូច្នេះអ្វីដែលខ្ញុំចង់បញ្ជាក់គឺថា ព្រះរាជអាជ្ញាគួរសួរសំណួរដែលបើកចំហមិនមែនសួរសំណួរដែលនិយាយពីលក្ខខណ្ឌតម្រូវណាមួយ ឬមួយក៏អំពីការលក្ខខណ្ឌតម្រូវនៃការរៀប-ការ<។ នេះគឺជាការជំទាស់របស់ខ្ញុំ។> ប៉ុន្តែដោយសារតែ<>សំណួរទី២បន្ថែមទៀត <> ទើបខ្ញុំអង្គុយចុះ<>មកវិញ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស លោកស្រីនៅចាំសំណួរចុងក្រោយរបស់ខ្ញុំទេ ឬក៏ឲ្យខ្ញុំបញ្ជាក់ឡើងវិញ? តើលោកស្រីនៅក្នុងរបបខ្មែរក្រហមហ្នឹង រៀបការដោយចិត្តឯង ឬក៏មានការរៀបចំដោយអ្នកណា?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស នៅរបបនោះ គឺខ្ញុំមិនមែនស្ម័គ្រចិត្តរៀបការដោយចិត្តឯងទេ គឺពេលនោះ ខ្ញុំរស់នៅក្នុងកង។ ពេលយប់មួយ នៅម៉ោងប្រាំពីរយប់ ម៉ោងប្រាំមួយកន្លះមានសារសំបុត្រមួយទៅហៅខ្ញុំថា "ឲ្យមកជួបជុំនៅសាលាឃុំជាបន្ទាន់ កុំឲ្យយប់ទាន់"។ ខ្ញុំពេលនោះ ក៏ខ្ញុំអត់ដឹងខ្លួនដែរថាមិនដឹង ព្រោះអីឪពុកខ្ញុំទើបតែស្លាប់ថ្មីៗ នៅរយៈពេល២ថ្ងៃ។ ដល់ពេលហើយ គេកោះហៅខ្ញុំមកទៀត ខ្ញុំក៏មានការរន្ធត់ហើយភ័យ មិនដឹងថា ខ្ញុំកើតរឿងអីដែរ។ ដល់ពេលនោះ ខ្ញុំមកដល់កង ស្រាប់តែប្រធានកងនារីឈ្មោះអុល គាត់ក៏បានប្រាប់ថា "អាឥឡូវរៀបចំទៅ យប់ហ្នឹងអង្គការសម្រេចប្ដេជ្ញាយប់ហ្នឹងហើយ"។ ខ្ញុំក៏

មានរន្ធត់ មិនដឹងថា ខ្ញុំរៀបការជាមួយយុវជនណា ក៏ខ្ញុំអត់ហ៊ានសួរគេដែរ។ រួចហើយគេសួរខ្ញុំថា "ម៉េច! សម្រេចចិត្តម៉េចហើយ?" ខ្ញុំថា "អ្ហឺ! ស្រេចទៅលើឪពុកម្ដាយ។ ខ្ញុំផ្អែកលើឪពុកម្ដាយ -- ម្ដាយខ្ញុំ"។ ដល់គេថា "ឥឡូវរាល់ថ្ងៃយើងកូនអង្គការ ឬមួយកូនឪពុកម្ដាយ?" ខ្ញុំឆ្លើយថា "ខ្ញុំកូនអង្គការ"។ "អ៊ីចឹង កូនអង្គការរៀបចំយប់ហ្នឹងទៅ។ រៀបចំខ្លួនទៅ គឺអង្គការប្ដេជ្ញាឲ្យយប់ហ្នឹងហើយ"។ ដល់ខ្ញុំឆ្ងល់ខ្ញុំក៏អត់ទ្រាំមិនបាន ខ្ញុំក៏សួរថា "ចុះ! រៀបចំឲ្យជាមួយយុវជនណា?" ដល់គេថា "ឈ្មោះ ទ្រី ទូច"។ ខ្ញុំក៏អត់ហ៊ានប្រកែកដែរ ពេលនោះ ក៏ខ្ញុំអត់ចិត្តដែរ ប៉ុន្តែមកពីខ្ញុំអត់ហ៊ានប្រកែក ក៏សម្រួលចិត្តរៀបចំ។ ចាស រៀបចំទៅ គេហៅឲ្យនៅក្នុងបន្ទប់ នៅកន្លែងកម្មវិធីហ្នឹង។ អ៊ីចឹង ប្ដីខ្ញុំក៏គាត់អត់ទាន់មកដល់ ខ្ញុំចេះតែអង្គុយរង់ចាំទៅ។ ក្រោយមកខ្ញុំអង្គុយមួយស្ទុះអ៊ីចឹង បានឃើញប្ដីរបស់ខ្ញុំមកដល់។

[០៩:៥៣:០៥]

**ស៖** លោកស្រីបានរំឭកដល់ពាក្យ "ប្ដេជ្ញា"។ តើមានន័យថាម៉េច ពាក្យថា "ប្ដេជ្ញា"?

**ឆ៖** ចាស ពេលនោះវាមានប្រធានកង និងមេឃុំហ្នឹងជាគណៈធិបតី។ ពេលនោះក៏គេសួរចម្លើយយើង ខាងប្រុស សួរថា "ឥឡូវ រៀបការជាមួយនារី ដោយស្ម័គ្រចិត្តដោយខ្លួនឯង ឬមួយមានអ្នកណាបង្ខំចិត្តឬទេ?" ប្ដីខ្ញុំក៏ឆ្លើយថា "ខ្ញុំរៀបការដោយស្ម័គ្រចិត្ត អត់មានអ្នកណាបង្ខំចិត្តឡើយ"។ ក្រោយមកប្រធានកងក៏មកសួរខ្ញុំម្ដង ដល់សួរខ្ញុំៗហើយ ខ្ញុំក៏ឆ្លើយថា "ខ្ញុំដោយរៀបការដោយស្ម័គ្រចិត្តដោយខ្លួនឯង គ្មានអ្នកណាខិតខំ -- បង្ខំចិត្តខ្ញុំ"។ អ៊ីចឹង តាមការពិត ខ្ញុំតែចេះឆ្លើយឲ្យស្របនឹងការណែនាំរបស់គេទៅ ចាស។

**ស៖** អ៊ីចឹងមានន័យថា លោកស្រីមិនបានស្ម័គ្រចិត្តរៀបការទេ មែនទេ?

**ឆ៖** ចាស ខ្ញុំអត់មានការស្ម័គ្រចិត្តទេ តែពេលនោះត្រូវតែស្ម័គ្រចិត្ត។ បើកាលណាមិនស្ម័គ្រចិត្ត គឺឪពុកខ្ញុំទើបតែស្លាប់ថ្មីៗ ខ្ញុំត្រូវការបាត់ខ្លួនទៀត។ អ៊ីចឹងខ្ញុំអ្វី ខ្ញុំត្រូវតែធ្វើតាមគេ។

**ស៖** តើខ្ញុំនិយាយជាការត្រឹមត្រូវទេ។ នៅពេលដែលខ្ញុំនិយាយថា ពេលនោះលោកស្រីនិយាយប្រាប់អង្គការ គឺខុសពីចិត្តដែលលោកស្រីចង់ មានន័យថា លោកស្រីមិនមែនចង់រៀបការដោយចិត្តឯងនោះទេ គឺមានការបង្ខំ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ការសាកសួរនេះជាត្រឹមត្រូវណាស់ ដោយថាខ្ញុំរៀបការដោយទាំងបង្ខំចិត្តចាស។ រួចហើយខ្ញុំក៏បាន គេ -- បានប្ដេជ្ញាចិត្តចំពោះមុខសមូហភាព បានប្ដេជ្ញាថា "ខ្ញុំយកយុវជននេះអស់មួយជីវិត" រួចយុវជនក៏គេបានថា "ខ្ញុំទទួលនារីនេះអស់មួយជីវិតដែរ"។ ចាស ប៉ុណ្ណឹងការរៀបចំរបស់ខ្ញុំចប់

ជាស្ពាន។

**ស៖** តើអ្នកណាជាអ្នកសម្រេចជ្រើសរើសគូស្រករឲ្យអ្នកស្រី?

[០៩:៥៦:១៤]

**ឆ៖** ចាស អ្នកសម្រេចរើសគូស្រករនោះ គឺមេឃុំ អ្នកដឹកនាំទាំងក្នុងឃុំទាំងមូលហ្នឹងគេអ្នករៀបចំ។ តែមុននឹងគេរើសរៀបចំហ្នឹង គេរើសប្រវត្តិរូប ប្រវត្តិរូបប្ដីខ្ញុំនិងខ្ញុំហ្នឹង រើសទៅប្រវត្តិរូបហ្នឹងវាស៊ីគ្នា អ៊ីចឹងគេរៀបអ្នកដែលរៀបការហ្នឹងដល់ប្រវត្តិរូបវាត្រូវគ្នាដែរ។ បើប្រវត្តិរូបគេ វណ្ណៈគេៗទាបជាង ឬមួយវណ្ណៈគេខ្ពស់ជាង ក៏ឥតរៀបការចំពោះគ្នាបានដែរ។ ដល់អ្នកហ្នឹងៗប្រវត្តិរូបហ្នឹងមានទិន្នាការដូចគ្នាបានអាចរៀបការបាន។

**ស៖** សូមឲ្យលោកស្រីបញ្ជាក់ថា ប្រវត្តិរូបដូចគ្នា ឬក៏ស្រដៀងគ្នា វាត្រូវគ្នាហ្នឹង លោកស្រីបាន -- ចង់បានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ចាស ប្រវត្តិរូបដែលថា វាដូចគ្នាហ្នឹង ស្រដៀងគ្នាហ្នឹង ដូចថាប្រវត្តិរូបចំពោះខ្ញុំអ៊ីចឹងវាមានទិន្នាការប្រវត្តិរូបគេដាក់ ជនជាតិ ដូចថាចិនភាគតិចអ៊ីចឹង តែចំពោះប្ដីខ្ញុំក៏ប្រវត្តិរូបអ៊ីចឹងដែរ ចិនភាគតិច។ អ៊ីចឹងជាប់ខ្សែៗដូចគ្នាហ្នឹងគេរៀបការតាមហ្នឹងចាស។

**ស៖** ចាស អរគុណ។ អ៊ីចឹងមានន័យថា ប្ដីលោកស្រីហ្នឹងជាប្រភេទក្រុមមនុស្សដែលអង្គការបែងចែកដូចជាលោកស្រីដែរ ដែលលោកស្រីបានបញ្ជាក់ពីមុនជាប្រជាជនត្រៀមអ៊ីចឹង ឬក៏ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស អ៊ីចឹងហើយអ្នកគ្រូ វាត្រឹមត្រូវហើយគេប្រភេទនៅក្នុងប្រជាជនត្រៀមដូចគ្នា។

[០៩:៥៨:២៩]

**ស៖** តើអ្នកដែលលោកស្រីត្រូវរៀបការជាមួយ ដែលជាស្វាមីលោកស្រីឈ្មោះ ទ្រី ទូច ហ្នឹងលោកស្រីធ្លាប់ស្គាល់គាត់ពីមុនច្បាស់ទេ ឬក៏ធ្លាប់បានជួបគាត់ពីមុននៅកន្លែងណាទេ?

**ឆ៖** ចាស វាដូចថានៅក្នុងឃុំជាមួយគ្នា ប៉ុន្តែគេប្រធានកងហ្នឹងវានៅឆ្ងាយពីគ្នា តាមការពិតគេប្រធាននៅ -- នៅកងយុវជនដែរ ប៉ុន្តែខ្ញុំអត់ស្គាល់គេទេ ឥតស្គាល់បានស្គាល់ខ្លះ មិនមែនថាមិនស្គាល់ទេ។ ប៉ុន្តែពេលអ្នកដែលខ្ញុំស្គាល់ហ្នឹង ដូចថាវាអត់មានការពេញចិត្ត ដូចហាក់បីដូចជាស្អប់គាត់ ពីមុនមកស្អប់គាត់។ ដល់តែពេលគេសម្រេចឲ្យប្ដេជ្ញាជាមួយបុរសហ្នឹងទៅ ហាក់បីដូចថាខ្ញុំមានវិប្បដិសារីណាស់ ដូចថាវាអត់ពេញចិត្តនឹងចំពោះបុរសហ្នឹងទេ។ ដូចថាបុរសហ្នឹងពីមុនមក ខ្ញុំដូចថាវាអត់ពេញ

ចិត្ត ឃើញគាត់វាអត់ពេញចិត្តមកហើយស្អប់គាត់ និយាយទៅស្អប់តែម្តងចាស។ ដល់តែពេលហើយមកឲ្យរៀបការចំពោះអ្នកដែលខ្ញុំស្អប់ហ្នឹង ខ្ញុំមានវិប្បដិសារីក្នុងមួយយប់ ប៉ុន្តែដូចថាខ្ញុំខ្លាចគេ ចេះតែរៀបការដោយបង្ខំចិត្ត។ ចាស ប៉ុណ្ណឹង។

**ស៖** តើខ្ញុំនិយាយជាការត្រឹមត្រូវទេ មានន័យថាលោកស្រីរៀបការដោយបង្ខំជាមួយមនុស្សដែលលោកស្រីស្អប់ លោកស្រីមិនស្គាល់ច្បាស់ទាល់តែសោះ?

[១០:០០:១៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក គង់ សំអុន៖**

បាទ សូមទោសលោកប្រធាន ខ្ញុំ គង់ សំអុន។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ ហើយខ្ញុំយល់ថាជាសំណួរនាំមុខ សាក្សីលោកបានឆ្លើយបញ្ជាក់ហើយថា គាត់រៀបការដោយមានការបង្ខំចិត្ត មិនមែនជាការរៀបការដោយបង្ខំទេ។ ហើយតំណាងសហព្រះរាជអាជ្ញាព្យាយាមលើកសំណួរនេះច្រំដែលពីរបីដង ដើម្បីចង់ឲ្យសាក្សីឆ្លើយបញ្ជាក់ទៅលើពាក្យនេះ ហើយការធ្វើបែបនេះមិនត្រឹមត្រូវទេ សូមជំទាស់។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបថា ហើយលោកស្រីសាក្សីបាននិយាយបញ្ជាក់ហើយថា គាត់រៀបការដោយៗមិនពេញចិត្ត ដោយបង្ខំ។ ហើយអ៊ីចឹងខ្ញុំគ្រាន់តែសួរបញ្ជាក់ ថាតើខ្ញុំយល់អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ? អ៊ីចឹងសូមឲ្យលោកប្រធានសម្រេចដើម្បីឲ្យខ្ញុំអាចបន្តសំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មានមូលដ្ឋានត្រឹមត្រូវ សមស្រប។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញារងជាតិអម្បាញ់មិញនេះទេ។ លោកស្រីអាចតាំងសំណួរផ្សេងទៀត។

[១០:០១:៣១]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** អ៊ីចឹងខ្ញុំសួរលោកស្រីបែបអ៊ីចេះវិញ។ តើលោកស្រីចង់រៀបការជាមួយនឹងមនុស្សដែលលោកស្រីមិនដែលស្គាល់ដែរឬទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស តាមការពិត--

**ប្រធានអង្គជំនុំ៖**

បាទកុំអាលៗទាន់ឆ្លើយតប! សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរនេះ។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួរនោះគឺ<កំពុងតែនិយាយខុសពីភស្តុតាងហើយ ព្រោះ>សាក្សីបានបញ្ជាក់ថាគាត់ស្គាល់ប្តីរបស់គាត់<ពីមុនមកហើយ ហើយពួកគេរស់>នៅក្នុងភូមិជាមួយគ្នា។ ដូច្នេះសូមឲ្យសហព្រះរាជអាជ្ញាកែសម្រួលសំណួរជាថ្មី។

[១០:០២:១៩]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស ខ្ញុំនឹងសួរលោកស្រីម្តងទៀត។ តើលោកស្រីចង់រៀបការជាមួយបុរសម្នាក់នោះដែរឬទេ នៅពេលនោះ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស នៅពេលនោះគឺខ្ញុំអត់ចង់រៀបការទេជាមួយបុរសនោះ។

**ស៖** ចាស សូមអរគុណ។ តើនៅក្នុងរបបខ្មែរក្រហម លោកស្រីមានការលំបាកទេនៅពេលដែលគេប្រាប់លោកស្រីថាលោកស្រីត្រូវរៀបការជាមួយបុរសម្នាក់នោះ? អារម្មណ៍លោកស្រីពេលនោះបែបណាដែរ?

**ឆ៖** ចាស អារម្មណ៍របស់ខ្ញុំពេលៗគេហៅខ្ញុំមករៀបការគឺខ្ញុំពិបាកចិត្តណាស់។ ពេលនោះខ្ញុំក៏លួចយំអត់ឲ្យគេដឹង។ លួចយំអត់ឲ្យគេដឹង ហើយខ្ញុំនិយាយត្រង់ទៅខ្ញុំទៅលួចបន់ព្រះ ពេលនោះវាមានវិហារនៅជិត ខ្ញុំទៅលួចបន់ព្រះទៀត ខ្ញុំថាសូមព្រះអង្គកុំឲ្យមានកម្មវិធីនេះកើតឡើងចាស។ ពេលនេះខ្ញុំថាបើពិតជាគូព្រេងរបស់ខ្ញុំវិញ សូមឲ្យចិត្តខ្ញុំទន់ ហើយសូមឲ្យមានកម្មវិធីហ្នឹងកើតឡើងចុះ បើសិនណាមិនមែនគូព្រេងរបស់ខ្ញុំទេ សូមឲ្យកុំឲ្យមានកម្មវិធីហ្នឹងកើតឡើងនៅក្នុងពេលយប់ហ្នឹង។ ពេលហ្នឹងនៅ

តែកម្មវិធីនៅតែមានកើតឡើង។

**ស៖** បើលោកស្រីមិនចង់រៀបការជាមួយនឹងបុរសម្នាក់នោះ ហេតុអ្វីបានជាលោកស្រីមិនបដិសេធទៅពេលហ្នឹង ពេលគេឲ្យលោកស្រីឡើងប្ដេជ្ញា?

[១០:០៥:៣៣]

**ឆ៖** ចាស ពេលនោះទោះបីចិត្តខ្ញុំមិនចង់រៀបការមិនស្រលាញ់ប្ដីក៏ដោយ ក៏ខ្ញុំត្រូវតែសម្រួលចិត្តដែរ ខ្ញុំអត់ហ៊ានប្រឆាំងទេ។ ពេលកាលដែរ ពេលដែលខ្ញុំប្រឆាំងនៅពេលនោះ ខ្ញុំមិនមានរៀបការ គឺខ្ញុំត្រូវតែស្លាប់ខ្លួននៅពេលហ្នឹងហើយ ត្រូវតែស្លាប់ ព្រោះអីឪពុកខ្ញុំទើបតែស្លាប់ថ្មីៗ។ ពេលនោះបើកាលណាខ្ញុំប្រឆាំងនៅពេលហ្នឹងទៀត គេថានៅប្រឆាំងបក្ស អ៊ីចឹងខ្ញុំជាមនុស្សប្រឆាំងក្រុម -- ក្រុមគ្រួសារខ្ញុំជាមនុស្សប្រឆាំងបក្ស។ អ៊ីចឹង ខ្ញុំត្រូវស្លាប់ខ្លួននៅពេលហ្នឹងទៀតហើយ។ អ៊ីចឹងដើម្បីសេចក្ដីរស់ ចាស ខ្ញុំត្រូវតែសម្របចិត្តធ្វើតាមអ្វីទាំងអស់នៅពេលហ្នឹង។

**ស៖** ចាស សូមអរគុណ។ ឥឡូវខ្ញុំចូលមកដល់ពិធីដែលគេរៀបចំឲ្យលោកស្រីរៀបការ តើពិធីហ្នឹងធ្វើឡើងនៅពេលវេលាណាដែរ? នៅម៉ោងប៉ុន្មាន? លោកស្រីចាំទេ?

**ឆ៖** ពេលនោះម៉ោងៗប្រាំបីកន្លះ។ ម៉ោងប្រាំបីកន្លះគេចាប់ផ្ដើមកម្មវិធី រហូតម៉ោងដប់ៗកន្លះប៉ុណ្ណឹង គឺចប់កម្មវិធីចាស។

**ស៖** តើមានរយៈពេលប៉ុន្មាន នៅពេលដែលលោកស្រីដឹងថាលោកស្រីត្រូវៗរៀបការហ្នឹង? ហើយនៅពេលដែលដល់ម៉ោងប្រាំបីកន្លះត្រូវរៀបការហ្នឹង វាមានរយៈពេលប៉ុន្មានដែលលោកស្រីអាចត្រៀមរៀបចំខ្លួន?

**ឆ៖** ចាស អត់បានត្រៀមផងព្រោះអីអត់ដឹង។ សំបុត្រសារមកហៅ នីរសារមកហៅក៏អត់បានបញ្ជាក់ថាការរៀបចំអាពាហ៍ពិពាហ៍អីក៏អត់ដែរ ខ្ញុំវាអត់ដឹង។ វាមានតែការភ័យស្លុត មិនដឹងជាមូលហេតុអី មិនដឹងជាកើតរឿងអីទៀត ព្រោះអីមិនងាយមេឃុំណាកោះហៅទេ មនុស្សៗម្នាក់។ អ៊ីចឹង នឹកស្មានថាមានរឿងកំហុសអីទៀតហើយ។ អ៊ីចឹង ការរៀបចំនោះអត់មានបានត្រៀមខ្លួនទេ។

[១០:០៧:០០]

**ស៖** ចុះជាក់ស្ដែងការរៀបការហ្នឹងគេធ្វើឡើងនៅទីតាំងណាដែរ?

**ឆ៖** ចាស ការរៀបចំហ្នឹងវាមានមន្ទីរបក្សមួយឈ្មោះកន្លែងសាលាឃុំញ៉ែងញ៉ងហ្នឹង។ គេហ្នឹងកន្លែងហ្នឹងកន្លែងមន្ទីរបក្ស កន្លែងប្រធានកង ប្រធានឃុំអីហ្នឹងគេស្នាក់នៅកន្លែងហ្នឹង។ អ៊ីចឹងគេហៅ

មកការ រៀបចំប្តេជ្ញានៅកន្លែងហ្នឹង។

**ស៖** នៅពេលដែលលោកស្រីទៅដល់មន្ទីរបក្សដើម្បីឡើងប្តេជ្ញាហ្នឹង អ្នកដែលលោកស្រីត្រូវរៀបការជាមួយហ្នឹង គាត់មកដល់មុនលោកស្រីឬក៏គាត់មកដល់ពីខាងក្រោយ មានន័យថាមកតាមក្រោយ?

**ឆ៖** ចាស ខ្ញុំមកត្រៀមអង្គុយមុន។ តែចំពោះប្តីខ្ញុំ ក្រោយមកគាត់ប្រាប់ខ្ញុំគាត់អត់ដឹងផង។ គាត់ចូលទៅហូបបាយនៅសហករណ៍ហ្នឹង ក៏មាននីរសារទៅហៅថាបងឲ្យទៅចាប់គោ គោដាច់នៅសាលាឃុំ។ គាត់ក៏ហូបបាយប្រញាប់ៗហ្នឹងថាមិនឆ្អែងផង ឮថាគោដាច់។ ដល់ចូលមកដល់ គេថាអ្វីយូរម្ល៉េះ ខ្ញុំចាំអើតមើលនៅមាត់ គាត់នៅអង្គុយចាំអ៊ីចឹងមិនឃើញគាត់មក គេថាអ្វីយូរម្ល៉េះ ចូលលឿនឡើង។ ដោយគាត់អត់ដឹងហេតុអីផង គាត់ក៏អត់ដឹងថាពេលហ្នឹងគាត់រៀបការដែរ។ គេរុញគាត់ទៅចូលទៅអង្គុយតុហ្នឹង សក់គាត់ស្រមិះស្រមូស ឃើញគាត់យកដៃសិតធ្វើអ៊ីចឹង។ ហើយគាត់ក៏អត់ដឹងខ្លួនថារៀបការជាមួយ ខ្ញុំក៏អត់ដែរ ពេលហ្នឹងគាត់ស្មានថាគោដាច់ គាត់មកចាប់គោ។ ដល់ហើយគេរុញចូលនៅក្នុងកន្លែងសាលាប្តេជ្ញាហ្នឹងទៅ គាត់ទៅអង្គុយទន្ទឹមគ្នា កៅអីមួយម្នាក់អ៊ីចឹង។ មិនបានត្រៀមខ្លួនទាំងពីរនាក់ដូចគ្នា ប៉ុន្តែខ្ញុំដឹងមុន គាត់អត់ដឹងសោះ។ ខ្ញុំគេបានប្រាប់ តែចំពោះប្តីខ្ញុំគេអត់បានប្រាប់ថារៀបចំជាមួយនារីណា អត់ទេ។

[១០:០៩:១៧]

**ស៖** ចាស សូមអរគុណ។ ហើយនៅពេលដែលត្រូវរៀបការហ្នឹង តើមានអ្នកណាខ្លះជាគណៈអធិបតី? ហើយមានអ្នកណាខ្លះបានចូលរួម?

**ឆ៖** ចាស អ្នករៀបចំជាគណៈអធិបតីហ្នឹងមានមេឃុំហ្នឹងឈ្មោះ អឿន និងកង -- ប្រធានកងនារីឈ្មោះ អុល អ៊ីចឹងទៅ ហើយអ្នកចូលរួមមានម្តាយខ្ញុំមួយនិងយាយខ្ញុំមួយ និងៗប្រធានកងអីគេមានតួនាទីអីនៅក្នុងហ្នឹងបីបួន ដប់នាក់ប៉ុណ្ណឹង។

**ស៖** សូមឲ្យលោកស្រីជួយបញ្ជាក់ឈ្មោះម្តងទៀត ថាតើមេឃុំដែលជាគណៈអធិបតីចូលរួមនោះ គាត់មានឈ្មោះអ្វី ប្រសិនបើលោកស្រីអាចបញ្ជាក់បាន? ហើយឈ្មោះពេញរបស់គាត់អ្វីដែរ?

**ឆ៖** ពេលនោះឈ្មោះអី អឿន ហើយទេ ត្រកូលគាត់ហ្នឹងចាំតែ អឿនៗ ហ្នឹង។ ពេលហ្នឹងមិនសូវស្គាល់ប្រធានកងច្បាស់ទៀត។ ហើយប្រធាននារីហ្នឹងឈ្មោះ អុល ហ្នឹងមិនដឹងឈ្មោះអីទេ ពេលហ្នឹងមិនសូវស្គាល់ឈ្មោះច្បាស់ៗទេ ស្គាល់តែ អុលៗ ហ្នឹងតែម្តង នាមត្រកូលអត់ស្គាល់ទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:១១:០៦]

**ស៖** ដើម្បីបញ្ជាក់ត្រង់ចំណុចនេះ ខ្ញុំយោងទៅនឹងចម្លើយរបស់លោកស្រីនៅត្រង់ចម្លើយលេខ៨ លោកស្រីបានប្រាប់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា ខ្ញុំសូមដកស្រង់៖ "ហឿន ដែលជាមេឃុំ និង អុល ជាមេកងនារី ជាគណៈអធិបតីក្នុងពិធីនោះ។" អ៊ីចឹងសូមឲ្យលោកស្រីបញ្ជាក់ថា តើមេឃុំហ្នឹងឈ្មោះ ហឿន ឬក៏ឈ្មោះ អឿន?

**ឆ៖** ចាស មេឃុំនោះឈ្មោះ ហឿន។

**ស៖** ចុះអ្នកណាដែលលោកស្រីរំឭកដល់ថាជា មេឃុំឈ្មោះ អឿន នោះ?

**ឆ៖** ចាស មានការភ័ន្តច្រឡំ។

**ស៖** ដើម្បីជាកំណត់ត្រា សូមឲ្យលោកស្រីបញ្ជាក់ម្តងទៀតថា តើមេឃុំដែលបានចូលរួមនៅក្នុងកម្មវិធីជាគណៈអធិបតីការរៀបការរបស់លោកស្រីហ្នឹង ឈ្មោះអ្វីឲ្យពិតប្រាកដ?

**ឆ៖** ចាស ឈ្មោះ ហឿន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា

ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយរំឭកថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផង មានពេលត្រឹមតែម៉ោងដប់មួយនិងសាមសិបនាទីប៉ុណ្ណោះ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

លោកស្រី ខ្ញុំនឹងបន្តសំណួរសួរលោកស្រីបន្ថែមបន្តិចទៀត មុនពេលនឹងបញ្ចប់នៅពេលដែលមុនសម្រាកបន្តិចនោះ លោកស្រីបានរំឭកដល់គណៈអធិបតីដែលចូលរួមក្នុងពិធីមង្គលការរបស់លោកស្រី។ ខ្ញុំមានឯកសារមួយចង់បង្ហាញលោកស្រី។

លោកប្រធាន សូមអនុញ្ញាតការពីលោកប្រធាន ដើម្បីបង្ហាញឯកសារមួយដល់សាក្សី គឺឯកសារ D232/71។ ឯកសារនេះ បានជាកំណត់ហេតុការសួរចម្លើយសាក្សីម្នាក់ទៀត ហើយសូមឲ្យផ្ដល់ជូនទៅសាក្សី ប៉ុន្តែនៅពេលដែលសាក្សីអានឯកសារនេះ សូមបញ្ជាក់សាក្សីថា លោកស្រីគ្រាន់តែអានបានហើយ ដោយមិនចាំបាច់ប្រាប់ឈ្មោះអ្នកដែលលោកស្រីឃើញនៅក្នុងកំណត់ហេតុនេះទេ។ ខ្ញុំនឹងសួរលោកស្រី។

[១០:៣៣:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលទទួលឯកសារជាក្រដាសពីសហព្រះរាជអាជ្ញា យកទៅជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកស្រី នៅឯកសារហ្នឹង គឺត្រង់ទំព័រទី១ និងទំព័រទី២ នៃឯកសារដែលលោកស្រីកំពុងតែកាន់ហ្នឹង សូមលោកស្រីពិនិត្យឈ្មោះ អ្នកដែលលោកស្រីបានឃើញ។ ហើយលោកស្រីប្រាប់ទៅអង្គសវនាការថា ឈ្មោះអ្នកដែលលោកស្រីបានឃើញដែលត្រូវគេសម្គាសនៅក្នុងកំណត់ហេតុហ្នឹង ជាអ្នកដែលបានចូលរួមនៅក្នុងកម្មវិធីរៀបអាពាហ៍ពិពាហ៍លោកស្រីដែលជាគណៈអធិបតីមែនទេ? គ្រាន់តែប្រាប់ថាមែន ឬមិនមែនបានហើយ លោកស្រីមិនចាំបាច់អានឈ្មោះគាត់ទេ។

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាសចាប់អានៗទាំងអស់ហ្នឹង? លោកប្រធាន ចាប់អានទាំងអស់ហ្នឹង?

[១០:៣៥:១៨]

**ប្រធានអង្គជំនុំ៖**

អត់ទេ ចាំមើលចំណុចៗដែលគេនឹងប្រាប់ ហើយមន្ត្រីរដ្ឋបាលសម្របសម្រួល ដើម្បីបង្ហាញចំណុចដែលៗគាត់ត្រូវពិនិត្យមើល ហើយនិងត្រូវឆ្លើយតបទៅនឹងសំណួរ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាសនៅត្រង់ទំព័រទី១ បន្ទាប់ចុងក្រោយគេ ដែលមានអក្សរដិតធំ –ជាឈ្មោះរបស់បុគ្គលម្នាក់– ថាតើលោកស្រីឃើញទេ? គ្រាន់តែឈ្មោះបានហើយ ឈ្មោះនៅទំព័រទី១ នៅបន្ទាត់ចុងក្រោយគេ។ ចាសអ៊ីចឹងខ្ញុំចាប់ផ្ដើមសួរ តើមនុស្សដែលលោកស្រីបានឃើញនៅក្នុងកំណត់ហេតុហ្នឹង ជាឈ្មោះមនុស្សម្នាក់ហ្នឹង ជាអ្នកដែលបានចូលរួមនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់លោកស្រីនៅក្នុងរបបខ្មែរក្រហមមែនទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ឈ្មោះដែលអ្នកចូលរួម អត់បានស្គាល់ដែរចាស ខ្ញុំអត់បានស្គាល់។

**ស៖** ចាស អរគុណ។ ឥឡូវខ្ញុំចូលមកដល់ពិធីរៀបអាពាហ៍ពិពាហ៍របស់លោកស្រីនៅក្នុងរបបនោះ។ លោកស្រីបានរៀបរាប់រួចហើយថា នៅពេលចូលមកដល់ថ្ងៃដែលគេឲ្យលោកស្រីឡើងប្ដេជ្ញាហ្នឹង មានគណៈអធិបតីចូលរួម។ ហើយចុះបន្ទាប់ពីលោកស្រីឡើងប្ដេជ្ញានៅយប់ហ្នឹងហើយ តើមានរឿងអ្វីបានកើតឡើងបន្ទាប់មកទៀត?

[១០:៣៧:៥១]

**ឆ៖** ចាសរួចពីបានប្ដេជ្ញារួចហើយ នេះគឺជាការពិតណាស់ គេក៏បានចាត់តាំងដកចេញពីក្នុងអង្គភាពពីក្នុងកង ឲ្យចាត់តាំងជាផ្ទះមួយឲ្យមកស្នាក់នៅ រៀបចំផ្ទះមួយឲ្យស្នាក់នៅ។ ប៉ុន្តែចំពោះខ្ញុំ អត់បានមកចូលរួមនៅផ្ទះហ្នឹងទេ ពេលការប្ដេជ្ញាយប់ហ្នឹងហើយ ប្ដីរបស់ខ្ញុំក៏គេមកៗត្រៀមខ្លួននៅចាំនៅផ្ទះដែលអង្គការរៀបចំប្រគល់ឲ្យ។ តែចំពោះខ្ញុំ ទៅកន្លែងកងៗនារីវិញ។ នៅហ្នឹងធម្មតាដូចរស់នៅដូចសព្វដង ប៉ុន្តែប្រធានកងគេអត់ដឹង។ ពេលនោះគេស្មានតែខ្ញុំហ្នឹង មកនៅកន្លែងផ្ទះដែលគេរៀបចំហើយដល់រំលង៣ថ្ងៃ បានគេដឹងថា ខ្ញុំអត់មកកន្លែងនោះ ក៏គេមានសំបុត្រនីរសារហ្នឹង ក៏គេឲ្យហៅមករួមរស់ជាមួយប្ដីខ្ញុំដែលផ្ទះគេរៀបចំឲ្យហ្នឹង ក៏ខ្ញុំត្រូវវិលត្រឡប់មកផ្ទះហ្នឹង មូលប្ដីមូលប្រពន្ធនៅផ្ទះដែលអង្គ

ការគេរៀបចំឲ្យហ្នឹងមក។

**ស៖** អ្នកណាជាអ្នក -- ៣ថ្ងៃក្រោយមកហ្នឹង តើអ្នកណាជាអ្នកហៅលោកស្រីឲ្យមករស់នៅក្នុងផ្ទះដែលអង្គការរៀបចំឲ្យ?

**ឆ៖** មេឃុំឈ្មោះ បឿន ក៏បានទៅហៅឲ្យមកផ្ទះដែលអង្គការរៀបចំឲ្យហ្នឹង មូលប្ដីមូលប្រពន្ធហ្នឹង គឺមេឃុំឈ្មោះ បឿន ហ្នឹងចាស។

**ស៖** នៅក្នុងចម្លើយដែលលោកស្រីបានឆ្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺនៅត្រង់ចម្លើយលេខ៨ លោកស្រីបាននិយាយថា ខ្ញុំដកស្រង់៖ "ក្រោយមក៣ថ្ងៃ មេកងប្រាប់ខ្ញុំឲ្យទៅនៅជាមួយប្ដីរបស់ខ្ញុំ"។ អ៊ីចឹងចង់ឲ្យលោកស្រីបញ្ជាក់ថា តើពេលហ្នឹងអ្នកណាជាអ្នកប្រាប់លោកស្រី? មេកង ឬក៏ឈ្មោះ បឿន?

**ឆ៖** ចាស ឈ្មោះ បឿន ជាមេឃុំក្ដាប់រួមចាស។

[១០:៤០:៥១]

**ស៖** លោកស្រីនៅចាំបានទេថា នៅពេលនោះ តើ បឿន បាននិយាយប្រាប់លោកស្រីថាយ៉ាងដូចម្ដេច? ពាក្យដែល បឿន និយាយលោកស្រីនៅចាំបានទេ?

**ឆ៖** ចាស ពេលនោះក៏គេ ខ្ញុំក៏ភ្លេចពាក្យអស់ដែរ វាយូរមកហើយ ប៉ុន្តែពេលនោះគេអត់មានគំរាមកំហែងអីទេ គេគ្រាន់តែថាឲ្យទៅមូលប្ដីមូលប្រពន្ធ ទៅផ្ទះដែលរៀបចំឲ្យ តែប៉ុណ្ណឹង ខ្ញុំក៏រៀបចំមកទាំងយប់។

**ស៖** តើលោកស្រីយល់ន័យថា "មូលប្ដីមូលប្រពន្ធ" ហ្នឹងមានន័យថាយ៉ាងម៉េចដែរ? សូមឲ្យលោកស្រីជួយបកស្រាយបញ្ជាក់។

**ឆ៖** ហ្នឹងគេឲ្យយើងមករស់នៅឲ្យត្រូវស៊ីសង្វាក់គ្នា។ ពេលនោះក៏ក្នុងពេលយប់ដែលខ្ញុំមករស់នៅជាមួយប្ដីហ្នឹង ខ្ញុំក៏លបឃើញឈ្លបមានឈ្លបនៅក្រោមផ្ទះ គេស៊ើបអង្កេតយើង ក្រែងលោយើងមិនស៊ីសង្វាក់គ្នាជាមួយប្ដីប្រពន្ធអ៊ីចឹង។ អ៊ីចឹងពេលនោះក៏ខ្ញុំដឹងថាមានឈ្លប ក៏ខ្ញុំសម្រួលចិត្ត ឥតមានបញ្ហាអីកើតឡើងជាមួយប្ដីប្រពន្ធទេ គឺដេកស្ងប់ដោយស្ងៀមស្ងាត់ ដោយការខ្លាចភ័យ ខ្លាចមានបញ្ហាកើតឡើងចាស ព្រោះអី ពេលនោះមានឈ្លបនៅក្រោមផ្ទះ។

**ស៖** តើយប់ដែលលោកស្រីឃើញឈ្លបដែលលបនៅខាងក្រោមផ្ទះនោះ លោកស្រីមានបានរួមដំណេកជាមួយគ្រួសារលោកស្រី ឬក៏ប្ដីលោកស្រីទេ?

[១០:៤៣:១៦]

**ឆ៖** ចាស មាន។

**ស៖** តើពេលនោះលោកស្រីធ្វើដោយស្ម័គ្រចិត្ត ឬក៏ដោយបង្ខំចិត្ត?

**ឆ៖** ចាស ពេលនោះខ្ញុំត្រូវតែស្ម័គ្រចិត្ត បើកាលណាយើងកើតមានបញ្ហា ខ្លាចវាមានគ្រោះថ្នាក់ ព្រោះក្នុងការភ័យខ្លាចមានឈ្លបនៅពីក្រោមអ៊ីចឹង។ ខ្ញុំដូចថា សម្រួលចិត្តដាក់ចិត្ត ក្នុងចិត្តថាវាជៀសវាងប្តីប្រពន្ធ ពីថ្ងៃនេះទៅវាជៀសវាងប្តីប្រពន្ធឥតៗជៀសវាងមិនផុត អ៊ីចឹងខ្ញុំត្រូវតែសម្រួលចិត្ត។

**ស៖** តើចិត្តពិតប្រាកដរបស់លោកស្រីនៅពេលនោះ លោកស្រីចង់ធ្វើដូច្នេះ ឬក៏លោកស្រីគិតថាគ្មានជម្រើសអីផ្សេងត្រូវធ្វើ?

**ឆ៖** ចាស ខ្ញុំគិតថា គ្មានជម្រើសអីផ្សេងក្រៅពីប្តីប្រពន្ធ។ បើកាលណាបើខ្ញុំមិនយកគ្នា គឺខ្ញុំខ្វះសេចក្តីសុខ ខ្ញុំនឹងបាត់បង់ជីវិត។ អ៊ីចឹងខ្ញុំត្រូវតែដាក់ចិត្ត ខ្ញុំពិចារណាក្នុងចិត្តដេកគិតថា ខ្ញុំជៀសមិនផុតពីប្តីប្រពន្ធ អ៊ីចឹងខ្ញុំត្រូវតែដាក់ចិត្តនៅពេលហ្នឹង។ ដាក់ចិត្ត ហើយក្នុងចិត្តហ្នឹងចេះតែមានកូនចិត្តមួយចេះតែបន់ស្រន់ អ៊ីចឹងថាបើពិតជាគូព្រេងរបស់ខ្ញុំឲ្យចិត្តខ្ញុំចេះតែមានការទោរទន់អ៊ីចឹង ហ្នឹងខ្ញុំនិយាយចិត្តខ្ញុំជាការពិតតែម្តង។ ខ្ញុំថ្ងៃណាក៏ខ្ញុំបន់ស្រន់ព្រះដែរ បើថាពិតមែនជាបុរសហ្នឹងជាគូព្រេងរបស់ខ្ញុំសូមឲ្យចិត្តខ្ញុំទោរទន់មានចិត្តអាណិតគេ។ ពេលនោះហាក់បីដូចជាគូព្រេងរបស់ខ្ញុំរហូតមកដល់សព្វថ្ងៃចេះចិត្តខ្ញុំដូចថា វាចេះតែដាក់ចិត្តម្តងបន្តិចៗ មានការស្រឡាញ់ប្តីចាស។

**ស៖** ខ្ញុំសួរនៅក្នុងស្ថានភាពយប់ៗដែលលោកស្រីបានរួមដំណេកជាមួយប្តីលោកស្រី។ លោកស្រីបានប្រើពាក្យថា "ខ្លាចដែរពេលនោះ នៅយប់នោះ"។ បើលោកស្រីខ្លាច ម៉េចបានលោកស្រីមិនប្រកែក?

[១០:៤៥:៥៩]

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយ!

**លោកស្រី ជាំង ស្រីម៉ុំ៖**

**ឆ៖** ចាស ពេលនោះ ចិត្តវាអត់ទាន់មានចិត្តស្រឡាញ់ប្តីទេ ប៉ុន្តែក្នុងការខ្លាចៗដូចថាមានឈ្លបមួយផង មួយណានឹកឃើញថា ប្តីក៏លួងលោមថាយើងជៀសផុតមិនប្តីប្រពន្ធ យើងអ្វីមានតែប្តីប្រពន្ធទេមិនបាច់មានការលាក់លៀមអីទេ យើងជៀសផុតប្តីប្រពន្ធមិនរួចទេ។ អ៊ីចឹងខ្ញុំចេះតែស្តាប់គេផង ក្នុងការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្លាចមិនៗហ៊ានប្រកែក ព្រោះអីឈ្លបគេមកស្តាប់ដើម្បីថាយើងហ្នឹងមានការប្រកែក មិនចុះសម្រុង ព្រោះអីនៅស្រុកខ្ញុំហ្នឹងវាមានគ្រួសារខ្លះដែលរៀបការហើយ វាមិនចុះសម្រុងគ្នាហ្នឹង គេក៏ហៅយុវជននារីហ្នឹងមកណែនាំ ឬមួយគេដាក់ទណ្ឌកម្មឲ្យធ្វើនេះធ្វើនោះអីចឹង។ ដល់អីចឹងខ្ញុំមើលឃើញគំរូហ្នឹង ខ្ញុំៗមិនពេញចិត្តមែនពិត មិនៗពេញចិត្តមែន ប៉ុន្តែចេះតែដាក់ចិត្តអីចឹងទៅដោយសារខ្លាចគេ តែក្រោយៗមកក៏ខ្ញុំសម្រួលចិត្ត សម្របតាមប្តីអីចឹងទៅ ចេះតែរហូតមកដល់សព្វថ្ងៃនេះមក ចាស។

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**សៈ** ចាស អរគុណលោកស្រី។ ដើម្បីបញ្ជាក់នូវបញ្ហានេះ ខ្ញុំយោងដល់ចម្លើយរបស់លោកស្រីឆ្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត នៅត្រង់ចម្លើយលេខ៨ ដដែលនោះ។ លោកស្រីបាននិយាយថា ខ្ញុំដកស្រង់៖ “ខ្ញុំមិនចង់រួមដំណេកជាមួយប្តីរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំត្រូវបង្ខំចិត្ត។ ខ្ញុំដឹងថាប្តីរបស់ខ្ញុំមិនស្រឡាញ់ខ្ញុំទេ ព្រោះគាត់ស្រឡាញ់នារីផ្សេងទៀត”។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា ហេតុអ្វីបានជាលោកស្រីមានអារម្មណ៍ថាលោកស្រីត្រូវគេបង្ខំពេលនោះ?

[១០:៤៨:២៦]

**ឆៈ** ចាស ចំពោះៗខ្ញុំៗយល់ៗក្រៅពីចិត្តគេ ខ្ញុំដឹងថាពេលនោះប្តីរបស់ខ្ញុំក៏មាននារីផ្សេងដែរ ប៉ុន្តែមកពីប្រវត្តិរូបខុសគ្នា។ អីចឹងប្តីខ្ញុំការរៀបចំជាមួយខ្ញុំហ្នឹងក៏អត់មានព្រាងទុកពីមុនដែរ ដោយសារថ្ងៃដែលរៀបអាពាហ៍ពិពាហ៍ហ្នឹងដោយអត់ដឹងខ្លួនដល់ទាល់តែសោះ ពេលម៉ោងរៀបអាពាហ៍ពិពាហ៍ហើយ គេប្រាប់ថាគោដាច់ទៅវិញ។ អីចឹងគ្រាន់តែមកដល់កន្លែងគេរុញច្រានគាត់ចូលមកអង្គុយកៅអីហ្នឹង ហើយម្យ៉ាងខ្ញុំមិនដឹងថាគាត់មាននារីផ្សេង ផ្គូផ្គងជាមួយនារីផ្សេង ប៉ុន្តែដល់នារីផ្សេងហ្នឹងប្រវត្តិរូបហ្នឹងអត់ត្រូវគាត់។ អីចឹងហ្នឹងខ្ញុំក្នុងចិត្តខ្ញុំៗថាគាត់មិនសូវស្រឡាញ់ខ្ញុំទេ ម្យ៉ាងខ្ញុំក៏អត់មានស្រឡាញ់គាត់ដែរ។ ប៉ុន្តែចំពោះគាត់វិញគាត់ដឹងថា ការរៀបចំមិនជៀសវាងជាប្តីប្រពន្ធ ជៀសវាងមិនផុតទៅហើយ អីចឹងមិនស្រឡាញ់ៗក៏ត្រូវតែស្រឡាញ់ដែរ។ ប៉ុន្តែចំពោះខ្ញុំ ចេះតែយល់ឃើញថាគាត់មិនស្រឡាញ់ខ្ញុំ ព្រោះអីគាត់មាននារីផ្សេងអីចឹង ខ្ញុំក៏មានចិត្តមួយចេះតែពិចារណាថា ប្តីក៏មិនសូវស្រឡាញ់ខ្ញុំ ប៉ុន្តែតាមការពិត ខ្ញុំមើលតែខាងក្រៅទេ តែចិត្តគេៗអត់អីទេ ពិតមែនគេថាគេនារីផ្សេងគេមិនត្រូវជាគូព្រេងរបស់គេ គេចាត់ទុកថាខ្ញុំហ្នឹងជាគូព្រេង ម្ល៉ោះហើយពេលហ្នឹងគេដាក់ចិត្តហើយ។ ប៉ុន្តែចំពោះខ្ញុំវាអត់មានចិត្ត ប៉ុន្តែខ្ញុំខ្លាចៗព្រោះអីមានឈ្លបនៅខាងក្រោម។ អីចឹងបើសិនណាជាដូចពីមុននេះ ដូចសម័យឥឡូវនេះ គឺខ្ញុំវារើបម្រះហើយ មានការតវ៉ាហើយ តែពេលហ្នឹងខ្ញុំអត់មានការតវ៉ាចំពោះអង្គការទេ ព្រោះអីគេថា

យើងកូនអង្គការ អ៊ីចឹងយើងត្រូវតែស្តាប់អង្គការ អ្នកណាមួយប្រឆាំងគឺអ្នកហ្នឹងប្រឆាំងបដិវត្តន៍។ អ៊ីចឹងខ្ញុំត្រូវតែ មិនៗពេញចិត្តក៏ត្រូវខ្ញុំសម្រេចចិត្តទៅធ្វើដែរ ព្រោះអីសេចក្តីស្លាប់វាធំពេកនៅខាងមុខ ចាស។

[១០:៥០:៥២]

**ស៖** ចុះប្រសិនបើពេលនោះ លោកស្រីប្រកែក ឬប្រឆាំងនឹងការរៀបចំរបស់អង្គការ នឹងមានរឿងអ្វីកើតឡើង?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ហើយជាប្រភេទសំណួរឧបមាណវិធីដែលអង្គជំនុំជម្រះបានអនុវត្តតាំងពីយូរមកហើយ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់សំណួររបស់ខ្ញុំ ហើយនិងប្រគល់វេទិកាបន្តទៅដល់សហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរ<>អ្នកស្រី។

[១០:៥១:៥០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរបន្ថែមទៅលើប្រធានបទ<> ដែលបានពិភាក្សារួចមកហើយ។ ខ្ញុំចង់សួរអ្នកស្រីអំពីស្ថានភាពចិត្តរបស់អ្នកស្រីនៅរាត្រីដំបូង នៅពេលដែលគេបង្គាប់ឲ្យអ្នកស្រីរស់នៅជាមួយប្តីរបស់អ្នកស្រី។ <> តើអ្នកស្រីនិងប្តីរបស់អ្នកស្រីហ្នឹង <ភ័យខ្លាច>ថាវាមានផលប៉ះពាល់អ្វីទេ ប្រសិនបើអ្នកទាំងពីរហ្នឹងមិនរួមដំណេកជាមួយគ្នានោះ?

**លោកស្រី ផាំង ស្រីមុំ៖**

**ឆ៖** ចាស ការរៀប --

**លោក គង់ សំអុន៖**

លោកប្រធាន!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

កុំទាន់អាល់ឆ្លើយតបសាក្សី! សូមអញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិអំម្បាញ់មិញនេះ គឺអត់ខុសអីពីសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាតិកន្លងទៅទេ គឺជាប្រភេទសំណួរឧបមាណវិធីដែលផ្តល់ឱកាសឲ្យសាក្សីធ្វើការសន្និដ្ឋាន មិនមែនជាការពិតទេបាទ។ សូមជំទាស់ សូមអរគុណ។

**លោក ខេល លីសាក់៖**

លោកប្រធាន មិនមែនជាការសន្និដ្ឋានឬក៏អ្វីនោះទេ យើងត្រូវយល់ដឹងថាតើមានអ្វីកើតឡើងនៅរាត្រីនោះ តើជាការស្ម័គ្រចិត្ត ឬក៏ជាការមិនមានជម្រើស ឬក៏មានលក្ខណៈថាជាការបង្ខំឲ្យធ្វើបែបនេះ។

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរសាជាថ្មីម្តងទៀត។ ហើយបើភាសាខ្មែរមានន័យថា ជាប្រភេទឧបមាណវិធីដូចគ្នានឹងសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាជាតិដែរ។ លើកលែងតែលោកបញ្ជាក់ម្តងទៀត ហើយមានការបកប្រែច្បាស់លាស់ជាភាសាខ្មែរ ដែលបញ្ជាក់ថាមិនប្រើ មិនមានន័យថាឧបមាណវិធីដែលបំណងឲ្យសាក្សី -- សក្ខីកម្មរបស់សាក្សីផ្តល់ដោយស្មានៗនោះទេ។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១០:៥៤:០៦]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំ គឺនៅរាត្រីដែលគេស្នើឲ្យលោកស្រីស្នាក់នៅជាមួយប្តីរបស់អ្នកស្រី តើអ្នកស្រីដឹងថាអ្នកស្រីមានជម្រើស ឬក៏អត់ក្នុងការរួមដំណេកជាមួយប្តីរបស់អ្នកស្រី? ឬមួយក៏អ្នកស្រីមានអារម្មណ៍ថាវាមានផលវិបាកអ្វីកើតឡើង ប្រសិនបើអ្នកស្រីមិនធ្វើដូច្នេះ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស លោកប្រធាន គឺការដំបូង គឺខ្ញុំគ្មានជម្រើសផ្លូវណាមួយ។ គឺការសម្រេចចិត្តដោយ

ពិបាកអារម្មណ៍បំផុត។ គឺថាបើកាលណាយើងមិនសម្រេចចិត្តសម្រួមចិត្តទៅតាមការរៀបចំរបស់អង្គការទេ គឺយើងខ្វះសេចក្តីសុខ និង -- ខ្វះសេចក្តីសុខ។ អ៊ីចឹងការសម្រេចចិត្តនេះដោយពិបាកណាស់ ដោយទាំងទឹកភ្នែកដោយទាំងអារម្មណ៍ ដោយរើសផ្លូវណា ជ្រើសរើសផ្លូវណាក៏អត់ចេញដែរ រកច្រកអត់ចេញម្តង។ អ៊ីចឹងគឺសម្រេចចិត្តដោយវេទនាចិត្ត។

**ស៖** សូមអរគុណដែលបានបញ្ជាក់ឲ្យបានច្បាស់ ហើយខ្ញុំសូមទោស ដែលខ្ញុំសួរអ្នកស្រីអំពីបញ្ហាលំបាកបែបនេះ។ ឥឡូវនេះ ខ្ញុំចង់បន្តបន្ថិចទៀតទៅនឹងប្រធានបទផ្សេង។ អ្នកស្រីបាននិយាយថា អ្នកស្រី និងស្វាមី មានកូនបីនាក់។ តើមានកូនណាម្នាក់កើតនៅក្នុងរបបខ្មែរក្រហមដែរឬទេ?

[១០:៥៥:៥៨]

**ឆ៖** ចាស មានកូនទី១ កូនស្រីទី១ កើតនៅឆ្នាំ១៩៧៩ ក្នុងដើមឆ្នាំ១៩៧៩ មានកូនស្រីមួយ។

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិកជននៅស្រុកត្រាំកក់។ នៅក្នុងសំណួរចម្លើយទី១០ របស់អ្នកស្រី នៅក្នុងកិច្ចសម្ភាសន៍អ្នកស្រីបាននិយាយថា បានចូលរួមកិច្ចប្រជុំធំមួយនៅថ្នាក់ស្រុក ដែលនៅពេលនោះមេប្រធានស្រុកត្រាំកក់ បានឡើង<>មានយោបល់ ហើយអ្នកស្រីនិយាយថា ប្រធានស្រុកនោះបាននិយាយថា ខ្ញុំសូមដកស្រង់៖ “សាសនា និងព្រះពុទ្ធសាសនាមិនមានអត្ថិភាព មិនមានបន្តទៅមុខទៀតទេ”។ អ្នកស្រីចាំដែរឬទេ ថាតើការប្រជុំថ្នាក់ស្រុកធំហ្នឹង គេធ្វើឡើងនៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនចាំច្បាស់នូវកំណត់ហេតុការប្រជុំ ប៉ុន្តែខ្ញុំចងចាំថា ពេលប្រជុំនៅទីកន្លែងធំៗ ខ្ញុំអាចចាំ ប៉ុន្តែដល់ថ្ងៃខែឆ្នាំកំណត់ហេតុ វាអត់ចាំ លោកប្រធាន ចាស។

**ស៖** នៅពេលពិភាក្សាអំពីកិច្ចប្រជុំនេះ អ្នកស្រីបាននិយាយអំពីទីតាំង។ ទីតាំងទី១ គឺអង្គរកា គឺវត្តអង្គរកា និងមួយទៀតគឺ នៅក្នុងឃុំអង្គរលាយ នៅក្នុងភូមិអង្គរលាយ។ តើអ្នកស្រី<ចងចាំ>ទេ ថាតើគេធ្វើការប្រជុំនៅទីកន្លែងណា នៅពេលដែលប្រធានស្រុកបាននិយាយថា សាសនា និងវត្តអារាម <នឹង>មិនមានទៀតទេ គេធ្វើនៅកន្លែងណាមួយ?

**ឆ៖** ចាស ការប្រជុំនេះគេលើកឡើងតាមអង្គប្រជុំតូចៗ និងមីទ្ទីងធំៗ ដូចជាអង្គរកា អង្គរលាយ ហ្នឹងសុទ្ធតែមីទ្ទីងធំៗហើយ និងលើកឡើង -- បើកាលណាលើកឡើងថា សង្គមវាគ្មានសាសនា គ្មានអីកើតឡើងហ្នឹង វានៅ -- តាមការពិតទៅ វាគ្រប់អង្គប្រជុំ នៅអង្គប្រជុំតូចៗអីតាមភូមិ តាមឃុំអីក៏គេលើកឡើងអ៊ីចឹង តែចំពោះមីទ្ទិងធំៗ ក៏គេលើកឡើងនៅអ៊ីចឹងដែរ ចាស។

[១០:៥៩:២៥]

**ស៖** តើគេបិទវត្តអារាម ហើយគេហាមឃាត់ប្រជាជនមិនឲ្យគោរពសាសនាដែរឬទេ នៅពេលដែលប្រជុំហ្នឹងបានបញ្ចប់ទៅ?

**ឆ៖** ចាស គេថាគ្មានសាសនា ដូចថា គេប្រៀបធៀបដូចថា ព្រះអីចឹងយើងថ្វាយបង្គំទៅ ស៊ីម៉ង់ត៍តែដដែល។ ដល់ចំពោះលោកសង្ឃ ថ្វាយបង្គំមកសុទ្ធតែមនុស្សគ្នាឯង និងកូនចៅឯងតែដដែល។ អីចឹងគេអត់មានជំនឿទៅលើព្រះពុទ្ធសាសនា គេដូចថា គេណែនាំយើងកុំឲ្យមានជំនឿ ទាំងអស់ហ្នឹងសុទ្ធតែអបិយជំនឿមិនពិតប្រាកដ។

**ស៖** តើព្រះសង្ឃនៅក្នុងឃុំដែលអ្នកស្រីស្នាក់នៅក្នុងរបបខ្មែរក្រហមនោះ គេធ្វើអ្វីដែលចំពោះព្រះសង្ឃទាំងអស់នោះ?

**ឆ៖** ចាស កាលពីឆ្នាំ៧០, ៧១, ៧២, ៧៣ អីអីចឹង ព្រះសង្ឃនៅខ្លះៗអីចឹង ក្រោយមក គេឲ្យព្រះសង្ឃសឹកអស់ហើយ។ ហើយបើព្រះសង្ឃនៅអីអីចឹង គេឲ្យដឹកស្បៀងអាហារ ជិះកង់អីអីចឹង។ វេចបាយកញ្ចប់អី យកទៅជួយកងទ័ពនៅសមរភូមិខាងមុខ។ ព្រះសង្ឃហ្នឹងជិះកង់ អីចឹងទេដឹកបាយដឹកអីអីចឹងទៅ ដឹកស្បៀងអីចឹងទៅ ទៅសមរភូមិ ដើម្បីយកស្បៀងអាហារហ្នឹងទៅឲ្យកងទ័ព។ ក្រោយមកព្រះអង្គ ព្រះសង្ឃក៏គេឲ្យសឹកអស់ហើយ អត់មាននៅក្នុងវត្តទេ ឲ្យសឹកទាំងអស់។ គ្មានព្រះសង្ឃនៅក្នុងវត្តទេ។ ដល់ព្រះសង្ឃសឹកហើយអីចឹងទៅ ដូចប្អូនថ្លៃខ្ញុំហ្នឹងផ្ទាល់ ដល់សឹកមកគេសុទ្ធតែថា "ពួកអាចាញ់បោកព្រះស៊ីម៉ង់ត៍អី សុទ្ធតែពួកអាចាញ់បោកអីអីចឹង"។ ចាស ក្រោយមកសឹកមកចូលកងយុវជនអស់ហើយ ព្រះសង្ឃ។

[១១:០១:៥៣]

**ស៖** អ្នកស្រីបាននិយាយពីព្រឹកនេះថា "នៅពេលដែលប្រធានក្រុមរបស់អ្នកស្រីប្រាប់អ្នកស្រីថា អ្នកស្រីត្រូវរៀបការ អ្នកស្រីបានដើរទៅវត្ត ហើយបួងសួងដល់ព្រះ"។ តើអ្នកស្រីអាចប្រាប់បានទេថា នៅពេលនុ៎ងគេនៅបើកឲ្យមានវត្តអារាមដែរឬទេ? ហើយនៅពេលដែលអ្នកស្រីទៅបន់ស្រន់ព្រះហ្នឹង តើអ្នកស្រីអាចបន់ស្រន់ជាចំហ ហើយគេមើលឃើញបាន ឬមួយក៏អ្នកស្រីធ្វើដោយសម្ងាត់ទេ?

**ឆ៖** ចាស ពេលនោះ ដូចថាក្នុងវត្តនីមួយៗ អស់ព្រះសង្ឃហើយ គេឲ្យសឹកអស់ហើយ ប៉ុន្តែបន្សល់ទុកនូវព្រះពុទ្ធអីនៅក្នុងព្រះវិហារហ្នឹង ប៉ុន្តែព្រះពុទ្ធតូចតាចហ្នឹងបាត់បង់អស់ហើយ តែព្រះពុទ្ធក្នុងវិហារហ្នឹង វាមានព្រះពុទ្ធធំហ្នឹង វាមិនទាន់អាចរើចោលបាន។ អីចឹង ខ្ញុំលបទៅខាងយប់ហ្នឹង លប

ទៅហ្នឹង កុំឲ្យគេ -- មិនឲ្យគេដឹងទេ។ បើសិនណាជាឲ្យគេដឹង គេថាយើងនៅមានជំនឿមិនពិតហ្នឹង។ អ៊ីចឹង ខ្ញុំលបទៅទេ ដោយសារថាទៅបន់ព្រះហ្នឹង ទៅដោយការលួចទេ លួចទៅខាងយប់។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីប្រធានបទថ្មីមួយទៀត។ តើអ្នកស្រីអាចប្រាប់បានទេថា តើមានប្រជាជនវៀតណាម ឬក៏ប្រជាជនខ្មែរក្រោមនៅក្នុងឃុំរបស់អ្នកស្រីនៅក្នុងរបបខ្មែរក្រហមនោះដែរឬទេ? ហើយប្រសិនបើមានប្រជាជនវៀតណាម ឬក៏ខ្មែរក្រោមនោះ តើមានអ្វីកើតឡើងចំពោះពួកគាត់ទាំងអស់នោះ នៅក្នុងរបបខ្មែរក្រហម?

[១១:០៣:៤២]

**ឆ៖** ចាស តំបន់ខ្ញុំ ដូចថាអត់មានប្រជាជនវៀតណាមអី ដូចវានោះ វាអត់សូវស្គាល់ច្បាស់លាស់ផង។ ប៉ុន្តែគេចេះតែស្រាវជ្រាវ គេស្រាវជ្រាវដែរ គេស្រាវជ្រាវថា បងប្អូនវៀតណាមអ៊ីចឹង គេជួយបញ្ជូនទៅស្រុកទៅទេសអី។ ប៉ុន្តែអ្នកខ្លះមិនមែនវៀតណាមផងហ្នឹង ឮថាគេបញ្ជូនទៅស្រុកទៅទេស ដូចថារស់នៅស្រុកខ្មែរ ដូចថាពិបាកពេកក្នុងការគាបសង្កត់ អ៊ីចឹងចេះតែឆ្លើយទៅ ចេះតែឆ្លើយថា "អ្ហឺ! ខ្ញុំបងប្អូនវៀតណាមៗអី" ដល់អ៊ីចឹងគេចេះតែធ្វើ គេកត់ហើយ គេថា "អឺ! ថ្ងៃនេះគេបញ្ជូនទៅបញ្ជូនអី"។ ដល់ពេលការពិត ដល់ពេលគេបញ្ជូនទៅ មិនបញ្ជូនទៅវៀតណាម បញ្ជូនទៅភ្នំវិញ។ ដល់តែចេះឆ្ងល់ដែរ ដល់ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃហ្នឹងទៅ។ ប៉ុន្តែតាមការពិត វាគ្មានបងប្អូនវៀតណាមទេដែលរស់នៅស្រុកខ្ញុំនោះ ខ្ញុំ វាដូចថាអារម្មណ៍មួយ ចេះតែឆ្លើយថា អូ! វៀតណាមៗដែរទៅ ដើម្បីថាឲ្យគេបញ្ជូនទៅ រស់នៅវៀតណាមនោះ ក្រែងលោវាសុខស្រួលជាងនៅស្រុកខ្មែរ។ ដល់ពេលហើយ ពេលគេបញ្ជូនទៅទាំងកូនទាំងចៅទៅ ទៅបាត់ខ្លួនអស់នៅខ្លះ ខ្លះនៅសល់កូនដែរហ្នឹង។ នៅក្នុងកងយកទៅមិនអស់ ឥឡូវកំព្រាអ៊ីចឹងទៅ។

**ស៖** លោកស្រីសាក្សី <លោកស្រី>ទើបតែបានយោងទៅរក<>ចម្លើយ១៤នៃចម្លើយ<របស់លោកស្រីជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកស្រីបាននិយាយដូចតទៅនេះ៖> <"> នៅចុងឆ្នាំ១៩៧៦ មានការប្រកាសដោយមេឃុំ គេនឹងបញ្ជូនវៀតណាមត្រឡប់ទៅប្រទេសរបស់គេវិញ <">។ តើលោកស្រីចាំទេ ថាតើបានឮសេចក្តីប្រកាសរបស់មេឃុំហ្នឹង ឮនៅកន្លែងណា?

**ឆ៖** គេប្រកាសនៅក្នុងអង្គប្រជុំតែម្តង។ វាអត់មានឮថាប្រកាសទេ ប៉ុន្តែតាមកងតាមអីហ្នឹង ដូចថាប្រធានកងប្រធានអីហ្នឹង គេដើរសួរដើរអីតាមផ្ទះអ៊ីចឹងទៅ គេដើរកត់ប្រវត្តិរូបតាមផ្ទះអ៊ីចឹងទៅ គេថាអ្នកជាប់បងប្អូនវៀតណាមហ្នឹង គេនឹងបញ្ជូនទៅស្រុកវិញចាស។ ហើយដល់អ្នកមូលដ្ឋានហ្នឹង វា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

អត់មានទេ។ និយាយទៅភាគច្រើន បងប្អូន១៧នេះ ចាសដល់បងប្អូន១៧ហ្នឹង ខ្លះហ្នឹងចេះតែថា ខ្ញុំវៀតណាម ខ្ញុំអីអ៊ីចឹងទៅ។ បញ្ជូនទៅដល់ហើយដាក់ពេញៗឡានទៅ មិនទៅវៀតណាម បញ្ជូនទៅៗខាងភ្នំវិញ។ ដល់អ៊ីចឹង ក្រោយមកបានដឹងថា អូ្ហ! នេះវាអត់ពិតទេរឿងវៀតណាមនេះ ចេះតែឆ្លើយៗ។

[១១:០៧:១៥]

**សៈ** ខ្ញុំចង់សួរសំណួរទៅលោកស្រីមួយចំនួនទៀត អំពីរយៈកាលបន្ទាប់ពីគេរៀបការលោកស្រី ហើយបន្ទាប់ពីគេដកលោកស្រីពីការបង្រៀនកុមារបាទ។ ចម្លើយទី១១ នៅក្នុងសម្ភាសទៅសហាថៅក្រុមស៊ើបអង្កេតហ្នឹង គឺថាគេឱ្យលោកស្រីរស់នៅក្នុងសហករណ៍ ហើយរែកដី ហើយនិងប្រមូលអាចម៍គោធ្វើជី <ព្រមទាំងជីកប្រឡាយ>។ ហើយលោកស្រីបានរៀបរាប់ថា ជីវភាពរស់នៅគឺលំបាក ហើយលោកស្រីបានបញ្ជាក់ថា "នៅពេលដែលខ្ញុំមានផ្ទៃពោះ ខ្ញុំមានការលំបាកនៅពេលដែល<ខ្ញុំកាន់ចប និង>ជញ្ជូនដី នៅពេលដែលខ្ញុំចាញ់កូន គេបានទិតៀនខ្ញុំនៅក្នុងអង្គប្រជុំ<ទិតៀន> ហើយខ្ញុំត្រូវប្រឹងធ្វើការឱ្យខ្លាំង" ចប់សេចក្ដីដកស្រង់។ តើ<>លោកស្រីអាចប្រាប់តុលាការបានទេ ថាតើ<លោកស្រី> មានផ្ទៃពោះនៅពេលណានៅក្នុងសម័យនោះ? ថាប៉ុន្មានខែក្រោយពីមានផ្ទៃពោះ ដែលគេតម្រូវឱ្យរែកដីដដែលនោះ?

**ឆះ** ចាសខ្ញុំមានផ្ទៃពោះចាប់តាំងពីឆ្នាំ១៩៧៩។ មានផ្ទៃពោះពីរបីខែអ៊ីចឹង ខ្ញុំគេឱ្យ សហករណ៍គេឱ្យដើររើសអាចម៍គោ រែកដីដំបូកអ៊ីចឹងចាក់ស្រែចាក់អ៊ីចឹង ដើររើសអាចម៍គោហ្នឹង ដើរថ្លឹង មួយថ្ងៃបានប៉ុន្មានគីឡូ បើបានតិចតួចៗគេកសាងយើង។ ហើយម្យ៉ាងខ្ញុំហូបបាយ វាចាញ់កូនផង ហូបបាយអត់កើត ឈឺឡើងស្គមអ៊ីចឹង ហើយសាច់ឡើងស្លេក។ ទៅរើសអាចម៍គោអ៊ីចឹងទៅ ហើយទៅរែកដីអ៊ីចឹងទៅ បន្តិចៗគេប្រជុំអ៊ីចឹង គេកសាងយើងហើយ។ គេថាយើងនឹងធ្វើសតិអារម្មណ៍ ខ្ជិលធ្វើការងារ។ ដល់ទៅរែកតែដីដំបូកហ្នឹង ពង្រាយស្រែហ្នឹង រែកហ្នឹងក្ដួតផង ហើយដល់ពេលបាយហ្នឹង ហូបបាយអត់កើតទេ ទឹកសម្លក៏ហូបមិនបាន ខ្ញុំហូបតែជាមួយអំបិលៗស្រូបទឹកអំបិលៗស្រូបទឹកអ៊ីចឹងទៅ។ ដល់ពេលទៅធ្វើការអ៊ីចឹង ទៅធ្វើអត់កើតអ៊ីចឹង គេចេះតែថាយើងហ្នឹងពេលៗនេះប្រធានកងគេមកស្ដីយើងហើយ។ គេបន្តិចៗគេមកស្ដីអ៊ីចឹងទៅ គេថាយើងសតិអារម្មណ៍។ ពេលបើកអង្គប្រជុំថ្ងៃ ខែ -- ថ្ងៃ១០ៗ ថ្ងៃ២០ ថ្ងៃ៣០អ៊ីចឹងគេប្រជុំកងហើយ គេប្រជុំក្រុមទិតៀនគ្នា។ គេលើកគ្នាទិតៀនតែខ្ញុំហ្នឹង គេថាខ្ញុំហ្នឹងសតិ-អារម្មណ៍ ខ្ជិលធ្វើការទម្រន់អី។

[១១:១០:១៤]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ៊ីចឹងខ្ញុំមានអារម្មណ៍មួយពិបាកចិត្តណាស់ ពិបាកចិត្តណាខ្ញុំធ្វើការអត់កើត ហើយដល់ពេលហើយអាហារអត់គ្រប់គ្រាន់ទៀត។ ធ្វើការម៉ោងបួន ម៉ោងបួនទៀបភ្លឺខ្ញុំត្រូវឡើងធ្វើការ ម៉ោងមួយដណ្តប់ពីរដណ្តប់បានឈប់ ម៉ោងមួយចូលទៀត -- ចូលទៀត ម៉ោងប្រាំបានឈប់ៗ ម៉ោងប្រាំមួយចាប់ផ្តើមធ្វើការទៀតហើយ។ ម្ល៉ោះហើយធ្វើការដោយវេទនាអ៊ីចឹង ខ្ញុំលួនខ្ញុំក្រាបខ្ញុំលូនអ៊ីចឹង តែនេះគេកសាងអីខ្លះអីអ៊ីចឹង។ ដល់ពេលពិបាកចិត្តពេកខ្ញុំនិយាយជាការពិតតែម្តង គេថាក្រសាំងហ្នឹងក្រសាំងពុល។ ក្រសាំងៗពុល ខ្ញុំនឹកឃើញមិនដឹងរកវិធីអី អ៊ីចឹងខ្ញុំពុះក្រសាំងហ្នឹង ហូបអស់ម៉េចអីក៏ម៉េចចុះ ដល់ក្រសាំងហ្នឹងអត់ពុលទៀត។ ចេះតែធ្វើការ ហើយជើងហើមប៉ុនៗណាណីជើង ហើយប្តីក៏អត់នៅដែរ ប្តីនៅឃុំផ្សេង ប្តីនៅ ខ្ញុំនៅឃុំញ៉ែងញ៉ង ប្តីនៅឃុំលាយបូរ។ ថ្ងៃអាទិត្យ -- ១០ថ្ងៃជួបគ្នាម្តងៗ ហើយជើងហើមសឹងនឹងចេញទឹកអស់ហើយ ប៉ុន្តែនៅតែធ្វើការអ៊ីចឹង។ គេថាអាហ្នឹងហើយយើងស្រណុកពេក ធ្វើការទម្រន់ ម្ល៉ោះហើយដើរចុះដើរឡើងៗ ជើងវាមិនសូវហើមទេ ដល់តែជើងវាស្រណុកពេកអ៊ីចឹងវាហើមហើយ។ គេថាអ៊ីចឹង ម្ល៉ោះហើយទៅធ្វើការទាំងខ្លាចទាំងភ័យអ៊ីចឹងទៅចេះតែធ្វើការ។

[១១:១១:៥១]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមបំភ្លឺពីអ្វី និយាយអំពីកាលបរិច្ឆេទ ថាតើអាចជាបញ្ហាបកប្រែដែរឬទេ។ ខាងដើមនោះលោកស្រីបានបញ្ជាក់ថាបានឱ្យកំណើតទៅកូនស្រី គឺដើមឆ្នាំ១៩៧៩។ អ៊ីចឹងគឺកូនទី១ កើតនៅដើមឆ្នាំ១៩៧៩ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ចាស កូនទី១ កើតនៅដើមឆ្នាំមួយពាន់ប្រាំបួន -- ចាប់កំណើតដើមឆ្នាំ១៩៧៩។

**ស៖** ហើយតាមដែលខ្ញុំយល់តើត្រឹមត្រូវដែរទេ លោកស្រីបានមានផ្ទៃពោះយ៉ាងហោចណាស់ចាប់ពីឆ្នាំ១៩៧៨មក។ តើអ៊ីចឹងឬយ៉ាងណា?

**ឆ៖** ចាស ហ្នឹងចាសចាប់កំណើតពេលហ្នឹងហើយ ដល់តែពេលកើតឆ្នាំ៧៩ ខ្ញុំកើតបាន២០ថ្ងៃបីកូនរត់។ កើតកូនបាន១៨ថ្ងៃ ៗខ្ញុំបីកូនរត់។

**ស៖** អ៊ីចឹងខ្ញុំត្រឡប់ទៅប្រធានបទមួយផ្សេងទៀត នៅក្នុងចម្លើយទី១២ នៅក្នុងបទសម្ភាសន៍លោកស្រីទៅការិយាល័យចៅក្រមស៊ើបអង្កេត ហើយលោកស្រីបានរៀបរាប់ពីល្ងាចមួយនៅឆ្នាំ១៩៧៨ ដែលបានឃើញគេចងមនុស្សប្រហែលជា១០នាក់ ហើយគេបណ្តើរចេញទៅ។ បន្ទាប់មកលោកស្រីបានបញ្ជាក់ថា សូមដកស្រង់៖ “ភាគច្រើនអ្នកដែលគេចាប់ទៅនោះ គឺជាប៉ូលិស ជាទាហាន គ្រូបង្រៀននៅក្នុងជំនាន់មុន ហើយនិងនិស្សិត”។ អ្វីដែលខ្ញុំចង់បំភ្លឺនោះគឺថា <ពេលដែល>លោកស្រីនិយាយថា ភាគ

ច្រើនអ្នកដែលគេចាប់នោះគឺប៉ូលិស ទាហាន គ្រូបង្រៀន។ តើ<និយាយចំពោះតែ>ក្នុងចំណោមអ្នកទាំង១០ ដែលលោកស្រីឃើញយប់ហ្នឹង ឬក៏លោកស្រីនិយាយជាទូទៅអំពីការចាប់ខ្លួននៅក្នុងសម័យខ្មែរក្រហម?

[១១:១៤:២៤]

**ឆ៖** ចាស ជាការពិតណាស់នៅឆ្នាំដែលគេចាប់មនុស្សចងហ្នឹង ពេលម៉ោងប្រាំមួយយប់ ខ្ញុំផ្ទះខ្ញុំនៅក្បែរថ្នល់ ខ្ញុំឮស្នូរព្រឹបៗដើរ មើលទៅខែភ្លឺ ដៃសុទ្ធតែទៅក្រោយទាំងអស់ ហើយគេដោតខ្សែគោហ្នឹងដើរបណ្ដោយថ្នល់ទៅលិចទៅ។ ចាស ដើរបណ្ដោយថ្នល់ខ្ញុំក៏មានការរន្ធត់ ហើយដូចថាអ្នកបងប្អូនអីឃើញអ៊ីចឹងគេមានការរន្ធត់ គេអត់សូវហ៊ានចេញមើលទេ នាំគ្នាដេកញាក់ញ័រភ័យសព្វរូបទាំងអស់។ តែដល់ពេលក្រោយមក ខ្ញុំដឹងថាអ្នកហ្នឹងគេសួរថាពីមុនធ្វើអី? ចង់ ហើយដល់ហើយគ្នាអត់ដឹងចង់គ្រាន់តែគេដកក្រែងដកស្រង់ប្រវត្តិរូបទៅ អ្នកពាក់ព័ន្ធធ្វើការហ្នឹងក្រែងគេដើម្បីជួយធ្វើការងារគេ អ្នកខ្លះគ្នាថាគ្រូបង្រៀន អ្នកខ្លះថាប៉ូលិស អ្នកខ្លះនិស្សិតនៅរៀនអីអ៊ីចឹងទៅ គ្នាចេះតែឆ្លើយ ខ្លះណាសួរពីមុនពាក់ស័ក្តិប៉ុន្មានៗចេះតែឆ្លើយប្រាប់គេត្រង់ គ្នាស្មានតែគេស្រាវជ្រាវអស់ហ្នឹងដើម្បីរកអ្នកចេះដឹង ដល់ពេលហើយទីបំផុតអ្នកអស់ហ្នឹងគេចាប់យកទាំងអស់ ឈ្មោះទាំងអម្បាលម៉ានហ្នឹងគេចេះតែកត់ឈ្មោះនៅក្នុងសៀវភៅប្រវត្តិរូបគេហើយ ដល់តែពេលយប់ហ្នឹងគេចេះតែហៅកោះឈ្មោះហ្នឹងទៅ ឲ្យនីរសារហៅមកប្រមូលទៅគេបណ្ដើរទាំងខ្សែៗអ៊ីចឹងទៅ។ ហើយប្រជាជនមូលដ្ឋានអ៊ីចឹងដែរ បើមានការពាក់ព័ន្ធអីមានបងប្អូនធ្វើធំធ្វើអីកាលជំនាន់ហ្នឹង ក៏គេស្រាវជ្រាវដែរ ថា "អូ្ហ! ខ្សែបងប្អូនវាសុទ្ធតែអ្នកធំ"។ អ៊ីចឹងគេៗត្រូវចាប់យកទៅសម្លាប់ចោលនៅពេលហ្នឹងដែរ។ គេពាក្យមួយគេនិយាយច្រើនថា បើសម្លាប់ហើយរំលើងអស់ទាំងឫសទាំងគល់អីទាំងអស់ គេពាក្យគេច្រើនតែអ៊ីចឹង។

[១១:១៦:៤៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចង់សួរសំណួរដោយឲ្យសាក្សីមើលឯកសារពីរដែលសុំអនុញ្ញាត។ ឯកសារទី១ គឺឯកសារ E3/2450<>, ខ្មែរ 00270746, អង់គ្លេស 00322161, បារាំង ERN 00623747។ ឯកសារនេះគឺជា<>សំបុត្រនិយាយអំពី មកពីឃុំនាង និយាយពីការចាប់ខ្លួនមន្ត្រីអតីតមន្ត្រីលន់នល់ ឯកសារទី២ គឺ <E3/2432> ដែលជាបញ្ជី<>រាយនាម<>ទាហាន លន់ នល់<១១នាក់ មកពីឃុំរបស់សាក្សីនេះ> ចុះថ្ងៃទី១<៨> មេសា ឆ្នាំ១៩៧៧ ហើយខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញឯកសារនេះទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សាក្សី ថាតើសាក្សីអាចស្គាល់អ្នកទាំងអស់នេះណាខ្លះ? សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសយកទៅជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:១៨:២៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សីបានទទួលឯកសារពីរ។ ឯកសារទី១ គឺ E3/2450 ដែលមានឈ្មោះអតីតទាហានលន់ នល់<បីនាក់ ដែលគេបានចាប់ខ្លួនមកពីឃុំរបស់អ្នកស្រី> ពីរគឺថា<>ទី១ គឺជាបាទស័ក្តិ២ ហើយនិងស័ក្តិ៣បាទ<។ យោងទៅតាមការសម្រេចរបស់បក្ស សំបុត្រនោះសរសេរថា “ទាក់ទងទៅនឹងជម្លោះ> <>គឺថាមិនមានអ្វីកើតឡើងទេ ប៉ុន្តែគេចាប់ខ្លួនដោយសារអ្នកទាំងអស់ហ្នឹងមានស័ក្តិធំ” ចប់សេចក្តីដកស្រង់។ នៅក្នុងឯកសារ<ទី>២<>គឺជាបញ្ជីរាយនាមមន្ត្រីលន់ នល់<១១នាក់ មកពីឃុំរបស់លោកស្រី> គឺមានវរសេនីយ៍ស័ក្តិ៤ <មានពីរនាក់> ហើយនិងស័ក្តិ<២>ហ្នឹង<>ចំនួន<ប្រាំនាក់ និងស័ក្តិ១ ចំនួនបួននាក់>។ អ៊ីចឹងសូមឲ្យលោកស្រីមើលឈ្មោះបញ្ជីដែលមកពីឃុំញ៉ែងញ៉ង់ហ្នឹង ថាតើលោកស្រីស្គាល់នរណាខ្លះនៅក្នុងបញ្ជីហ្នឹង?

**លោកស្រី ជាំង ស្រីម៉ុំ៖**

**ឆ៖** ចាស ឈ្មោះអ្នកពាក់សក្តិនៅក្នុងឃុំញ៉ែងញ៉ង់ប៉ុន្មាននាក់ ខ្ញុំដូចជាអត់ស្គាល់ គ្រាន់តែឮឈ្មោះខ្លះៗ ប៉ុន្តែអត់ដែរស្គាល់ចាស។

**ស៖** សំណួរចុងក្រោយមួយរបស់ខ្ញុំ លោកស្រីបញ្ជាក់ថាមានគេប្រើងប្រែងស្រាវជ្រាវកំណាត់មនុស្សមុខសញ្ញាដោយប្រវត្តិរូប<នៅក្នុងឃុំរបស់លោកស្រី>ថាតើ<លោកស្រីដឹងថា>ខ្មែរក្រហមបានធ្វើអ្វីខ្លះដើម្បីស្វែងរកអ្នកណាខ្លះនៅឃុំរបស់លោកស្រី ដើម្បីរកឲ្យឃើញថាជាអតីតទាហាន ឬក៏មន្ត្រីលន់ នល់ នោះ?

**ឆ៖** ចាស ដែលឈ្មោះអតីតដែលទាហាន លន់ នល់ ដែល ប៉ុល ពត យកទៅសម្លាប់ហ្នឹង? ខ្ញុំស្តាប់អត់បាន អំមិញអារម្មណ៍អត់មូល។ ចាស សូមម្តងទៀតចាស។

**ស៖** ខ្ញុំសួរលោកស្រីថាតើលោកស្រីបានដឹងថា តើខ្មែរក្រហមបានធ្វើអ្វីខ្លះដើម្បីកំណាត់ ដើម្បី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រាវជ្រាវរកថាអ្នកណាជាអតីតមន្ត្រី ឬក៏ទាហាន លន់ នល់ ពីរបបចាស់នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១១:២១:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានជំទាស់ពីដើមហើយ ចំពោះសាក្សីផ្សេងដែលប្រើពាក្យថា "ខ្មែរក្រហម" ហើយខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះថា តើឲ្យខ្ញុំលើកការជំទាស់ជាបន្តដែរឬអត់? នៅពេលដែលខ្ញុំបានជំទាស់នោះ ខ្ញុំសូមជំទាស់ចំពោះការប្រើពាក្យថា "ខ្មែរក្រហម" នោះ។ ហើយជាពិសេសការប្រើឯកសារដូចគ្នានោះដែរ ដូចដែលខ្ញុំបញ្ជាក់ថាគឺមិនមានឯកសារដើមនោះទេ ហើយយើងក៏មិនដឹងថាតើឯកសារនេះមកពីក្រាំងតាចាន់ដោយរបៀបណាដែរ។ ហើយខ្ញុំនឹងអាចជំទាស់ ប៉ុន្តែខ្ញុំក្រែងអាចថានឹងពន្យឺតពេលរបស់សហព្រះរាជអាជ្ញា។ អ៊ីចឹងខ្ញុំជម្រាបសួរអង្គជំនុំជម្រះថា តើខ្ញុំត្រូវជំទាស់ការសួរសំណួរបែបនេះជានិច្ចជាកាលពេលដែលខ្ញុំឮ ឬដូចម្ដេច? ពីព្រោះកាលប្រើពាក្យនេះ ខ្ញុំបានជំទាស់ហើយពីមុនហើយលោកប្រធាន។

[១១:២១:៥៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣១:១៧]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ម៉ោងសម្រាកហើយ ហើយពេលវេលាសម្រាប់ភាគីខាងសហព្រះរាជអាជ្ញារួមជាមួយនឹងមេធាវីនាំមុខតំណាងបណ្ដឹងរដ្ឋប្បវេណីនៅសល់១៥នាទីទៀតអម្បាញ់មិញ។ ប៉ុន្តែឥឡូវដោយសារមានបញ្ហាជំទាស់ តវ៉ានឹងការតាំងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញា ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី -- ចំពោះក្សីរូបនេះ រួមទាំងឯកសារថតចម្លងផង ដែលបញ្ហានេះ អង្គជំនុំជម្រះពិភាក្សាទៅឃើញថា មានបញ្ហាស្មុគស្មាញផង ដើម្បីផ្ទួងជាមួយនឹងសេចក្ដីសម្រេចមុនៗដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ដើម្បីជៀសវាងមានការខុសគ្នារវាងការសម្រេចសេចក្ដីលើបញ្ហាតែមួយ។

អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅ

រសៀលនេះ ចាប់ផ្ដើមពីម៉ោងមួយនិងសាមសិបនាទី។ ហើយសូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១១:៣២:៣១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណើ<ខ្លី>មួយជូនអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានលើកឡើងថា <យើងនៅសល់ពេលតែ>១៥នាទី ក៏ប៉ុន្ដែខាងយើង យើងចង់បាន៣០នាទី ពីព្រោះថាពីព្រឹកមិញ<> យើងបានពិភាក្សាគ្នាអស់១៥នាទី<ទៅហើយ> អំពីរឿងសវនាការអសាធារណៈចំពោះសាក្សីនេះ។ ដូច្នេះ យើងបានបាត់បង់<ពេល>ប្រហែល<៣០នាទី ទៅហើយ> ដោយសារតែ<ពិភាក្សាលើ>កាលវិភាគថ្មី<>សម្រាប់ការសវនាការ<នៅ>ព្រឹក<មិញ>នេះ។ ដូច្នេះខ្ញុំ<សុំពេល>ប្រហែលជា៣០នាទី គឺប្រហែលជា <ឬ>យ៉ាងហោចណាស់ក៏២០ទៅ២៥នាទីដែរសម្រាប់<ការសួរដេញដោលនៅ>រសៀលនេះ។ សូមអង្គជំនុំជម្រះសម្រេចលើសំណើនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយពិតជាដូច្នោះមែន ប៉ុន្ដែអង្គជំនុំជម្រះក៏បានថ្លឹងថ្លែងផងដែរ រវាងថាតើគប្បីតម្រូវឲ្យសាក្សីរូបនេះ អញ្ជើញមកនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយទៀតម្ដងទៀតនោះដែរឬទេ។ ឧទាហរណ៍ថា ត្រូវចំណាយពេលត្រឹមតែ១៥នាទី ឬ២០នាទីនោះ ឲ្យគាត់ត្រូវចំណាយពេលវេលាមកម្ដង។ នោះក៏ជាបញ្ហាមួយដែរ។

បញ្ហាទី២ គឺរឿងយើងធ្វើកន្លងមកនេះ វាអាចមានការលើសខ្វះបន្ដិចបន្ដួច នៅលើពេលវេលាដោយការគ្រប់គ្រងពេលវេលា នៅក្នុងការប្រព្រឹត្តទៅនៃសវនាការ តាមដែលបទពិសោធន៍របស់ខ្ញុំបានធ្វើប្រធានសវនាការនៅអង្គជំនុំជម្រះនេះ៧ឆ្នាំមកហើយនោះ ដូចជាយើងមិនបានកំណត់ច្បាស់លាស់កម្រិតដូចពេលម៉ោងប្រដាល់ ឬក៏ពេលម៉ោងសម្រាប់បាល់ទាត់ ដែលថា៩០នាទី គឺ៩០នាទីគត់ ឬក៏រត់ប្រណាំងល្បឿន កម្រិតត្រឹម១០០ម៉ែត្រហ្នឹងប៉ុន្មាននាទី ប៉ុន្មានវិនាទីនោះ ដូចជាយើងមិនមានអាហ្នឹងទេ។ អ៊ីចឹង វាអាស្រ័យលើហេតុផលលក្ខណៈសមស្របដែលយើងលទ្ធភាពថា ផ្ដល់ឲ្យ។ គប្បីភាគីគប្បីប្រឹងប្រែងដើម្បីផ្ដង់នៅក្នុងការសម្រិតសម្រាំងសំណួរដើម្បីសួរឲ្យចំដែរ ដើម្បីមានប្រយោជន៍ថាតើអង្គជំនុំជម្រះហ្នឹងផ្ដល់ពេលវេលាឲ្យដែរ ឬក៏យ៉ាងណា នេះគឺជាទិដ្ឋភាពជាក់ស្ដែង។ អង្គជំនុំជម្រះនឹងពិចារណានៅពេលរសៀលនេះ ដើម្បីសម្រេចថាតើឲ្យបន្ដ ឬក៏មិនបន្ដ? ពីព្រោះសហព្រះរាជអាជ្ញា គាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានប្រើពេលវេលាយូរផងដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាកនៅបន្ទប់រង់ចាំ ឬកន្លែងណាមួយសមស្រប ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ -- ភារៈជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីបង្ហាញអំពីសេចក្តីសម្រេចឆ្លើយតបទៅនឹងសេចក្តីជំទាស់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ ចំពោះការតាំងសំណួរ និងការដាក់ឯកសារនៅចំពោះមុខសាក្សីរបស់សហព្រះរាជអាជ្ញាកាលពីព្រឹកមិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលយើងឈប់សម្រាក មេធាវីការពារក្តី នួន ជា បានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារ<ថតចម្លង>សម្រាប់ការសួរសំណួរ ហើយគាត់បានស្នើសុំឲ្យមានការណែនាំទាក់ទងទៅនឹងការជំទាស់ទៅពេលអនាគតទៅលើឯកសារបែបនេះ។ ហើយនិងការជំទាស់

ទាក់ទងទៅនឹងការប្រើប្រាស់ពាក្យថា "ខ្មែរក្រហម"។ នៅពេលដែលយើងនិយាយពីការជំទាស់ គឺថា មេធាវីការពារក្តីបានលើកឡើងពីការជំទាស់កន្លងមក ហើយការជំទាស់នេះត្រូវបានសម្រេចកាលពីមុន រួចមកហើយ។ ចំពោះគោលការណ៍ណែនាំជាទូទៅវិញ អង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់មេធាវី ដែលស្នើសុំឲ្យបែបនេះ ប៉ុន្តែមានការលំបាកនៅក្នុងការចេញវិធាន ចេញការសម្រេចទៅលើបញ្ហានេះ។ ដូច្នេះហើយ មេធាវីការពារក្តីមិនចាំបាច់ត្រូវជំទាស់ទៅលើអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចទៅហើយ។ មេធាវីការពារក្តីគ្រាន់តែធ្វើការរៀបចំឡើងវិញទៅលើការជំទាស់ ប្រសិនបើអាចធ្វើទៅបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ សូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមបន្តសំណួរ<ចុងក្រោយរបស់ខ្ញុំ មុនពេលខ្ញុំប្រគល់វេទិកាទៅឲ្យភាគដើមបណ្តឹងរដ្ឋប្បវេណី>។ អ្នកស្រីបាននិយាយរួចហើយអំពីដំណើរការដែលពួកខ្មែរក្រហមព្យាយាម ដើម្បីកំណត់អំពីជនជាតិវៀតណាម។ សំណួររបស់ខ្ញុំចង់សួរថា តើអ្នកស្រីដឹងដែរឬទេថា ខ្មែរក្រហមធ្វើយ៉ាងដូចម្តេចនៅក្នុងឃុំរបស់អ្នកស្រី ដើម្បីស្វែងរកឲ្យឃើញថា អ្នកណាជាទាហាន អ្នកណាជាអ្នករដ្ឋការរបស់របប លន់ នល់ ជាដើមនោះ?

[១៣:៣៦:២៨]

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាសអរគុណ។ ចំពោះការស្រាវជ្រាវរកអ្នកពាក់ព័ន្ធដូចជា ទាហាន ដូចជានិស្សិត ការស្រាវជ្រាវរបស់គេ គេតែងតែចុះសាកសួរនៅតាមកង ឬមួយនឹងការឈប់សម្រាកពីការងារចាស។ ឈប់សម្រាកពីការងារអ៊ីចឹង គេតែងតែសួរប្រវត្តិរូប អតីតធ្លាប់ធ្វើអ្វីខ្លះ អ្នកខ្លះគ្នាក៏ឆ្លើយតាមត្រង់ទៅថា ពាក់ស័ក្តិ៤ ឬមួយធ្លាប់ធ្វើគ្រូបង្រៀន ឬមួយធ្វើទាហាន តាមចំណោះអ៊ីចឹងទៅ។ ការដឹងរបស់គេ គេៗចុះសួរតាមពេលហ្នឹង ពេលការសម្រាកពីការងារ ឬមួយតាមការសម្រាករៀងៗខ្លួនហ្នឹង គេចុះសាកសួរនៅតាមផ្ទះអ៊ីចឹង លោកប្រធាន ចាស។

**លោក ឌេល លីសាក់៖**

សូមអរគុណអ្នកស្រី ដែលបានចំណាយពេលមកទីនេះ។ ហើយក្នុងនាមព្រះរាជអាជ្ញា គឺយើងខ្ញុំមិនមានសំណួរអ្វីបន្ថែម ដើម្បីសាកសួរអ្នកស្រីទេ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៣:៣៨:១៥]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យលោកស្រីមេធាវី ជេត វណ្ណលី សួរសំណួរទៅសាក្សី ជាំង ស្រីមុំ នេះ ហើយនិងអាចបន្តដោយលោកស្រី លោកស្រី ម៉ារី ហ្គីរ៉ូដ៍។ សូមអរគុណលោកប្រធាន សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ជម្រាបសួរលោកស្រី ជាំង ស្រីមុំ! ពីព្រឹកមិញមកដល់ពេលនេះ លោកស្រីបានឆ្លើយនូវចំណុចមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យលោកស្រីមេត្តាជួយបំភ្លឺនូវមួយចំណុចបន្ថែមទៀត ដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ។ ដោយពេលវេលារបស់យើងខ្ញុំមានកំណត់ ខ្ញុំសូមចាប់ផ្ដើមសំណួរតែម្ដង។

[១៣:៣៩:០៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកស្រី ជាំង ស្រីមុំ ពីព្រឹកមិញ លោកស្រីបានបញ្ជាក់ថា សុំទោស -- តាមចម្លើយលេខ៥ របស់លោកស្រី នៅមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបានបញ្ជាក់ថា៖ “ឃឹម ធៀម ជាប្រធានកង ហើយត្រូវបានគេដកចេញពីតំណែង ដោយសារបានធ្វើខុសសីលធម៌”។ តើបញ្ហាខុសសីល

ធម៌ហ្នឹងយ៉ាងម៉េចដែរលោកស្រីចាស?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាសអរគុណ។ លោក ឈឹម ធៀម ជាប្រធានកង តែប្រធានកងហ្នឹងគឺមិនមែនកងហ្នឹងក្តាប់ទាំងឃុំទេ ប្រធានកងហ្នឹងវាមានបីផែន ដូចថាបីភូមិអ៊ីចឹង គេឲ្យមើលខុសត្រូវក្នុងៗក្នុងបីភូមិហ្នឹងមួយផែនហ្នឹង ហើយការខុសសីលធម៌ហ្នឹងគឺដូចថាប្ដីរបស់គេ ដូចថាយកតែប្ដី ៗហ្នឹងយកទៅសម្លាប់ទៅ ដល់ហើយនៅតែប្រពន្ធហ្នឹងនៅធ្វើសហករណ៍ហ្នឹងពលកម្មហ្នឹងជាមួយគ្នាអ៊ីចឹង គាត់មើលការខុសត្រូវអ៊ីចឹង។ ដល់ពេលហើយយប់ឡើងវាមានការប៉ះពាល់ដល់ប្រពន្ធគេ ដល់ហើយអ្នកប្រធានក្រុមប្រធានអីដូចគ្នាហ្នឹង គេតាមដានទៅ វាឃើញនឹងភ្នែកទៅ គេរាយការណ៍ទៅដក ឈឹម ធៀម ហ្នឹងចេញពីប្រធានកងទៅ។ ដល់រួចគេយក ឈឹម ធៀម ហ្នឹងយកទៅដាក់ទណ្ឌកម្ម ទៅស្រោចដូងដកស្មៅអីនៅកន្លែងមន្ទីរបក្សអ៊ីចឹងទៅ។ រួចមកហើយ ឈឹម ធៀម ក៏អស់សិទ្ធិជាអ្នកដឹកនាំប្រធានកង រួចគាត់មកដូចថាមានទោសអ៊ីចឹង គេដាក់ទណ្ឌកម្មអ៊ីចឹង គាត់ហ្នឹងក៏ក្លាយជាមនុស្សគ មនុស្សអីពេលហ្នឹង គេសួរចម្លើយទៅ ក៏គាត់អត់មាននិយាយអីទាំងអស់ ទៅជាមនុស្សគទៅ។ អ៊ីចឹងគាត់ជាមនុស្សគហ្នឹង ប៉ុន្តែគាត់នៅក្នុងការជាប់ទោស នៅដកស្មៅនៅស្រោចដំណាំស្រោចអីអ៊ីចឹងទៅ អ៊ីចឹងគាត់អស់សិទ្ធិពីអ្នកដឹកនាំចាស។

[១៣:៤១:៤១]

**ស៖** សូមអរគុណលោកស្រី។ ហើយបញ្ហាខុសសីលធម៌ហ្នឹងតែងមានញឹកញាប់ទេនៅក្នុងទីកន្លែងដែលលោកស្រីរស់នៅ?

**ឆ៖** ចាស អត់ៗសូវមានការញឹកញាប់ទេ ប៉ុន្តែតាមខ្ញុំដឹងច្បាស់មានពីរនាក់។ មានពីរនាក់ដូចជា ឈឹម ធៀម ហ្នឹងមួយ បន្ទាប់មកប្រធានក្រុមរងមួយ ចាសវាមានពីរនាក់។ ដល់មួយ ឈឹម ធៀម មួយ អី នឹម ទេ! ឈ្មោះ នឹម។ ឈ្មោះ នឹម ក៏គាត់ប្រព្រឹត្តខុសសីលធម៌ជាមួយប្រពន្ធគេដែរ ដល់ក្រោយមក តែប្រជាពលរដ្ឋអត់ដឹងទេ ដឹងតែអ្នកប្រធានកងប្រធានក្រុមដូចគ្នាហ្នឹង គេអាចតាមដានគ្នាគេដឹង។ អ៊ីចឹងគេរាយការណ៍ ម្នាក់ហ្នឹងក៏ត្រូវមានបញ្ហាដាក់ទោសទណ្ឌកម្មដែរ។

**ស៖** សូមអរគុណលោកស្រី។ ពីព្រឹកមិញលោកស្រីបានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះ ក៏ដូចជាចំពោះសហព្រះរាជអាជ្ញាថាលោកស្រីធ្លាប់បានឃើញកំណត់ហេតុនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលស្ដីអំពីការសម្លាប់ឪពុកលោកស្រី។ តើលោកស្រីឃើញនៅពេលណា? នៅឆ្នាំណាអាហ្នឹង?

**ឆ៖** ចាស លោកប្រធានខ្ញុំឃើញពេលនៅថ្មីៗនេះ មើលឆ្នាំមួយពាន់ -- ឆ្នាំ២០១៣ ចាសឃើញឆ្នាំ២០១៣។ ពេលនោះខ្ញុំទៅធ្វើបុណ្យ ៗហើយខ្ញុំចេះឧទ្ទិស បើសិនណាជាឪពុកខ្ញុំស្លាប់នៅកន្លែងហ្នឹងមែន សូមឱ្យខ្ញុំឃើញឯកសារប្រវត្តិរូបរបស់គាត់ កំណត់ហេតុរបស់គាត់។ ខ្ញុំចេះតែឧទ្ទិសបួងសួងអ៊ីចឹងខ្ញុំព្យាយាមមើល ខ្ញុំឃើញឯកសារមួយមានសៀវភៅបកប្រែជាភាសាអង់គ្លេសផង បកប្រែជាអក្សរខ្មែរហ្នឹងផង។ ដល់តែព្យាយាមទៅ ប៉ុងចុះប៉ុងឡើងខ្ញុំឃើញ ឃើញឪពុកឈ្មោះ ជាំង យ័ន្ត ប្រពន្ធ សៅ នន ខ្ញុំឃើញក៏ហៅបងប្អូនមកមើល។ អ៊ីចឹងខ្ញុំដឹងច្បាស់ថា កំណត់ហេតុនៅកន្លែងហ្នឹង ដឹងច្បាស់ថាឪពុកខ្ញុំគេសម្លាប់ចោលនៅក្រាំងតាចាន់ហ្នឹងហើយ ព្រោះអីខ្ញុំឃើញកំណត់ហេតុ ចាសឃើញកំណត់ហេតុច្បាស់ណាស់ តែឥឡូវហ្នឹងសៀវភៅហ្នឹងនៅតម្កល់ទុកនៅក្រាំងតាចាន់ទាល់ឥឡូវ។ ខ្ញុំចេះនិយាយប្រាប់បងប្អូនថា បើមានបងប្អូនណាស្លាប់នៅកន្លែងក្រាំងតាចាន់ហ្នឹង សូមឱ្យទៅព្យាយាមមើលកំណត់ហេតុទៅ ស្លាប់ថ្ងៃទីប៉ុន្មាន វេលាម៉ោងប៉ុន្មានអីនៅហ្នឹងឃើញទាំងអស់។ អ្នកខ្លះក៏គេរកឃើញ អ្នកខ្លះរកមិនឃើញ ព្រោះអីអក្សរនោះដូចពងចៃអ៊ីចឹង មិនងាយរកឃើញទេ។

[១៣:៤៤:៥៩]

**ស៖** សូមអរគុណលោកស្រី។ តើបញ្ជីហ្នឹង ដែលលោកស្រីបានឃើញជាបញ្ជីរបស់ -- បញ្ជីដែលគេធ្វើ សៀវភៅដែលគេធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ជាបញ្ជីថ្មីដែលគេតម្កល់នៅមន្ទីរក្រាំងតាចាន់ចាស?

**ឆ៖** ចាស សៀវភៅនោះ គឺឯកសារនោះ គឺអក្សរនោះ កាលពីជំនាន់ៗខ្មែរក្រហមរួចមក គេថតចម្លងយកមកដាក់ជាសៀវភៅមួយចាស។ ឯកសារហ្នឹងតាំងពីៗជំនាន់មុននោះ ហើយក្រោយមកគេថតចម្លងហ្នឹងយកមកដាក់ជាសៀវភៅមួយ ប៉ុន្តែមិនដឹង សៀវភៅហ្នឹងមិនដឹងជាដាក់នៅឆ្នាំប៉ុន្មានទេអ្នកគ្រូ ខ្ញុំដូចអត់សូវចាំច្បាស់។ ប៉ុន្តែសៀវភៅហ្នឹងនៅដល់ទល់ឥឡូវនេះ។

**ស៖** អរគុណលោកស្រី។ ក្រៅពីឈ្មោះឪពុកលោកស្រី តើលោកស្រីមានឃើញឈ្មោះបញ្ជីអ្នកទោសផ្សេងទៀតទេលោកស្រី? មានច្រើននាក់ទេនៅក្នុងសៀវភៅហ្នឹង?

**ឆ៖** ចាស ក្នុងសៀវភៅហ្នឹងមិនមែនមានតែឪពុកខ្ញុំទេ រាប់ពាន់នាក់។ តែសៀវភៅហ្នឹងថាមានពីរក្បាល ប៉ុន្តែខ្ញុំឃើញតែមួយក្បាលទេដែលជាឪពុកខ្ញុំហ្នឹង។ តែខ្ញុំសួរអ្នកមើលការខុសត្រូវនៅក្នុងហ្នឹងដូចជាអាចារ្យ ដូចជាអីហ្នឹង គាត់ថាមនុស្សវាចូលរាប់ម៉ឺននាក់ហើយដែលស្លាប់នៅក្នុងនេះចាស មិនមែនតែរាប់រយទេ ចូលរាប់ម៉ឺននាក់ហើយ ព្រោះអីគ្រាន់តែឆ្អឹងហ្នឹងគំនរកម្ពស់ហ្នឹងចាស ជាគំនរគិតទៅ

កម្ពស់ហ្នឹង ហើយទំហំប្រហែលជាជិត១០ម៉ែត្រហើយ គរជាន់លើគ្នា។ ហើយអ្នកស្លាប់ហ្នឹងវាមានកំណត់ហេតុនៅក្នុងហ្នឹងទាំងអស់ ថារាប់ម៉ឺននាក់។ ចាស ខ្ញុំគ្រាន់តែសួរថា សួរអ្នកមើលការខុសត្រូវនៅក្នុងហ្នឹង ខ្ញុំគ្រាន់សួរថាចុះចំនួនមនុស្សស្លាប់ហ្នឹងប្រហែលជាប៉ុន្មាននាក់លោកតា? ថាចូលរាប់ម៉ឺននាក់ហើយ ប៉ុន្តែនៅសៀវភៅមួយក្បាលទៀត។ នេះដូចថាអន្តរជាតិអីៗអីចឹងទេ គាត់និយាយ ថាមកសើរើទៅវាឃើញឯកសារហ្នឹង អីចឹងគេយកទៅចម្លងដាក់ដើម្បីជាសៀវភៅហ្នឹង ដើម្បីឲ្យមានក្រុមគ្រួសារអីចូលមកធ្វើបុណ្យធ្វើទានមើលទៅ ក្រែងឃើញសពឃើញបងប្អូនអីនៅក្នុងហ្នឹងចាស។

[១៣:៤៨:០៩]

**ស៖** អរគុណលោកស្រី។ លោកស្រីអាចបញ្ជាក់បានទេថា មន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងនៅចម្ងាយប៉ុន្មានពីភូមិដែលលោកស្រីរស់នៅ?

**ឆ៖** ចាស ភូមិនាងខ្ញុំហ្នឹងនៅក្នុងឃុំញ៉ែងញ៉ង តែក្រាំងតាចាន់ដែលគេ -- កន្លែងសារមន្ទីរគេសម្លាប់មនុស្សហ្នឹងនៅក្នុងឃុំគុស តែចម្ងាយប្រហែលជា១០គីឡូលោកប្រធានចាស។

**ស៖** អរគុណលោកស្រី។ តើលោកស្រីមានបានដឹងទេថា ក្រៅពីមន្ទីរសន្តិសុខក្រាំងតាចាន់នៅក្នុងស្រុកត្រាំកក់ហ្នឹង តើមានមន្ទីរសន្តិសុខណាផ្សេងទៀតទេ ដែលលោកស្រីធ្លាប់បានឃើញបានដឹង?

**ឆ៖** ចាស វាដូចថាវាអត់មានកន្លែងប្រមូលផ្តុំមួយកន្លែងៗអីចឹង។ វាឃើញដូចថា កន្លែងខ្មោចរៃចោលនោះៗមួយកន្លែង ពីរកន្លែងអីចឹង តែមួយកន្លែងហ្នឹង តាមខ្ញុំដឹងវាអត់ច្រើនទេ ដូចថាម្នាក់អី ពីរនាក់ រៃនៅព្រៃជិតខាងៗហ្នឹង។ តែចំពោះវាដូចថា គំនរដែលច្រើន ខ្មោចរាប់ពាន់ទៅ វាអត់មានទេ មានតែនៅកន្លែងក្រាំងតាចាន់ហ្នឹងទេ ដែលមានច្រើន។

[១៣:៤៩:៤៥]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំឆ្លងទៅរឿងមួយទៀត ពីព្រឹកមិញលោកស្រីបានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា លោកស្រីធ្លាប់បានចូលរួមនៅក្នុងមីទ្ទិងធំមួយនៅថ្នាក់ស្រុក នៅអង្គរកាហើយនិងអង្គរលាយ។ ខ្ញុំចង់បញ្ជាក់សួរលោកស្រីដែរថា អង្គរការ និងអង្គរលាយ ជាកន្លែងតែមួយ ឬក៏កន្លែងផ្សេងគ្នា?

**ឆ៖** ចាស ដូចម្តេចមីទ្ទិងនៅអង្គរកា និងអង្គរលាយហ្នឹង គឺកន្លែងផ្សេងពីគ្នា គឺឆ្ងាយដាច់ពីគ្នាគឺអង្គរកាហ្នឹង ពីចម្ងាយឃុំខ្ញុំទៅប្រហែល ការស្មានទៅជិត២០គីឡូ។ តែអង្គរលាយ ការប៉ាន់ស្មានពីឃុំខ្ញុំទៅប្រហែលជា១០គីឡូ តែប៉ុណ្ណឹង។ ចាស ការឆ្ងាយដាច់ពីគ្នា អត់មានជិតគ្នាទេ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**សៈ** អ៊ីចឹងបានន័យថា លោកស្រីបានចូលរួមប្រជុំមីទិ្ទងថ្នាក់ស្រុកហ្នឹងពីរដង អ៊ីចឹងលោកស្រីមែនទេ?

**ឆៈ** ចាស ការមីទិ្ទងហ្នឹង វាកើតមានញឹកញាប់ដែរ ប៉ុន្តែខ្ញុំវាភ្លេចខ្លះអីខ្លះ ប៉ុន្តែចាំដូចជាចាំវាពីរដងចាស ដឹងថាកន្លែងចំណុចអង្គរកា និងអង្គរលាយ។

[១៣:៥១:២៤]

**សៈ** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីរំឭកឡើងវិញមើល តើពេលដែលប្រជុំមីទិ្ទងហ្នឹង តើមានមនុស្សប្រហែលប៉ុន្មាននាក់ លោកស្រីចូលរួម? ហើយអ្នកណាជាអ្នកដឹកនាំអង្គប្រជុំហ្នឹង?

**ឆៈ** ចាស ខ្ញុំអត់សូវស្គាល់ច្បាស់ទេ ចាសអត់សូវស្គាល់ ដឹងតែពីថ្នាក់លើ អង្គការ ដឹងតែអង្គ-ការៗ ពេលនោះដឹងតែអង្គការៗ ប៉ុន្តែមិនដឹងអង្គការមកពីណា ចេះតែថាមកពីលើៗ។ ចាស ហើយអ្នកចូលរួមនោះច្រើនណាស់ ខ្ញុំដូចថា វាអត់ដឹងវត្តមានហ្នឹងមានប៉ុន្មាននាក់ទេ ដឹងតែច្រើនតែម្តង។ ពេលនោះអ្នកចូលរួមមានយុវជន យុវនារី ប្រធានកង ហើយមានកងទ័ពចាស កងទ័ពទាំងអស់មកចូលរួមធ្វើមីទិ្ទងហ្នឹង។

**សៈ** អរគុណលោកស្រី។ តើលោកស្រីនៅចាំទេថា តើនៅពេលប្រជុំហ្នឹង ខ្លឹមសារដែលសំខាន់នៃអង្គប្រជុំហ្នឹងម៉េចខ្លះទៅលោកស្រី លោកស្រីអាចរៀបរាប់បានទេ?

**ឆៈ** ចាស ការរៀបរាប់ក្បោះក្បាយ ហាក់បីដូចជាអត់ចាំទេ តែតែចាំចំណុចខ្លះៗ ដូចថាចំណុចមួយ ដូចថាគេពង្រឹងកងទ័ពអ៊ីចឹងទៅ និយាយពីសមរភូមិខាងមុខ និយាយតែពីសមរភូមិខាងមុនអ៊ីចឹងទៅ។ មួយដូចថាយើង ដូចនិយាយពីកម្លាំងស្រួចអ៊ីចឹង និយាយតែរើសម្រុក ចូលសម្រុកអ៊ីចឹងទៅកម្លាំងស្រួច កម្លាំងទី១អ៊ីចឹងទៅ គេដូចថាលើកទឹកចិត្តយើងខ្លះៗអ៊ីចឹងទៅ មានស្អីស្បែកជើងអីលើកទឹកអ៊ីចឹងទៅ។ ហើយនិងមួយទៀត គេនិយាយដូចថា ដូចថាកុំស្រម៉ៃអ៊ីចឹងទៅ កុំឲ្យយើងស្រម៉ៃមើលឃើញសង្គមវិលត្រឡប់មកវិញអ៊ីចឹង កុំឲ្យសង្គមវិលត្រឡប់មកវិញ គេនិយាយថា កសាងប្រទេសជាតិអ៊ីចឹង។ គេលើកហេតុផលដែរ ថាថ្ងៃអនាគតទៅ យើងសម្បូរសប្បាយអី មានផ្លូវអីខ្វាត់ខ្វែង ដូចក្រឡាចត្រង្គ មានភ្លើងអគ្គិសនី ទូរទស្សន៍អីមានឃើញរូប មានអីអ៊ីចឹងទៅ។ ចាស ប៉ុន្តែសំខាន់គេសង្កត់នៅលើសីលធម៌ ដូចជាចម្រៀងសម័យអីហ្នឹង កុំឲ្យភ្លើតភ្លើន ការស្រឡាញ់គ្នាហ្នឹងកុំឲ្យខុសសីលធម៌ អ៊ីចឹងទៅ។ និយាយដល់ចំពោះលោកសង្ឃវិញ គេនិយាយសុទ្ធតែចាញ់បោកព្រះអ៊ីចឹងទៅណា មានចាញ់បោកព្រះស៊ីម៉ងត៍អី។ ចាស អាហ្នឹងខ្ញុំចាំចំណុចខ្លះៗប៉ុណ្ណឹង។

[១៣:៥៤:៥០]

**ស៖** អរគុណលោកស្រី។ ខ្ញុំសូមឲ្យលោកស្រីបញ្ជាក់មួយចំណុចទៀត គឺថាតាមចម្លើយលេខ ១០របស់លោកស្រី លោកស្រីបានឃើញ តាម៉ុក ម្តង ធ្វើទស្សនកិច្ចនៅពេលគាត់មកផ្នែកឧស្សាហកម្ម។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់កន្លែងហ្នឹងបន្តិចមើលលោកស្រី តើលោកស្រីឃើញ តាម៉ុក ហ្នឹងនៅកន្លែងណា? ភូមិណា? ហេតុអីបានជាលោកស្រីដឹងថាជា តាម៉ុក?

**ឆ៖** ចាស តាម៉ុក ហ្នឹង ចំពោះខ្ញុំផ្ទាល់អត់ដែលឃើញទេ។ តែចំពោះប្តីខ្ញុំ គាត់ធ្វើឧស្សាហកម្មនៅឃុំលាយបូរ។ រួច តាម៉ុក ហ្នឹងគាត់មកផ្ទាល់។ ប្តីខ្ញុំប្រាប់ថាមាន តាម៉ុក មក គាត់មកមើលត្រួតពិនិត្យខាងឧស្សាហកម្មហ្នឹង។ ប្តីខ្ញុំគាត់ធ្វើជាងដែកជាងអីហ្នឹង ហើយខ្ញុំក៏អត់បានឃើញផ្ទាល់នឹងភ្នែកដែរ ប៉ុន្តែគ្រាន់ថា តាម៉ុក គាត់ចុះមកស្រុកត្រាំកក់ហ្នឹង។ ចាស ប្តីខ្ញុំគាត់បានប្រាប់ថា "ថ្ងៃណេះៗ តាម៉ុក មកអ៊ីចឹង" ថាអីភូមិភាគអី ខ្ញុំអត់ -- អាហ្នឹងខ្ញុំតាមរយៈប្តីខ្ញុំទេ ប្តីខ្ញុំគាត់មកពីធ្វើការ គាត់ប្រាប់ថាៗ តាម៉ុក មកថ្ងៃណេះអ៊ីចឹង មកត្រួតពិនិត្យខាងឧស្សាហកម្មអ៊ីចឹងទៅ ចាស។ តែចំពោះខ្ញុំអត់ដែលស្គាល់ អត់ឃើញ។ ស្គាល់តែអង្គការៗ ឃើញអង្គការអ៊ីចឹងទៅ មកប្រជុំ ដឹងតែអង្គការៗ។

[១៣:៥៦:៣២]

**ស៖** អរគុណលោកស្រី។ អ៊ីចេះ ពេលនោះលោកស្រីមានដឹងថា តាម៉ុក ហ្នឹង ធ្វើអីដែរកាលនុ៎ង? ជាគណៈស្រុក ឬក៏គណៈតំបន់ ឬក៏អី? លោកស្រីមានដឹងទេ ចាស?

**ឆ៖** ចាស ខ្ញុំអត់ដឹងតួនាទីគាត់អីទេ ដឹងតែអង្គការមួយមុខ ដឹងតែអង្គការថ្នាក់លើ។

**ស៖** អរគុណលោកស្រី។ ពីព្រឹកមិញដែរ លោកស្រីបានបញ្ជាក់នៅមុខអង្គជំនុំជម្រះ និងតាមចម្លើយទី៧របស់លោកស្រី លោកស្រីបានបញ្ជាក់ថាលោកស្រីបានទទួលលិខិតមួយពីមេឃុំឈ្មោះបឿន។ លោកស្រីមានបានមើលទេ នៅក្នុងខ្លឹមសារនៃសំបុត្រដែលលោកស្រីទទួលពីមេឃុំហ្នឹង មានខ្លឹមសារម៉េច ដែរលោកស្រី? ហើយអ្នកណាជាអ្នកចុះហត្ថលេខា ឬក៏ផ្តិតមេដៃអីលើសំបុត្រអញ្ជើញលោកស្រីហ្នឹង?

**ឆ៖** ចាស សំបុត្រនោះ ខ្ញុំគ្រាន់តែបានឃើញពាក្យតែឃ្លាខ្លីទេ ព្រោះអីគាត់ឲ្យនីរសារយកមកឲ្យគាត់គ្រាន់តែដាក់ឈ្មោះ អញ្ជើញឈ្មោះខ្ញុំហ្នឹង ហើយថា "ទៅជាប្រញាប់ កុំឲ្យយប់ទាន់" ដាក់គ្រាន់តែដាក់ប៉ុណ្ណឹងទេ "កុំឲ្យយប់ទាន់ -- ជាប្រញាប់ កុំឲ្យយប់ទាន់" ហើយដាក់លេខទោហ្នឹង ខ្ញុំចាំ ដាក់លេខទោហ្នឹងច្រើនណាស់ "ប្រញាប់ៗ" ហ្នឹងច្រើនណាស់។ ប៉ុន្តែពាក្យសំបុត្រហ្នឹង ពាក្យឃ្លាដែលខ្លី

មួយមាត់ទេ អត់មានវែងឆ្ងាយទេ។ នីវសារយកមកហ្នឹង ខ្ញុំអានហ្នឹង អាននោះថា ឲ្យឈ្មោះខ្ញុំហ្នឹងទៅសាលាឃុំជាបន្ទាន់ "កុំឲ្យយប់ទាន់ ប្រញាប់ៗ" ខ្ញុំចាំពាក្យប៉ុណ្ណឹង អាប្រញាប់ហ្នឹង ខ្ញុំចាំពាក្យជាងគេលេខទោច្រើនណាស់។

[១៣:៥៨:៣៩]

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកស្រី ស្រីមុំ ដែលលោកស្រីបានជួយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះ។

លោកប្រធាន ដោយពេលវេលារបស់យើងខ្ញុំមានកំណត់។ ខ្ញុំសូមប្រគល់ការសួរសំណួរទៅដល់សហភាគអន្តរជាតិ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! លោកស្រីមានពេលវេលា១០មីនុត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីអន្តរជាតិដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរួម។ ខ្ញុំសូមចោទសំណួរបន្តមួយចំនួនធៀបទៅនឹងអ្វីដែលលោកស្រីបានឆ្លើយកាលពីព្រឹកមិញ ហើយនិងសុំឲ្យលោកស្រីនិយាយអំពីយប់មួយ នៅ<ក្នុងខែឧសភា> ឆ្នាំ១៩៧៧ នៅពេលដែលគេកោះហៅលោកស្រីទៅសាលាឃុំដើម្បីរៀបការ។ ខ្ញុំចង់ដឹងថា តើគេបានពន្យល់លោកស្រីពីមូលហេតុដែលលោកស្រីត្រូវរៀបការដែរឬទេ នៅពេលនោះ?

[១៣:៥៩:៤៧]

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ពេលគេកោះហៅខ្ញុំចូលរួមទៅរៀបការ គឺមុនដំបូង គឺមានលិខិតមួយ គេហៅខ្ញុំថា "ឲ្យទៅជាបន្ទាន់ កុំឲ្យយប់ ប្រញាប់ៗ" លេខទោច្រើនហ្នឹងខ្ញុំចាំ។ ប៉ុន្តែដល់ពេលអ្នកកោះហៅហ្នឹងៗអ្នកផ្សេង អាហ្នឹងជាប្រធាន។ ដល់តែពេលខ្ញុំទៅជួបហ្នឹង អ្នកផ្សេងដែលៗ មកជួបខ្ញុំគឺប្រធានកងនារីៗមកដល់ ខ្ញុំក៏សួរថា៖ "បងហៅខ្ញុំមានការអី?" គាត់ថា៖ "ឥឡូវរៀបចំទៅ អង្គការរៀបប្តេជ្ញាយប់ហ្នឹងហើយ។" ខ្ញុំក៏មានការរន្ធត់ឮថាប្តេជ្ញាហ្នឹង មិនដឹងថាប្តេជ្ញាជាមួយបុរសណា ខ្ញុំក៏អត់ហ៊ានសួរគេដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដល់ហើយប្រធានកងនារីហ្នឹង គេសួរខ្ញុំថា៖ “ម៉េចឥឡូវហ្នឹងសម្រេចចិត្តម៉េចហើយ?” ខ្ញុំក៏ទាល់ច្រកពេក ខ្ញុំមិនដឹងឆ្លើយថាម៉េច ខ្ញុំផ្អែកទៅលើថា “ស្រេចលើម្ដាយខ្ញុំ”។ គេថា៖ “រាល់ថ្ងៃយើងកូនអង្គការ ឬមួយកូនម៉ែឪ?” ខ្ញុំឆ្លើយថា៖ “ខ្ញុំកូនអង្គការ”។ “អ្ហឺ! បើកូនអង្គការរៀបចំទៅ អង្គការសម្រេចប្ដេជ្ញាយប់ហ្នឹងហើយ” ខ្ញុំក៏ដាច់ចិត្តសួរថា៖ “តើឲ្យខ្ញុំរៀបការជាមួយបុរសណា? យុវជនណា?” គេឆ្លើយថា៖ “រៀបការជាមួយ ទ្រី ទូច។” ខ្ញុំក៏អត់ហ៊ានឆ្លើយដែរពេលហ្នឹងនៅស្ងៀម នៅស្ងៀមអ៊ីចឹងគេឲ្យពេលវេលាយើង មកកន្លែងកង។ ហ្នឹងដូច -- មកកន្លែងកងហ្នឹង ដើម្បីឲ្យត្រៀមខ្លួនវិលត្រឡប់ទៅវិញ ខ្ញុំក៏មកកន្លែងកងមួយភ្លែតហ្នឹង ក៏សុខចិត្តហ្នឹង ថាឆ្លៀតឱកាសហ្នឹងចូលថ្វាយបង្គំព្រះអង្គហ្នឹង បន់ស្រន់ព្រះអង្គហ្នឹងថា កុំឲ្យមានកម្មវិធីហ្នឹងកើតឡើងក្នុងពេលយប់នេះ បើគិត -- បើពិតមែន -- បើគូព្រេងរបស់ខ្ញុំ សូមព្រះអង្គជួយសម្រួលចិត្តខ្ញុំឲ្យខ្ញុំមានចិត្តទោរទន់អី។ អ៊ីចឹងខ្ញុំបន់ដូច-- លើកដៃសំពះផង យំផងអ៊ីចឹង។ ដល់ពេលហើយខ្ញុំរូតទៅវិញៗ ស្រវាចូលក្នុងកន្លែងកម្មវិធីគេរៀបហ្នឹង ប៉ុន្តែប្ដីគាត់អត់ទាន់ដឹងទេ ខ្ញុំដឹងមុនគេ។ ដល់ប្ដីខ្ញុំហ្នឹងគាត់មកហូបបាយ ដល់ពេលមកហូបបាយអ៊ីចឹង គេថាមាននីរសារ ហៅថា “អ្ហូ! ទៅៗចាប់គោៗរួចនៅសាលាឃុំ”។ ប្ដីខ្ញុំក៏គាត់ហូបបាយហ្នឹងអត់ទាន់ឆ្អែតដែរ ប៉ុន្តែឮគោដាច់ហើយ គាត់ស្រវាៗមកចាប់គោ ទៅដល់ “យី! យូរម្ល៉េះ? ចូលទៅៗ”។ ចាស ចូលទៅៗ ដល់ពេលចូលទៅ--

[១៤:០២:៤២]

**ស៖** លោកស្រីៗ ខ្ញុំសូមកាត់ផ្ដាច់បន្តិច។ ខ្ញុំសូមអរគុណលោកស្រី ដែលបានពន្យល់ម្ដងទៀតយ៉ាងលម្អិតនូវលំដាប់លំដោយនៃព្រឹត្តិការណ៍នេះ ប៉ុន្តែសំណួរខ្ញុំគ្រាន់តែសួរថាតើ<>គេមានប្រាប់ទេថាហេតុអីបានលោកស្រីត្រូវ<រៀប>ការ គេមានពន្យល់ពីមូលហេតុទេ <តើគោលបំណងនៃការរៀបការនេះជាអ្វីដែរ?> អ៊ីចឹងខ្ញុំគ្រាន់ចង់បានប៉ុណ្ណឹងទេលោកស្រី សូមលោកស្រីជួយប្រាប់ថាតើគេពន្យល់ពីមូលហេតុនៃការ<>រៀបការហ្នឹងទេ?

**ឆ៖** ចាស សុំទោសចាស។ ពីមុនគេអត់បានពន្យល់ទេ ក្រោយមកបានខ្ញុំមកជួបគេ បានពន្យល់ក្នុងពេលដែលចូលរៀបការហ្នឹង បានគេពន្យល់ប្រាប់ថាពេលសម្រេចចិត្ត -- អង្គការសម្រេចចិត្តយប់ហ្នឹងហើយ ឲ្យត្រៀមខ្លួនទៅ គេពន្យល់នៅពេលហ្នឹង ចាស។

**ស៖** លោកស្រី ចំពោះលោកស្រីវិញ តើគោលបំណងនៃការរៀបការនេះគឺដើម្បីបង្កើតកូនឲ្យអង្គការ? គេពន្យល់លោកស្រីប្រាប់ថាអ៊ីចឹង ឬក៏យ៉ាងម៉េច? តើ<នេះគឺជាហេតុផលជាក់ស្ដែងដែរទេ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៤:០៤:២៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ព្រោះសាក្សីមិនដែលបានឆ្លើយថារៀបការដើម្បីបង្កើតកូនឱ្យអង្គការទេ ហើយសំណួរនេះគឺជាសំណួរនាំមុខ។ ដូច្នេះខ្ញុំសូមជំទាស់បាទ។ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ។ លោកប្រធានខ្ញុំមិន<បានដាក់សំណួរ>នាំមុខទេអម្បាញ់មិញហ្នឹង ខ្ញុំគ្រាន់តែសួរថាគាត់ទទួលអារម្មណ៍យ៉ាងម៉េចដែរ? យើងត្រូវដឹងៗពីមូលហេតុព្រោះថា ពួកគាត់ទាំងអស់គ្នាត្រូវគេបង្ខំឱ្យរៀបការ។ អ៊ីចឹង<>ទាក់ទងទៅនឹងការរៀបការដោយបង្ខំនេះ <វាគឺជាបទចោទមួយនៅក្នុងរឿងក្ដីនេះ> ហើយចៅក្រមអាចធ្វើការ<ថ្លឹងថ្លែងទៅលើសក្ខីកម្មរបស់សាក្សីនេះ តាមការយល់ឃើញរបស់លោក ប៉ុន្តែ ចំពោះខ្ញុំ ខ្ញុំយល់ថាសំណួរនេះ គឺវាពាក់ព័ន្ធទាំងស្រុងទៅនឹងសំណុំរឿងក្ដីនេះ>?

**ប្រធានអង្គជំនុំ៖**

សំណួរបើជាភាសាខ្មែរ គឺមានន័យខ្លឹមសារគឺនាំមុខហើយ។ អ៊ីចឹងការជំទាស់ហ្នឹងសមស្រប។ អ៊ីចឹងដើម្បីឱ្យច្បាស់លាស់ ដោយមានបញ្ហាអ្នកស្ដាប់ភាសាអង់គ្លេស ចៅក្រមហ្នឹងគឺគាត់យល់ថាសំណួរហ្នឹងសមស្រប ប៉ុន្តែយើងជាភាសាខ្មែរយល់ថាសំណួរនេះមិនអនុញ្ញាតឱ្យឆ្លើយទេ ដោយសារមូលហេតុជាសំណួរនាំមុខ។ អ៊ីចឹងសូមលោកស្រីមេធាវីរៀបចំសំណួរអម្បាញ់មិញនេះសាជាថ្មីម្ដងទៀត។

[១៤:០៦:០៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធានខ្ញុំសាកល្បងមួយសាទៀត។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកស្រី យប់នុំង ឬក៏យប់ក្រោយមកទៀតលោកស្រីមានបានឮគេពន្យល់ពីមូលហេតុដែលត្រូវរៀបការ ដើម្បីបង្កើតកូនឱ្យអង្គការដែរឬទេ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស សូមទោស អម្បាញ់មិញខ្ញុំស្ដាប់សំណួរមិនសូវបានចាស។ ពេលការរៀបការគេអត់មានពន្យល់ពីអ្វីទាំងអស់ គេគ្រាន់តែបញ្ជាក់ថា យប់ហ្នឹងត្រៀមខ្លួនចូលរៀបការ គឺអង្គការសម្រេចប្ដេជ្ញាឲ្យយប់ហ្នឹងហើយ។ តែគេពន្យល់ទៅមុខទៀតការរៀបការ ទៅអ្វីខាងមុខទៀតគេអត់មានពន្យល់ទេចាស។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីយប់ទី១ ដែលលោកស្រីបាននៅជាមួយប្ដីរបស់លោកស្រី ហើយលោកស្រីបានរៀបរាប់កាលព្រឹកមិញដែរ ហើយនៅរាត្រីនោះមានឈ្លប <នេះជាពាក្យដែល>ខ្ញុំឮតាមរយៈអ្នកបកប្រែជាភាសាបារាំងទេ ដែលគេបកព្រឹកមិញថាអ៊ីចឹង គឺថាមានឈ្លបមកក្រោមផ្ទះលោកស្រីដើម្បីលបស្ដាប់។ អ៊ីចឹងខ្ញុំសូមឲ្យលោកស្រីផ្ដល់ព័ត៌មានបានលម្អិតបន្តិច ហើយលោកស្រីអាចដឹងថាតើឈ្លបហ្នឹងគេចង់មកស្ដាប់<>អ្វីខ្លះ? លោកស្រីអាចពន្យល់បានទេគេមកលបស្ដាប់ហ្នឹងចង់ស្ដាប់អីគេ សូមពន្យល់ឲ្យបានច្បាស់លាស់បន្តិច។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់នេះគឺជាការ<សួរឲ្យ>ទាយស្មានតែប៉ុណ្ណោះ។ <សំណួរជាក់លាក់នេះគឺសួរថាតើពួកគេបានព្យាយាមធ្វើអ្វី? មានន័យថា> គាត់អាចទាយថា មានអ្វីដែលកើតឡើង ឬក៏គេអាចនឹងធ្វើអ្វីប៉ុន្តែ<>គាត់អាចធ្វើបានក្នុងនាមជាសាក្សី គឺគាត់គ្រាន់តែអាចផ្ដល់សក្ខីកម្មអំពីអ្វីដែលគាត់បានឃើញបានឮ <គឺមិនមែនអ្វីដែលគេបានព្យាយាមធ្វើនោះទេ>។

[១៤:០៨:០៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន គឺថាស្ដុតាង<ទាំងអស់ត្រូវទទួលយកនៅក្នុងតុលាការនេះ។> យើងអាចចោទសំណួរដែលយើងចង់សួរ <ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់>អង្គជំនុំជម្រះ។ <លោក និងលោកស្រីចៅក្រម គឺជា>ចៅក្រមអាជីព <ដែលជាអ្នកទាញរកភាពខុសគ្នា> អ្វីដែលត្រូវ អ្វីដែលមិនត្រឹមត្រូវ<នៅក្នុងកំណត់ត្រាសក្ខីកម្ម>។ អ៊ីចឹងយើងត្រូវតែមានសិទ្ធិសេរីភាព<ដែរ>ក្នុងការចោទសំណួរ <ហេតុដូច្នេះ យើងអាចសួរប្រភេទសំណួរប៉ះពាល់អាម្មរណ៍ទាំងនេះបាន។> ខ្ញុំចោទសំណួរមួយជាក់លាក់ទៅគាត់ ទៅសាក្សី<> ហើយខ្ញុំចង់បានមតិយោបល់ពីគាត់ ព្រោះគាត់ជាសាក្សីផ្ទាល់នៅពេលនោះ។ អ៊ីចឹងខ្ញុំគិតថា ដូចជាមិនមែនជាការសួរទៅគាត់ដើម្បីឲ្យគាត់ឆ្លើយព្រាវៗស្មានៗនោះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០៨:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៀតទេ ដោយសារសំណួរនេះនាំឲ្យសាក្សីឆ្លើយតបដោយស្មានៗ ជាសំណួរដែលមិន--

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១០:៤៤]

**ប្រធានអង្គជំនុំ៖**

ហ្សង់ម៉ាក អាចបញ្ជាក់ប្រាប់គាត់ឲ្យបានច្បាស់លាស់ទេ មេធាវីការពារក្តី? ដែលការតាំងសំណួរហ្នឹងយ៉ាងម៉េចទៅ? លោក ហ្សង់ម៉ាក ដែលមានបំណងចង់ឲ្យគាត់កែសម្រួលនូវពាក្យ -- នូវសំណួរដែលគាត់មានបំណងសួរ ហើយនេះជាសំណួរចុងក្រោយហើយ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ <ខ្ញុំគិតថា> យើងអាចសុំឲ្យគាត់<ប្រាប់មកអង្គជំនុំជម្រះវិញ ពាក់ព័ន្ធនឹងអ្វីដែលលោកស្រីសាក្សីដឹងឮផ្ទាល់>អំពីវត្តមានឈ្លបនៅក្រោមផ្ទះគាត់<។ ដូច្នេះ លោកស្រីនឹងមិនឆ្លើយព្រាវៗនោះទេ។> តើ<>កាលនោះគាត់ដឹងថាមានឈ្លបនៅនឹងក្រោមផ្ទះគាត់ទេ? អ៊ីចឹង សំណួរហ្នឹងសួរថា លោកស្រីសាក្សីសំណួរនេះច្បាស់ទេ? <>

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ជាការពិតណាស់ ពេលដំបូង ពេលខ្ញុំមករួមដំណេកជាមួយប្តី ខ្ញុំលបឃើញឈ្លបឃើញលបៗឃើញឈ្លបនៅក្រោមផ្ទះ ប៉ុន្តែខ្ញុំមានការភ័យខ្លាច ចំពោះខ្លួនខ្ញុំមានការភ័យខ្លាច។ ប៉ុន្តែចំពោះឈ្លបគេមានគោលបំណងយ៉ាងម៉េចក៏ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែខ្ញុំធ្លាប់ដឹង អ្នករៀបការពីមុនៗមកពេលឈ្លបគេស្តាប់ឮនៅក្រោមផ្ទះអ៊ីចឹង ពេលយើងមិនចុះដំណេកគ្នា គេតែងតែយកយើងទៅកសាងចាស គេយកយើងកសាងហើយ។ អ៊ីចឹង ចំពោះខ្លួនខ្ញុំ ពេលនោះខ្ញុំលបឃើញឈ្លប ក៏ខ្ញុំមានការភ័យខ្លាចៗព្រោះអីខ្ញុំខ្លាចមានកំហុសមួយ។ ម៉្យាងខ្ញុំបារម្ភ ព្រោះអីឪពុកខ្ញុំទើបតែស្លាប់ ឥឡូវមានឈ្លបមកលបនៅក្រោមផ្ទះទៀតអ៊ីចឹង ខ្លាចដល់មានបញ្ហាចំពោះខ្លួនខ្ញុំចាស។ អ៊ីចឹង ខ្ញុំមានការភ័យខ្លាចត្រង់ហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:១៣:១១]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំនៅសំណួរមួយទៀត សំណួរចុងក្រោយបន្តពីចម្លើយរបស់លោកស្រីនេះ និងតាមខ្ញុំស្ដាប់ឮការបកប្រែជាបារាំងនោះ គឺថានៅពេលដែលគូស្វាមីទាំងពីរហ្នឹងមិនត្រូវរ៉ូវគ្នាហ្នឹង អ៊ីចឹងចុះ លោកស្រីចង់ៗនិយាយយ៉ាងម៉េចដែរ ពេលដែលនិយាយថា ពេលដែលគូស្វាមីដែលគេទើបរៀបការឲ្យថ្មីៗហ្នឹងមិនចុះសម្រុងនឹងគ្នាហ្នឹង <តើលោកស្រី>ចង់មានន័យថាយ៉ាងម៉េច?

**ឆ៖** ចាស ហ្នឹងមានន័យថា ការមិនចុះសម្រុងគ្នាហ្នឹង ពេលខ្លះយុវជនហ្នឹងស្រឡាញ់ ប៉ុន្តែប្រពន្ធអត់ស្រឡាញ់ប្ដី។ អ៊ីចឹង ដល់ពេលអត់មាន -- អត់ស្រឡាញ់ប្ដីអ៊ីចឹង ចេះតែមានបញ្ហា។ ដល់មានបញ្ហាអ៊ីចឹង ថ្ងៃណាក៏គេហៅទៅកសាងប្រជុំ តិចៗហៅប្រជុំកសាង តិចៗប្រជុំកសាងអ៊ីចឹង ព្រោះអីនៅក្នុងឃុំខ្ញុំធ្លាប់មានបញ្ហាការរៀបការហើយ។ នារីហ្នឹងអត់ស្រឡាញ់ប្ដី ដល់អត់ស្រឡាញ់ប្ដីទៅ អត់ចុះដំណេក ដល់អត់ចុះដំណេកអ៊ីចឹងទៅ ឈ្លបគេដឹង គេហៅនារីហ្នឹងមកកសាងអ៊ីចឹងទៅ ចេះតែមកកសាង ប៉ុន្តែដល់ដាក់ទោសអីដល់ប្រហារជីវិត វាអត់ទាន់មានទេ។ ប៉ុន្តែបើកាលណាគេណែនាំ យើងអត់នេះ គេដាក់ជាទណ្ឌកម្ម ឲ្យដកស្មៅរែកដីអ៊ីចឹងទៅចាស។

[១៤:១៥:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អស់ពេលហើយណ៎ា។ បាទ មុននឹងអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី សួរទៅចៅក្រម អស់លោក លោកស្រី តើមានអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ។

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** នេះគឺជាសំណួរសួរបន្តពីសំណួរចុងក្រោយ ដែលសហមេធាវីនាំមុខបានសួរ។ សហមេធាវីនាំមុខបានសួរថាតើលោកស្រីខ្លាចអ្វីដែរបើសិនណាលោកស្រីមិនចុះដំណេកជាមួយប្ដីលោកស្រី? ហើយលោកស្រីថា <ប្ដីប្រពន្ធនោះ>អាចមាន<បញ្ហា>អ្វីមួយកើតឡើង រឿងអ្វីមួយមិនល្អ<អាច>កើតឡើងចំពោះ<>លោកស្រី។ តើ<បញ្ហាមិនល្អអីទៅ ដែលលោកស្រីគិតថានឹងកើតឡើងចំពោះលោកស្រីនោះ?>។ <ខ្ញុំមិនប្រាកដថា ការបកប្រែនេះបានល្អទេ។ បើសិនជាមិនបានល្អទេ> ខ្ញុំសូមបំបែកទៅ

ជាឃ្លាខ្លីៗ<។> លោកស្រីយល់សំណួរខ្ញុំទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស យល់ថាចំពោះខ្លួនខ្ញុំ បើមិនចុះដំណេក ខ្ញុំយល់ថា ខ្ញុំមុខតែមានបញ្ហា ព្រោះអីឪពុកខ្ញុំទើបតែស្លាប់ពីរថ្ងៃ។ អ៊ីចឹង ដូចថាគេចាត់ទុកថា គ្រួសារខ្ញុំប្រឆាំងនឹងបក្ស។ អ៊ីចឹងខ្ញុំខ្លាចនៅកន្លែងសេចក្ដីស្លាប់ត្រង់ហ្នឹងហើយ បានថាខ្ញុំចេះតែសម្រួលចិត្ត ចាស សម្រួលចិត្ត ខ្លាចគេយកទៅសម្លាប់ចោល ព្រោះអី ម្យ៉ាងការរៀបការនេះ ដោយសារថា ខ្ញុំនេះវាមានចំណុចពាក់ព័ន្ធជាមួយឪពុក បានតែគេឲ្យរៀបការ។ រៀបការ បើកាលណារៀបការហើយ យើងនៅតែប្រឆាំងនឹងបក្ស ខ្ញុំដឹងថា ខ្ញុំខ្វះសេចក្ដីសុខនៅពេលហ្នឹងហើយ។ អ៊ីចឹងត្រង់ហ្នឹងហើយ ដែលកាលខ្ញុំភ័យខ្លាច ឃើញឈ្លបមកលប។

[១៤:១៧:៣៤]

**ស៖** សូមអរគុណលោកស្រី ច្បាស់ហើយចម្លើយនេះ។ សំណួរមួយទៀត លោកស្រីបាននិយាយថា លោកស្រីខ្លាចថា គេសម្លាប់លោកស្រីចោល ប្រសិនណាលោកស្រីមិនរួមដំណេកទេ។ សំណួរខ្ញុំសួរថា តើលោកស្រីធ្លាប់បានដឹងថា មានអ្វីកើតឡើងទៅលើគូស្រករដទៃទៀតដែរទេ ដែលមិនចុះដំណេកនឹងគ្នា ក្រោយពីរៀបការហើយ? លោកស្រីបានជម្រាបជូនអង្គជំនុំជម្រះនូវចំណុចមួយ គឺគេបាននិយាយអំពីបញ្ហានេះ<>ជាក្រុម<>។ តើ<មាន>រឿង<អ្វីផ្សេងទៀតកើតឡើង>ចំពោះគូស្រករដទៃ ដែលមិនចុះសម្រុងគ្នាហ្នឹង<>?

**ឆ៖** ចាស ចំពោះខ្ញុំដឹងដែលគ្រួសារដទៃ ដែលមិនចុះដំណេកគ្នាហ្នឹង ដោយសារនៅក្នុងក្រុមក្នុងកង ដល់តែពេលអង្គប្រជុំទិតៀន គេលើកយកមកណែនាំនារីហ្នឹង ដែលមិនចុះដំណេកជាមួយប្ដីគេចេះតែកសាងញឹកញាប់។ អ៊ីចឹងបានខ្ញុំដឹងថា នារីហ្នឹងមិនចុះដំណេក មូលហេតុប្រធានកងគេដឹងប្រធានក្រុមគេដឹង ដឹងអ៊ីចឹង ដល់ពេលហើយកសាងនៅក្នុងអង្គប្រជុំទៅ ចំពោះខ្ញុំចូលរួមអង្គប្រជុំ ខ្ញុំដឹងរយៈពេលមេក្រុម មេកងហ្នឹង គេកសាងសមាជិកឲ្យប្រជុំហ្នឹង។ ចាស ហ្នឹងខ្ញុំដឹងតាមរយៈហ្នឹង ចាស។

**ស៖** ប្រហែលជាបញ្ហាបកប្រែទៀតហើយ។ ខ្ញុំមិនចង់និយាយអំពីការប្រជុំរួមគ្នានោះទេ ខ្ញុំយល់ចំពោះការប្រជុំ<>នោះ។ សំណួរខ្ញុំសួរថា តើប្រសិនណាជាគូស្រករដទៃមិនរួមដំណេកនឹងគ្នាទេ តើមានអ្វីកើតឡើងចំពោះអ្នកទាំងនោះ? នេះខ្ញុំមិនទាន់និយាយទៅដល់រឿងថា គេកសាងអីនៅក្នុងអង្គប្រជុំអីទេ។ ថាតើបើមិនចុះដំណេក មានអ្វីកើតឡើងទៅអ្នកគូស្រក<រ>ថ្មីនោះ?

[១៤:២០:១២]

**ឆ៖** ចាស ចំពោះគ្រួសារដែលមិនចុះដំណោក គេកសាងជាលើកទី១ ទី២ ទី៣។ បើពេលនោះអ្នកនោះនៅមិនតាម គឺគេចាត់ទុកប្រឆាំងនឹងបក្ស។ អ៊ីចឹង អ្នកនោះក៏ត្រូវមានទោស គេដាក់ជាទណ្ឌកម្មឲ្យរែកទឹក ដកស្មៅ។ ចាស ឲ្យរែកទឹក ដកស្មៅអី ស្រោចដូង ស្រោចអី កាប់ដីអ៊ីចឹងទៅ វាស់ដី វាស់អីឲ្យចែកនេះអ៊ីចឹង។ អាហ្នឹងអ្នកដែលមិនចុះដំណោក ឬ -- ហ្នឹងហើយ គេដាក់ទណ្ឌកម្មទៅរបៀបហ្នឹង។

**ស៖** លោកស្រីបានជម្រាបជូនអង្គជំនុំជម្រះថាលោកស្រីខ្លាចគេសម្លាប់លោកស្រីចោល ប្រសិនណាជាលោកស្រីមិនរួមដំណោកជាមួយប្ដីលោកស្រី។ ហេតុអីបានជាលោកស្រីខ្លាចគេសម្លាប់លោកស្រី?

**ឆ៖** ចាស បានជាខ្ញុំខ្លាចគេសម្លាប់ចោល ព្រោះអីគ្រួសារខ្ញុំមានការពាក់ព័ន្ធធ្ងន់ធ្ងរ ព្រោះអីឪពុករបស់ខ្ញុំគេត្រូវយកទៅសម្លាប់ចោល។ ម្យ៉ាងខ្ញុំឮពាក្យមួយយ៉ាងច្បាស់ថា "គេសម្លាប់ហើយ គេរំលើងទាំងឫស" អ៊ីចឹង ខ្ញុំរស់នៅក្នុងសង្គមហ្នឹង ខ្ញុំមានការភ័យខ្លាចរហូត រហូតខ្ញុំធ្វើអ្វីក៏ខ្ញុំប្រុងប្រយ័ត្នខ្ញុំឮពាក្យថា "គេសម្លាប់ចោល" ដូចថា ឪពុកហើយ អ៊ីចឹងមានកូនទៀត គេក្នុងការតាមដានរហូត។ អ៊ីចឹងខ្ញុំធ្វើអ្វី ខ្ញុំដូចថា ប្រុងប្រយ័ត្នរហូត ខ្លាចនូវការស្លាប់ ចាស។

[១៤:២១:៥៩]

**ស៖** សូមអរគុណលោកស្រី។ សំណួរខ្ញុំជាសំណួរចុងក្រោយ តើលោកស្រីធ្លាប់បានឮថា អ្នកណាម្នាក់ដែលធ្លាប់បដិសេធមិនរួមដំណោក ហើយត្រូវបានគេសម្លាប់ចោលទេ?

**ឆ៖** ចាស វាអត់ទាន់មាន ដូចថាការរួមដំណោកហ្នឹង មិនចុះសម្រុងគ្នាហ្នឹង ទោសដូចថា អត់មានទាន់ការសម្លាប់ទេ។ ប៉ុន្តែបើសិនណាជាយើង ចំពោះខ្លួនខ្ញុំវិញ ខ្ញុំគិតថា បើកាលណាខ្ញុំ កាលបក្សរៀបចំ បើខ្ញុំប្រឆាំងនឹងបក្ស គេចាត់ទុកថា "អូ្ហ! គ្រួសារនេះប្រឆាំងនឹងបក្ស សុទ្ធពួកប្រឆាំងនឹងបក្សហើយ"។ ខ្ញុំដឹងច្បាស់ថា គ្រួសារខ្ញុំ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំដឹងថា មុខតែគេសម្លាប់ចោលហើយ ព្រោះអីគេថា យើងប្រឆាំងនឹងបក្ស គេចោទឪពុកខ្ញុំមួយប្រឆាំងនឹងបក្សហើយ។ អ៊ីចឹង កូនហ្នឹង គេថា វាតំណៗគ្នាហើយ។ ចាស តំណៗគ្នា អ៊ីចឹងគេ គេមុខ -- គេតាមដានហើយ។ អ៊ីចឹង បើកាលណា គេរៀបចំឲ្យយើងរៀបអាពាហ៍ពិពាហ៍ហើយ យើងនៅតែប្រឆាំងគេ អាហ្នឹងគេចាត់ទុកថា យើងប្រឆាំងគេហើយ។ ហើយសត្រូវគ្រួសារខ្ញុំ គេចោទប្រកាន់ថា អ្នកប្រឆាំងនឹងបក្សទៀត។ អ៊ីចឹងចំពោះខ្លួនខ្ញុំហ្នឹង ខ្ញុំខ្លាចត្រង់ហ្នឹង ថាខ្ញុំហ្នឹងប្រឆាំងនឹងបក្សទៀតហើយ។ បានខ្ញុំសន្និដ្ឋានថា ខ្ញុំមិនមែនគេកសាងទេ ខ្ញុំមុខតែគេសម្លាប់ចោល។ នេះការសន្និដ្ឋានរបស់ខ្ញុំទេ។

[១៤:២៣:៣៣]

**សះ** សូមអរគុណ។ ខ្ញុំយល់ចម្លើយនេះ គឺថា ដូច្នេះសង្ខេបមកវិញ <មិនមែនករណីរបស់លោកស្រីទេ។ ខ្ញុំយល់ពីបញ្ហាដែល>លោកស្រីខ្លាចគេសម្លាប់ចោល។ ឥឡូវនេះ ខ្ញុំសួរជាទូទៅ មានន័យថា តាមដែលលោកស្រីដឹងបានឲ្យល្អបំផុតនោះ គឺថាអ្វីដែលកើតឡើងចំពោះគូស្រករដទៃទៀត ដែលបដិសេធមិនរួមដំណេក គឺថាវាអាចមានកិច្ចប្រជុំកសាង អប់រំកសាង ហើយនិងអាចដាក់ទណ្ឌកម្មធ្ងន់ៗតែប៉ុណ្ណឹងទេ។ តើមានអ្វីក្រៅពីនេះទៀតទេ ពាក់ព័ន្ធទៅនឹងការមិនរួមដំណេកនោះ?

**ឆះ** ចាស សូមទោស ខ្ញុំស្ដាប់សំណួរមិនសូវបានចាស ម្ដងទៀត។

**សះ** ខ្ញុំសួរសង្ខេប ឥឡូវនេះ ខ្ញុំមិនសួរពីរឿងករណីរបស់លោកស្រីផ្ទាល់ទេ។ ខ្ញុំយល់ហើយ ថាហេតុអ្វីបានជាលោកស្រីខ្លាចគេសម្លាប់ចោល បើសិនណាមិនរួមដំណេក ខ្ញុំយល់ហើយ។ លោកស្រីបានជម្រាបជូនអង្គជំនុំជម្រះថា គូស្រករដទៃទៀត គឺមិនមែនគូស្រករលោកស្រីនេះទេ។ គូស្រករដទៃទៀតដែលមិនរួមដំណេកត្រូវបានដាក់ទណ្ឌកម្ម ដូចជាការកសាងនៅក្នុងអង្គប្រជុំ ឬក៏ដាក់ទណ្ឌកម្មឲ្យធ្វើការងារពលកម្មធ្ងន់ធ្ងរ។ តើមានការដាក់ទណ្ឌកម្មទ្រង់ទ្រាយដទៃទៀតទេ ចំពោះគូរស្រករដទៃទៀតក្រៅពីលោកស្រីនោះ ដែលបដិសេធមិនរួមដំណេក?

[១៤:២៥:២៦]

**ឆះ** ចាសចំពោះគ្រួសារដទៃដែលមិនរួមដំណេកជាមួយគ្នា គេកសាងជាលើកទី១ ទី២ ទី៣ តែចំពោះអ្នកនោះក៏ខ្លាចនូវសេចក្ដីស្លាប់ដែរ ក្រោយមកវា -- ហ្នឹង ខ្ញុំនិយាយដោយខ្ញុំដឹងពិតនៅក្នុងភូមិខ្ញុំមានម្នាក់អ៊ីចឹង អត់ចុះដំណេក គេកសាងអ៊ីចឹង កសាងជាលើកទី១ ទី២ រហូតគេដាក់ទណ្ឌកម្ម ដល់តែគេកសាងទៅគេដាក់កម្រិតដែរ ដល់ដាក់កម្រិតទៅពេលនោះនារីវាចេះតែចុះដំណេកជាមួយប្ដីហើយ។ ប៉ុន្តែចុះដំណេកជាមួយប្ដីហាក់បីដូចជា ការទំនាក់ទំនងប្រាស្រ័យទាក់ទងគ្នាអី រាងព្រងើយៗ ប៉ុន្តែការរួមដំណេកហ្នឹងជាធម្មតាទៅ។ ចាស អ៊ីចឹង ការគេតាមដានហ្នឹង ក៏មើលទៅថានារីហ្នឹងវាស៊ីចង្វាក់គ្នាហើយក៏ៗស្ងប់ស្ងាត់ទៅ។ ប៉ុន្តែខ្ញុំមើលចិត្តនារីនោះចេះតែបំពេញកាតព្វកិច្ចហ្នឹងដោយសារការភ័យខ្លាច ចាស ការភ័យខ្លាចនឹងសេចក្ដីស្លាប់។ អ៊ីចឹងចេះតែរស់នៅជាមួយប្ដីដោយល្ងើងជូរចត់អ៊ីចឹងទៅ ប៉ុន្តែហាក់ -- ធ្វើដូចថាមិនដឹងអ៊ីចឹងមក។ ប៉ុនតាមខ្ញុំដឹងការពិត គ្រាន់តែក្រោយមកបែកនៅឆ្នាំ៧៩ ហ្នឹងនារីហ្នឹងបែកគ្នារហូតៗដល់គេយកប្ដីផ្សេងទៀត បុរសនោះយកប្រពន្ធផ្សេងទៀត ចាស។ ហ្នឹងការមិនចុះដំណេកហ្នឹងអ៊ីចឹង ការចេះតែរស់នៅជាមួយប្ដីដោយល្ងើងជូរចត់ហើយ ចំពោះនារីម្នាក់ហ្នឹងខ្ញុំដឹងពិតប្រាកដអ៊ីចឹង ចាស។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តើមាន--

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ សូមអញ្ជើញ!

[១៤:២៧:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកស្រីខ្ញុំមានសំណួរពីរទេ។ <សំណួរទី១ ទាក់ទងនឹងអ្វីដែលលោកស្រីបានលើកឡើង។>បន្ទាប់ពីរៀបការហើយ<គេបានឱ្យ>លោកស្រីទៅ<នៅ>ផ្ទះមួយដែលអង្គការ<រៀបចំ>ឱ្យលោកស្រីបាននិយាយយ៉ាងដូច្នេះ។ អ៊ីចឹងខ្ញុំចង់ដឹងថា <តើផ្ទះ>ហ្នឹង<បានក្លាយទៅ>ជាកន្លែងដែលលោកស្រីរស់នៅជាអចិន្ត្រៃយ៍ ឬក៏<ជាកន្លែងដែលលោកស្រីស្នាក់នៅ>តែម្តងម្កាលទេ ទៅផ្ទះហ្នឹងណា?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ការគេរៀបចំនេះ ផ្ទះមួយគឺជាផ្ទះប្រជាជន ហើយគេជម្លៀសប្រជាជនហ្នឹងចេញពីផ្ទះហ្នឹង។ តែក្រោយមក កាលខ្ញុំរៀបការ គេចាត់តាំងថាឱ្យទៅនៅផ្ទះហ្នឹង គឺនៅជាៗការបណ្តោះអាសន្នទេ គឺគ្មានទីតាំងអីឱ្យច្បាស់លាស់ទេ គឺខ្ញុំចល័តរហូត ចាស។ គ្រាន់តែស្នាក់នៅបណ្តោះអាសន្នតែប៉ុណ្ណឹងទេ។

**ស៖** នេះគឺជាផ្ទះដែល<អង្គការរៀបចំដើម្បីជាកន្លែងរស់នៅសម្រាប់>គូស្រករថ្មីថ្មោងឬ? <ហេតុអ្វីជាផ្ទះហ្នឹងត្រូវបានរៀបចំជាពិសេសដោយអង្គការ>?

**ឆ៖** ចាស ផ្ទះហ្នឹងមិនមែនធ្វើសម្រាប់ជាគូស្រករថ្មីថ្មោងទេ។ ផ្ទះហ្នឹងជាផ្ទះប្រជាជនតាំងពីដើមឡើយ តែអង្គការជម្លៀសប្រជាជនហ្នឹងចេញពីផ្ទះហ្នឹង ដល់តែពេលចំពោះខ្ញុំ ប្តីខ្ញុំក៏នៅកង ចំពោះខ្លួនខ្ញុំក៏នៅកង ដល់តែពេលប្តេជ្ញារួចវាអត់មានកន្លែងស្នាក់នៅ។ អ៊ីចឹងគេចាត់ឱ្យទៅនៅផ្ទះហ្នឹងសម្រាប់ថាផ្សំដំណេកអ៊ីចឹងទៅ បណ្តោះអាសន្នអ៊ីចឹងមក ហើយក្រោយមកមិនមែននៅផ្ទះហ្នឹងស្ថិតស្ថេរទេ បានតែ បីបួនដប់ថ្ងៃអ៊ីចឹង វា -- បានមួយអាទិត្យអ៊ីចឹង ត្រូវបែកគ្នាហើយ។ ប្តីគេចាត់ឱ្យទៅនៅឃុំផ្សេងទៅ ចំពោះខ្ញុំនៅឃុំផ្សេងទៅ ក្នុងរយៈពេល១០ថ្ងៃជួបគ្នាម្តងៗ ប៉ុន្តែមិនមែននៅផ្ទះហ្នឹងទេ គឺវានៅចល័តតែ

ពាសចាស។

[១៤:៣០:០៣]

**ស៖** តើអ្នកណាជាអ្នកកំណត់កាលពេលវេលា ដែលលោកស្រីត្រូវជួបគ្នាជាមួយនឹងប្តីលោកស្រី? ហេតុអ្វីបានគេត្រូវជ្រើសរើសយកកាលបរិច្ឆេទ<ជាក់លាក់> ដើម្បីឱ្យគូស្រករជួបគ្នា?

**ឆ៖** អ៊ីចឹងដូចថាជាទូទៅ គឺអង្គការ គឺប្រធានហ្នឹង ខាងអង្គការខាងលើហ្នឹង គេកំណត់ថាថ្ងៃ ១០ ថ្ងៃ២០ ថ្ងៃសម្រាក អ៊ីចឹងគេកំណត់ឲ្យប្តីប្រពន្ធមកជួបគ្នាម្តងថ្ងៃ អ្ហ៎! ម៉ាថ្ងៃ -- កំណត់ថាថ្ងៃទី១០ ថ្ងៃទី២០ ថ្ងៃទី៣០ អ៊ីចឹងតែម្តង គឺសម្រាកទូទៅ សម្រាកតែពេលថ្ងៃហ្នឹងទេ។ ប្តីប្រពន្ធនៅឆ្ងាយអីគេមកឲ្យជួបគ្នាពេលថ្ងៃហ្នឹង។

**ស៖** នៅពេលដែលលោកស្រីជួបប្តីរបស់លោកស្រីហ្នឹង តើមានឈ្លបមកលបស្តាប់<ម្តង> ទៀតនៅក្រោមផ្ទះទេ ឬក៏គេមកលបស្តាប់ហ្នឹងតែម្តងទេលោកស្រី?

**ឆ៖** ចាស ក្រោយមកគេអត់មានលបស្តាប់ទេ គេលបស្តាប់តែពេលដំបូងហ្នឹង។ តែក្រោយមកគេអត់មានលបស្តាប់ទេ ព្រោះអីនាងខ្ញុំមិនមានទីតាំងច្បាស់លាស់ ជួនកាលទៅធ្វើការនៅកន្លែងណាដាក់ទីតាំងកន្លែងហ្នឹងទៅ។ មានថែបមានអីអ៊ីចឹង គេមានស្លឹកត្នោតហ្នឹងរែកតាមអ៊ីចឹងទៅ យើងទៅធ្វើការកន្លែងណាយើងមានស្លឹកត្នោតហ្នឹង ដាក់អ៊ីចឹងមកក្រាលកន្ទេលក្នុងហ្នឹង យើងដេកជាមួយប្តីប្រពន្ធទៅចាសនៅតាមវាលស្រែ នៅតាមក្រោមដើមឈើអ៊ីចឹងទៅ។

[១៤:៣២:៣១]

**ស៖** បាទ នេះសំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងឈ្លប។ តើពួកឈ្លបហ្នឹងជាអ្នកណាហើយពួកគេមានអាយុប៉ុន្មានដែរ? តើពួកគេហ្នឹងមានវណ្ណៈក្នុងសង្គម<>យ៉ាងម៉េចដែរ? លោកស្រីអាចរៀបរាប់បានទេ?

**ឆ៖** ចាស ឈ្លបហ្នឹងមានអាយុប្រហែលជា៣០ គេមានប្តីមានប្រពន្ធដែរ មានប្តីមានប្រពន្ធមានកូនហើយចាស។ គេលបមើលតែពេលយប់ដំបូងហ្នឹងទេ តែក្រោយមកគេដឹងថាយើងស្និទ្ធស្នាលនឹងគ្នា គេលែង គេអត់ដែលលបមើលទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកស្រីខ្ញុំសូមអរគុណ ខ្ញុំអស់សំណួរហើយ។ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ម៉ោងសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលសវនាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៤ នាទី ដល់ម៉ោង ១៤:៥៤ នាទី)*

[១៤:៥៤:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការនិងផ្តល់វេទិការជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សួន វិសាល៖**

សូមគោរពតុលាការ។ សូមជម្រាបសួរលោក ហើយនិងលោកស្រីចៅ -- លោកស្រី ជាំង ស្រីមុំ ខ្ញុំឈ្មោះ សួន វិសាល ខ្ញុំជាមេធាវីការពារក្តីឲ្យលោក នួន ជា។ ខ្ញុំឡើងមកនេះសួរបញ្ជាក់នូវអ្វីដែលអ្នកស្រីបានដឹង បានឮហើយនិងបានឃើញនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលអ្នកស្រីបានរស់នៅ។ ខ្ញុំមានប្រធានបទបីសំខាន់សម្រាប់សួរអ្នកស្រី គឺទី១ គឺខ្ញុំសួរពីស្ថានភាពនៅក្នុងសហករណ៍របស់អ្នកស្រី ហើយទី២ទាក់ទងនឹងការរៀបការរបស់អ្នកស្រី និងទី៣ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទជាដំបូងនេះខ្ញុំចាប់ផ្តើមសំណួរទី១ ទាក់ទងនឹងប្រធានបទទី១តែម្តង។ អ្នកស្រីស្រុកកំណើតនៅទីណាដែរបាទ?

[១៤:៥៥:៥៦]

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស លោកប្រធានខ្ញុំមានស្រុកកំណើតនៅភូមិឫស្សីស្រុក ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ ចាស។

**ស៖** ចាប់តាំងពីអ្នកស្រីកើតមករហូតដល់ឆ្នាំ១៩៧៩ ឬក៏បច្ចុប្បន្ន តើអ្នកស្រីមានផ្លាស់ទីលំនៅទីកន្លែងណាផ្សេងទេ?

**ឆ៖** ចាស ពីឆ្នាំ -- សុំទោសលោកប្រធានសួរពីឆ្នាំ៧៩ ចាស? សូមសួរម្តងទៀត។

**ស៖** ខ្ញុំចង់ដឹងថាតើតាំងពីអ្នកស្រីកើតរហូតដល់ឆ្នាំ១៩៧៩ តើអ្នកស្រីរស់នៅស្រុកកំណើតហ្នឹងរហូត ឬក៏ផ្លាស់ទីលំនៅទីកន្លែងណាផ្សេង?

**ឆ៖** ចាស ខ្ញុំការផ្លាស់ទីលំនៅចាប់តាំងពីឆ្នាំ៧០ រហូតដល់ឆ្នាំ៧៩ គឺខ្ញុំមានការផ្លាស់ទីលំនៅការគេចនូវសង្គ្រាមគឺការខ្ញុំផ្លាស់រហូត។ ប៉ុន្តែខ្ញុំវាអត់ទៅពីស្រុកមួយទៅស្រុកមួយទេ គ្រាន់តែផ្លាស់ពីកន្លែងមូលដ្ឋានហ្នឹងទៅកន្លែងមូលដ្ឋានមួយទៀត ពីឃុំមួយទៅឃុំមួយ តែប៉ុណ្ណឹងទេ។ ប៉ុន្តែឆ្លងខេត្ត ឬមួយឆ្លងស្រុកវាអត់មានការផ្លាស់ប្តូរទេ ទៅឆ្ងាយទេ។ ផ្លាស់ពី៧០ រហូតដល់៧៩ ហ្នឹងវាមានការផ្លាស់ប្តូររហូត វាអត់មានទីតាំងច្បាស់លាស់ទេចាស។

**ស៖** ប៉ុន្តែអ្នកស្រីបានរស់នៅក្នុងឃុំហ្នឹងដដែល។ បានន័យថាឃុំនិងស្រុកហ្នឹងដដែល? អ្នកស្រីចង់បញ្ជាក់របៀបហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំនៅ -- ចាសការផ្លាស់ប្តូរនៅក្នុងឃុំហ្នឹងដដែល ពេលខ្លះពីឆ្នាំ៧០, ៧១, ៧២, ៧៣ អី។

**ស៖** ចង់បញ្ជាក់បានតែប៉ុណ្ណឹងបាទ។ ខ្ញុំចង់សួរបន្ទាប់ទៀតបាទ។ តើនៅក្នុងឆ្នាំណាដែលគេបង្កើតសហករណ៍នៅក្នុងភូមិស្រុករបស់អ្នកស្រីបាទ?

[១៤:៥៨:៤០]

**ឆ៖** ខ្ញុំភ្លេចកាលបរិច្ឆេទមិនដឹងជាចាប់ថ្ងៃទីប៉ុន្មានចាប់ជាសហករណ៍ដាំបាយរួមគ្នា ប៉ុន្តែខ្ញុំចាំពី៧៥រហូតដល់៧៩ ទើសដល់បែកហ្នឹង បានបែករំលាយសហករណ៍ចាស។

**ស៖** សូមអរគុណ។ បាទកាលពីព្រឹកមិញ អ្នកស្រីបានលើកឡើងច្បាស់លាស់នៅចំពោះមុខសវនាការ ដែលថាអ្នកស្រីថានៅក្នុងភូមិរបស់អ្នកស្រី គឺបានបង្កើតសហករណ៍តាំងពីឆ្នាំ១៩៧០។ តើ

សម្តីរបស់អ្នកស្រីកាលពីព្រឹកមិញហ្នឹងគឺជាការពិតទេ?

**ឆ៖** ចាស ខ្ញុំហាក់បីដូចជាសូមទោស វាមានការភ្លេចកន្លែងហ្នឹងបន្តិច។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលក្នុងភូមិរបស់អ្នកស្រីបង្កើតសហករណ៍នេះ តើគេបង្កើតរបៀបណាដែរ? គេធ្វើយ៉ាងម៉េចបានយើងចាត់ទុកថាជាសហករណ៍?

**ឆ៖** ចាស ពេលដែលកើតជាសហករណ៍ គេដាំបាយរួមគ្នា ធ្វើការរួមគ្នាចាស។ ធ្វើការរួមគ្នាដាំបាយរួមគ្នាឆ្នាំងតែមួយ។ ពេលហូបបាយ គេមានពេលកំណត់ម៉ោង គឺយើងមកញ៉ាំបាយរួមគ្នាហ្នឹងគឺគេមានការកំណត់ម៉ោង ដូចថាក្នុងមួយឃុំអ៊ីចឹង វាមានបី -- ក្នុងមួយផែនអ៊ីចឹង គេមានបីភូមិ។ អ៊ីចឹងគេកំណត់ថា មួយសហករណ៍ហ្នឹងមួយផែនហ្នឹង គឺទៅធ្វើការអ៊ីចឹងហើយ គឺដល់ពេលម៉ោងកំណត់មកញ៉ាំបាយរួមគ្នាតែម្តងចាស។

**ស៖** បាទ ខ្ញុំចង់សូមសួរអ្នកស្រីបន្តទៀត។ នៅមុនពេលដែលបង្កើតសហករណ៍ហ្នឹង តើមានជនជាតិ ឬក៏ប្រជាពលរដ្ឋយើងផ្សេងទៀតមករស់នៅក្នុងសហគមន៍របស់អ្នកស្រីឬទេ?

**ឆ៖** បើទៅស្រុកៗឃុំនាងខ្ញុំ វាមិនសូវ -- និយាយទៅវាអត់មានជនជាតិផ្សេង វាមានតែប្រជាជនខ្មែរ។ តែដូចថាក្រោយមកពី៧៥ មានអ្នកមកពីភ្នំពេញអីអ៊ីចឹង ចូលរួមនៅក្នុងសហករណ៍ហ្នឹងក៏អត់សូវ -- ខ្ញុំនិយាយទៅអត់ស្គាល់ប្រវត្តិរូបច្បាស់លាស់ទេ ដឹងតែប្រជាជនខ្មែរចាស។

**ស៖** កាលពីព្រឹកមិញផងដែរ អ្នកស្រីបានលើកឡើងអំពីថាមានប្រជាពលរដ្ឋថ្មី។ អ៊ីចឹងបើអ្នកស្រីអត់ដឹងថាប្រជាពលរដ្ឋថ្មីហ្នឹងប្រភេទណា អ៊ីចឹងហេតុអ្វីបានជាអ្នកស្រីថាមានប្រជាពលរដ្ឋថ្មី តើសំអាងលើមូលដ្ឋានអីដែរ?

[១៥:០២:២១]

**ឆ៖** ចាស បានៗខ្ញុំសន្មតថាប្រជាជនថ្មី គឺប្រជាជននៅមូលដ្ឋាន គឺថ្មីគេរៀបចំដាក់ដោយឡែកហើយអ្នកចំណូលថ្មីអាចដឹងមកពីនេះមកពីនោះ មកពីភ្នំពេញអ៊ីចឹង អាចដឹងព្រោះអីអ្នកថ្មីគេធ្វើប្រវត្តិរូបអ្នកថ្មី អ្នកចាស់គេធ្វើប្រវត្តិរូបអ្នកចាស់។ ហើយអ្នកថ្មីហ្នឹងដូចថាធ្វើការដោយឡែកអ៊ីចឹង គេចែកជាក្រុម មិនមែនច្របូកច្របល់ទេ គ្រាន់ថាៗមានអ្នកមូលដ្ឋានហ្នឹងមួយ អ៊ីចឹងគេអ្នកក្តោបក្តាប់អ្នកថ្មីហ្នឹង។ អ៊ីចឹងអ្នកថ្មីនៅដោយឡែកៗ អ្នកចាស់នៅដោយឡែក។ ចាសអ៊ីចឹង។ ខ្ញុំ បានខ្ញុំដឹងច្បាស់ថាអ្នកថ្មី អ្នកចាស់។

**ស៖** កាលពីព្រឹកមិញផងដែរ អ្នកស្រីបានលើកឡើងថាអ្នកស្រីមានប្រជាពលរដ្ឋពីរផ្នែកនៅក្នុង

មូលដ្ឋានហ្នឹង ទី១ គឺអ្នកពេញសិទ្ធិ មួយទៀតអ្នកត្រៀម។ តើនៅពេលនោះអ្នកស្រីធ្វើគេឲ្យត្រៀមហ្នឹង តើរយៈពេលប៉ុន្មានដែរ?

**ឆៈ** ពេញសិទ្ធិ និងត្រៀម។ អ្នកពេញសិទ្ធិនិងត្រៀម ដូចជាត្រៀម ត្រៀមអ៊ីចឹង ដូចចំពោះខ្ញុំអ៊ីចឹងមានការពាក់ព័ន្ធ អ៊ីចឹងគេដាក់ទៅត្រៀមជាមួយអ្នកថ្មី។ តែអ្នកមូលដ្ឋានចាស់ហ្នឹង គេរើសប្រវត្តិរូបអ្នកគ្មានការពាក់ព័ន្ធ។ អ៊ីចឹង ដូចថាអ្នកគ្មានការពាក់ព័ន្ធហ្នឹង ដូចថាអ្នកក្រីក្រ។

**សៈ** ខ្ញុំសូមកត់បន្តិចបាទ។ ខ្ញុំចង់សួរថារយៈពេលដែលអ្នកស្រីត្រៀមហ្នឹង តើរយៈពេលប៉ុន្មាន? គេចប់នៅពេលណាបាទ? បាទខ្ញុំចង់សួរប៉ុណ្ណឹង ឆ្លើយឲ្យខ្លីៗ ព្រោះយើងពេលវេលាមានកំណត់។ បាទ សូមអរគុណ។

**ឆៈ** ចាស ត្រៀមហ្នឹងត្រៀមរហូតដល់ឆ្នាំ៧៩ នៅត្រៀមរហូត។

[១៥:០៤:៤០]

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់បន្តទៀត ទាក់ទងទៅនឹងការធ្វើការងាររបស់អ្នកស្រី តើអ្នកស្រីចូលកងនារីហ្នឹងនៅពេលណាដែរ?

**ឆៈ** ការរៀបចំកងនារីហ្នឹង ខ្ញុំក៏មិនដឹង -- ខ្ញុំភ្លេចភ្លាំងនូវកាលបរិច្ឆេទទៅ មិនដឹងជាឆ្នាំប៉ុន្មាន និងថ្ងៃទីប៉ុន្មានទេ លោកប្រធាន វាអត់ចាំច្បាស់ ដឹងតែចូលកងនារី។

**សៈ** បាទ សូមអរគុណ។ នៅក្នុងកងនារីហ្នឹង តើមានសមាជិកនារីប៉ុន្មាននាក់ដែរ?

**ឆៈ** សមាជិកនៅកងនារីដឹងតែសមាជិកនារីហ្នឹង ដឹងតែមួយកងៗ ដឹងតែច្រើន ប៉ុន្តែអត់ដឹងចំនួនទេលោកប្រធាន ខ្ញុំវាដូចថា វាអត់សូវយកចិត្តទុកដាក់ ដឹងតែចូលកងនារី ដឹងតែកងនារីហ្នឹងច្រើន ដឹងតែចែកថា ពេញសិទ្ធិ និងមិនពេញសិទ្ធិអ៊ីចឹងទៅ។ កងនារីពេញសិទ្ធិផ្សេងទៅ កងនារីមិនពេញសិទ្ធិហ្នឹងផ្សេងទៅ ដឹងតែអ៊ីចឹង។

**សៈ** បាទ សូមអរគុណ។ នៅពេលដែលគេធ្វើការ តើគេមានបែងចែកឲ្យធ្វើការប្រភេទខុសគ្នារវាងកងនារីពេញសិទ្ធិ ហើយនិងមិនពេញសិទ្ធិហ្នឹង?

[១៥:០៦:៥៧]

**ឆៈ** ចាស ក្រោយមក នារីពេញសិទ្ធិ មិនពេញសិទ្ធិហ្នឹង យើងនិន្នាការ វានៅមានប្រវត្តិរូបខុសគ្នា ប៉ុន្តែដល់ក្រោយមកធ្វើការរួមគ្នា។ ប៉ុន្តែដល់ពេលរួមគ្នា គេរើសកម្លាំងស្រួច និងកម្លាំងមិនស្រួច វានៅមានការធ្វើការខុសគ្នាដែរ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** ដូច្នេះក្នុងន័យកម្លាំងស្រួច អ្នកស្រីបានលើកឡើងថា ធ្វើការអត់មានបែងចែកគ្នា ធ្វើការរួមគ្នា ប៉ុន្តែមានការបែងចែកកម្លាំងស្រួច មិនស្រួច តើគេផ្អែកអីមើលមូលដ្ឋានអី ដោយសារតែអ្នកស្រីមានកម្លាំងច្រើន ចាស់ក្មេង ឬយ៉ាងម៉េច បាទវ័យរបៀបណាបានគេបែងចែកបាន?

**ឆ៖** ចាស មានន័យកម្លាំងស្រួចហ្នឹង គឺដូចថា ក្រុមនារី ដូចថានារីដែលមានការទន់ជ្រាយ ធ្វើការកម្លាំងពលកម្មហ្នឹង មិនរហ័សរហួនហ្នឹង គេបែងចែកអ្ហ៎។ ដែលនារីណាមានកម្លាំងលឿន ហើយវ៉ៃគេហៅថា វ៉ៃរហ័សហ្នឹង គេមានការមួយក្រុម មានមួយក្រុមសម្រាប់ធ្វើការនៅក្នុងឃុំហ្នឹង វាមានពីរក្រុម ១មួយថា គេហៅ គេដាក់ឈ្មោះថា "កម្លាំងនារីស្រួច" ស្រួចហ្នឹង កម្លាំងហ្នឹង នារីហ្នឹងគេមានការកម្លាំងគេពេញខ្លួន គេរែកអី គេធ្វើអីរហ័សហាក់បីដូចជាស្ទួង។ នារីស្ទួងអ៊ីចឹង មួយហិកតាអ៊ីចឹង គេស្ទូងតែប្រាំមួយប្រាំពីរនាក់ គេអាចស្ទូងពេញ អាហ្នឹងកម្លាំងស្រួច។ ហើយបើកម្លាំងមិនស្រួចហ្នឹង បី-បួនដប់ម្ភៃនាក់អ៊ីចឹង អ៊ីចឹងគេបែងចែកជាពីរក្រុម។ កម្លាំងស្រួចនោះគេគាំទ្រ គាំទ្រលើកទឹកចិត្តអ៊ីចឹង តែកម្លាំងមិនស្រួចហ្នឹងនៅក្នុងមួយក្រុមហ្នឹង គេនៅក្នុងការតាមដាន ហើយពង្រឹងសតិអារម្មណ៍យើងឲ្យប្រឹងអ៊ីចឹង កុំឲ្យទម្រន់ កុំឲ្យមានសតិអារម្មណ៍លាក់ត្បុតអ៊ីចឹងទៅ គេណែនាំអ៊ីចឹង ចាស។

[១៥:០៩:២៣]

**ស៖** ខ្ញុំចង់បញ្ជាក់ឡើងវិញដែរថា តើនៅពេលគេបែងចែកកម្លាំងស្រួច ឬកម្លាំងមិនស្រួចអ៊ីចឹង នៅពេលដែលយើងធ្វើការមិនបានកម្លាំងខ្លាំងអ៊ីចឹង។ តើការបែងចែកម្ហូបអាហារ ឬក៏វិធានការអីខ្លះដែលគេត្រូវចាត់ទៅលើជនទាំងនោះ?

**ឆ៖** ចាស ដល់តែពេលម្ហូបអាហារ ការហូបចុកអី វាដូចថា អត់បែងចែកដែរ ឃើញមករួមគ្នាទាំងអស់ ចាស ឃើញតែរួមគ្នាពេល។ ពិតមែនថា គ្រាន់តែថាកម្លាំងស្រួច លើកជាទឹកចិត្តអី ប៉ុន្តែពេលបាយទឹកអី ឃើញតែមករួមគ្នាទាំងអស់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បង្វែរប្រធានបទបន្តិច ទាក់ទងទៅនឹងការងាររបស់អ្នកស្រី។ អ្នកស្រីបានលោកលើកឡើងថា អ្នកស្រីបានបង្រៀនសិស្សកាលពីព្រឹកមិញ។ តើអ្នកស្រីបានលើកឡើងពីបញ្ហានេះទេ?

**ឆ៖** ចាស កាលបង្រៀនសិស្សហ្នឹង គឺខ្ញុំគ្រាន់តែជាជំនួយនាយអាយបន្តិចបន្តួចទេ ហាក់បីដូចថាក្នុងហ្នឹងមើលសិស្សមួយក្រុមហ្នឹង ដូចថាមិនមែន ដូចថាជាជំនួយការអីគ្រូដែល និយាយទៅគ្រូគេពេញសិទ្ធិអីអ៊ីចឹងទៅ គេឈឺ គេអីអ៊ីចឹងទៅ ខ្ញុំហ្នឹងគ្រាន់តែជាជំនួយការអី មើលការខុសត្រូវហ្នឹង បង្រៀន

ហ្នឹងជាបណ្ដោះអាសន្នដែរ មិនមែនដូចថា ក្នុង -- និយាយទៅថា មិនមែនក្របខ័ណ្ឌអ៊ីចឹង។ គ្រាន់តែជំនួយការ ថ្ងៃណាគេដកចោលដកទៅ ថ្ងៃណា ព្រោះអីកាលខ្ញុំអប់រំសិស្សហ្នឹង គឺចំពោះខ្លួនខ្ញុំហ្នឹង វាមិនមានប្រវត្តិរូបល្អទេ ព្រោះអីប្រវត្តិរូបរបស់ខ្ញុំអ្នកគ្រូសិក្សាបង្រៀនសិស្សហ្នឹង គេសុទ្ធតែរើសអ្នកមានប្រវត្តិរូបអត់មានការពាក់ព័ន្ធនិន្នាការជាមួយបងប្អូនអី ធ្វើការងារអី ថាស្អីគេនិយាយ សក្ដិភូមិ ម៉េចទេហ្នឹង ថាពាក់ព័ន្ធអ៊ីចឹង គេអត់ឲ្យធ្វើទេ ព្រោះអីយើងអ្នកដឹកនាំអប់រំសិស្សអ៊ីចឹង គេត្រូវរើសពីប្រវត្តិរូប។ អ៊ីចឹង ខ្ញុំដឹងថា ខ្ញុំវាមានការពាក់ព័ន្ធប្រវត្តិរូប អ៊ីចឹងៗការខ្វះគ្រូហើយ គ្រាន់តែជាជំនួយការប៉ុណ្ណោះទេ ថ្ងៃណាមួយគេដកចេញតែដដែល ចាស។

[១៥:១២:២៨]

**ស៖** បាទ សូម -- ខ្ញុំចង់បញ្ជាក់ឡើងវិញពីចំណុចនេះ។ បាទ អ្នកស្រីចង់សំដៅថា អ្នកស្រីមិនបានបង្រៀនទេ ឬក៏អ្នកស្រីបានបង្រៀនដែរ នៅក្នុងខ្លឹមសារហ្នឹង? ជំនួយការហ្នឹង ជំនួយធ្វើយ៉ាងម៉េចបាទ?

**ឆ៖** ចាស បង្រៀនដែរ ប៉ុន្តែគ្រាន់តែបណ្ដោះអាសន្នជំនួសគេ គ្រាន់តែបណ្ដោះអាសន្ន។ ជំនួសអ្នក ដូចថាអ្នកគ្រូដែលគេឈឺ ឬគេត្រូវឡើងទៅប្រជុំអ៊ីចឹង ត្រូវប្រជុំថ្ងៃហ្នឹង។ អ៊ីចឹងខ្ញុំហ្នឹងគ្រាន់តែបណ្ដោះអាសន្នប៉ុណ្ណឹងទេ។

**ស៖** ដូច្នេះនិយាយឲ្យខ្លីទៅគឺថាអ្នកស្រីបានបង្រៀនដែរនៅក្នុងហ្នឹង ហើយអ្នកស្រីបានបង្រៀនរហូតដល់ពេលមុនអ្នកស្រីរៀបការ តើអ្វីដែលអ្នកស្រីលើកឡើងហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** ចាស ពេលនោះ ខ្ញុំជាអ្នកនៅខាងសេដ្ឋកិច្ច គេឲ្យរកបន្លែៗខាង នៅខាងអង្គភាពកុមារហ្នឹងរកបន្លែ រកម្ហូបអីអ៊ីចឹងទៅ ដល់តែពេលខ្លះ ហើយខ្ញុំក៏មើលការខុសត្រូវចំពោះកុមារដែរ។ ប៉ុន្តែគ្រូបង្រៀនវាមានអ្នកផ្សេង លុះត្រាតែគ្រូបង្រៀនហ្នឹងទៅបាត់ទៅ ហ្នឹងខ្ញុំហ្នឹងដូចថាជាជំនួយការបង្រៀនអ៊ីចឹងទៅ។

[១៥:១៤:៤១]

**ស៖** តើនៅពេលដែលអ្នកស្រីបង្រៀន តើអ្នកស្រីបង្រៀនមុខវិជ្ជាអីខ្លះ? គេឲ្យបង្រៀនពីអ្វីដែរ?

**ឆ៖** បង្រៀនតាៗ ដាំដំណាំអី ពុកម៉ែអី មានគុណអី ហើយពូៗទៅសមរភូមិអ៊ីចឹង។ អាហ្នឹងៗរៀនដូចថា ក្មេងៗតូចៗ ដូចមត្តេយ្យអ៊ីចឹង ហ្នឹង។

**ស៖** តើកូនសិស្សរបស់លោកស្រី អាយុពីត្រឹមណាដល់ត្រឹមណាដែរបាទ?

**ឆ៖** ពី៩ឆ្នាំ ៨ឆ្នាំ ១០ឆ្នាំលោកគ្រូ ចាស។

**ស៖** តើមុខវិជ្ជាអី -- មានសៀវភៅឬក៏មានមុខ -- មានៗគោលការណ៍អ្វីខ្លះដែលៗអង្គការណែនាំឲ្យលោកស្រីបង្រៀនបាទ? ប្រើឯកសារអ្វីខ្លះសម្រាប់បង្រៀនសិស្សនៅពេលនោះ?

**ឆ៖** ចាស មានសៀវភៅបោះពុម្ពពីខាងអង្គការខាងលើមក មានសៀវភៅបោះពុម្ពហ្នឹងយកមកបង្រៀន។ ចំពោះក្មេងតូចៗរៀនប្រកបអ៊ីចឹងទៅ តែចំពោះក្មេងធំៗអាន គេរៀនតាមអានអ៊ីចឹងទៅ។ មានសៀវភៅបោះពុម្ពពីខាងលើមក។

[១៥:១៧:១០]

**ស៖** សូមអរគុណ។ ខ្ញុំសូមដកស្រង់ចម្លើយរបស់អ្នកស្រី ទី៦ កាលអ្នកស្រីបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត។ សូមដកស្រង់សម្ដីតែម្ដង គឺថា៖ “ក្រសួងអប់រំបានផ្ដល់សៀវភៅណែនាំអំពីអ្វីដែលយើងត្រូវបង្រៀនកុមារ។ ខ្ញុំបង្រៀនកុមារឲ្យចេះអាន ចេះសរសេរ ឲ្យចេះស្រឡាញ់ជាតិ និងប្រាប់ថាពូរបស់គេកំពុងការពារជាតិ”។ តើនេះជាអ្វីដែលអ្នកស្រីបានលើកឡើងនៅចំពោះមុខចៅក្រមស៊ើបអង្កេតឬទេ បាទ?

**ឆ៖** ចាស សុំទោស ខ្ញុំអត់យល់ពីសំណួរ ចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់រំឭកឡើងវិញ គឺថាកាលពីថ្ងៃទី១១ វិច្ឆិកា ឆ្នាំ២០០៩ អ្នកស្រីបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ឬក៏អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹង នៅក្នុងចម្លើយទី៦ របស់អ្នកស្រីហ្នឹងគឺអ្នកស្រីបានឆ្លើយថា៖ “ក្រសួងអប់រំបានផ្ដល់សៀវភៅណែនាំអំពីអ្វីដែលយើងយកមកបង្រៀនកុមារ។ ខ្ញុំបង្រៀនកុមារឲ្យចេះអាន ចេះសរសេរ ឲ្យចេះស្រឡាញ់ប្រទេសជាតិ និងប្រាប់ថាពូរបស់ពួកគេកំពុងការពារជាតិ។” តើអ្វីដែលអ្នកស្រីឆ្លើយហ្នឹងគឺពិតជាបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ឬក៏អ្នកស៊ើបអង្កេតឬទេបាទ?

**ឆ៖** កាលខ្ញុំឆ្លើយចំពោះអ្នកស៊ើបអង្កេតនេះ គឺពិតមែនចាស ពីខាងសៀវភៅអប់រំហ្នឹង។

**ស៖** តើអ្នកស្រីមានបានបង្រៀនអ្វីក្រៅពីសៀវភៅណែនាំឲ្យស្រឡាញ់ជាតិ ឲ្យចេះសរសេរ ឬក៏ការពារជាតិនោះទេ បាទ ក្រៅពីនេះ?

**ឆ៖** ចាស ក្រៅពីបង្រៀនពីអក្សរ បន្ទាប់មកបង្រៀនតែសិល្បៈ ច្រៀង រាំ តែប៉ុណ្ណឹង ហើយនិងបង្រៀនធ្វើពលកម្ម។

**ស៖** បាទ អរគុណ។ ឥឡូវខ្ញុំចង់ចូលដល់ប្រធានបទទី២ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ម្ដ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ង។ ខ្ញុំចង់ដឹងថា នៅសហករណ៍របស់អ្នក ឬនៅអ្នកស្រី ឬក៏នៅក្នុងកងរបស់អ្នកស្រីមានអ្នកគេរៀបការមុនអ្នកស្រីឬទេបាទ?

**ផ៖** បាទ មាន។

**ស៖** តើមានប៉ុន្មានគូដែរបាទ?

**ផ៖** ចាស រៀបម្តងបួនប្រាំគូក៏មានដែរ ពីរគូក៏មាន។

[១៥:២១:០៨]

**ស៖** តើអ្នកស្រីដែលបានចូលរួមនៅក្នុងពិធីនោះឬទេ?

**ផ៖** ចាស ខ្ញុំបានចូលរួមអាពាហ៍ពិពាហ៍ប្អូនស្រីខ្ញុំ។

**ស៖** នៅអ្នកដែលបានរៀបអាពាហ៍ពិពាហ៍ពីពេលមុនអ្នកស្រី តើដែលមានព្រឹត្តិហេតុអីកើតឡើងទេ ប្រសិនបើគេមិនព្រមរៀបការ?

**ផ៖** ចាស អត់មានពេលការចាត់តាំងឲ្យរៀបនេះ គឺប្រកាសហៅឈ្មោះ ឈ្មោះ "ក" គូជាមួយ "ខ" អីអ៊ីចឹងទៅ ចាំតែស្តាប់ការប្រកាស ហើយម្នាក់ៗវាអត់មានបញ្ហាអីជំទាស់ដែរ និយាយទៅអត់ហ៊ានជំទាស់។

**ស៖** ដូច្នេះជារួមមក គឺថានៅមានការរៀបហ្នឹងជាច្រើនគូមុនអ្នកស្រីដែរ ហើយអ្នកស្រីមិនបានដែលឮអ្នកណាម្នាក់ដែលថា គេបដិសេធមិនព្រមរៀបការហើយមានទោសពៃរ៍អីទេ តើអ្នកស្រីចង់សំដៅលើហ្នឹង ឬក៏យ៉ាងម៉េចបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:២៣:១៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលខ្ញុំស្តាប់ការបកប្រែ គឺសាក្សីបានផ្តល់សក្ខីកម្មថាមិនមានបុគ្គល ឬក៏គូស្រករណាមួយដែលបដិសេធមុនគាត់ឡើយ។ ដូច្នេះហើយខ្ញុំ <--> មេធាវីការពារក្តីគាត់សួរថា <តើត្រឹមត្រូវទេអ៊ីចឹង ដែលថាមិន>មានអ្នកណា<ម្នាក់ ត្រូវបាន>ផ្តន្ទាទោស<ចំពោះ>ការបដិសេធ<នោះទេ>។ ដូច្នេះខ្ញុំគិតថា នេះគឺជាបញ្ហានៃការយល់ច្រឡំ<> ព្រោះថាសាក្សីគាត់បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយហើយថាមិនមានគូស្រករណាមួយមុនពេលគាត់រៀបការហ្នឹងបានបដិសេធនោះឡើយ។ <ដូច្នេះ ខ្ញុំមិនដឹងថា តើគាត់អាចឆ្លើយសំណួរនោះយ៉ាងម៉េចបានទេ។>

**លោក សួន វិសាល៖**

លោកតុលាការ លោកចៅក្រម អ្វីដែលខ្ញុំលើកឡើងនេះគឺថា យើងខ្ញុំគ្រាន់តែបញ្ជាក់អំពីខ្លឹមសារ អំពីអ្វីដែលសាក្សីបានបញ្ជាក់ ថាតើនៅពេលដែល -- នៅពេលរៀបការ១មុនការរៀបការរបស់គាត់ ហើយគូស្រករទាំងអស់នោះមិនមានដែលអ្នកណាបដិសេធ ឬត្រូវធ្វើទណ្ឌកម្មអីទេ ខ្ញុំគ្រាន់តែបញ្ជាក់ ឡើងវិញតែប៉ុណ្ណោះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់មានមូលដ្ឋានត្រឹមត្រូវ។ លោកមេធាវីអាចប្តូរសំណួរទៅកាន់សំណួរថ្មីផ្សេងទៀត។

[១៥:២៤:២៥]

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទ សូមអរគុណ។ ខ្ញុំបង្វែរសំណួរបន្តទៀត សូមសួរបន្តទៀត។ គឺថានៅ អ្នកស្រីបាន លើកឡើងថា នៅមុនពេលរៀបការ គឺអ្នកស្រីត្រូវបានឈ្លប ឬក៏នីរសារទៅអញ្ជើញអ្នកស្រី។ តើនៅ ពេលអញ្ជើញនេះគឺគេបានប្រាប់អ្នកស្រីអ្វីខ្លះ ដែលធ្វើឱ្យអ្នកស្រីត្រូវតែមកដាច់ខាតបាទ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ដែលពេល -- ក្នុងនោះវាមាននីរសារសម្រាប់នីរសារហ្នឹងសម្រាប់បម្រើមេឃុំ តែ ខ្លឹមសារដែលកោះអញ្ជើញហ្នឹង គឺអត់មានថាកោះអញ្ជើញមកកម្មវិធីអី ឬមួយដាក់ជាមូលហេតុអី គឺខ្ញុំ អត់ដឹងដែរ។ គ្រាន់តែដាក់ថា“ឲ្យទៅជាប្រញាប់ កុំឲ្យយប់ទាន់ កុំឲ្យយប់ជ្រៅ” ហើយដាក់“ប្រញាប់ៗ” ហ្នឹងដឹងតែលេខទោច្រើនចាំតែប៉ុណ្ណឹង។ តែខ្លឹមសារពីខាងដើមមកបញ្ជាក់ថា ឬមួយទៅរៀបអាពាហ៍ ពិពាហ៍ ឬមួយទៅជាបញ្ហាអីអត់មានបញ្ជាក់ទេ។ អ៊ីចឹងខ្ញុំមានការព្រួយបារម្ភកន្លែងហ្នឹងចាស មិនដឹងជា មូលហេតុអី។

**ស៖** នៅពេលដែលអ្នកស្រីមកដល់ភូមិ ឬក៏ឃុំរបស់អ្នកស្រីវិញ តើ១អ្នកណាដែលសួរអ្នកស្រី ឬប្រាប់អ្នកស្រីអំពីគោលបំណងនៃការអញ្ជើញមកហ្នឹងបាទ?

**ឆ៖** លិខិតកោះហៅ ការហៅនេះគឺមេឃុំចាស មេឃុំអ្នកហៅ ប៉ុន្តែដល់តែពេលខ្ញុំមកកន្លែង ស្នាក់ការឃុំហ្នឹងមាននារីកងចាស ប្រធាននារីកងហ្នឹងឈ្មោះ អុល ក៏មកជួប ដល់ពេលមកជួបអ៊ីចឹងខ្ញុំ

សួរថា "បងកោះហៅមានការអ្វី?" គាត់ប្រាប់ថា "មិត្តនារីឯងរៀបចំទៅ ប្ដេជ្ញាយប់ហ្នឹងហើយ" ក៏គាត់ប្រាប់ៗនៅពេលហ្នឹង ខ្ញុំដឹងនៅពេលហ្នឹងចាស ខ្ញុំរន្ធត់នៅពេលហ្នឹងដែលដឹងខ្លួនថាខ្ញុំរៀបការ។

[១៥:២៧:០៥]

**ស៖** ក្រៅពីប្រាប់របៀបនេះ តើមានប្រើពាក្យអីផ្សេងដែលនាំធ្វើឲ្យអ្នកស្រីខ្លាចទេ?

**ឆ៖** វាអត់មានប្រើពាក្យអីឲ្យធ្ងន់ធ្ងរ ប៉ុន្តែខ្ញុំខ្លាចខ្លួនឯង។ គាត់គ្រាន់តែសួរបញ្ជាក់ថា "ម៉េចឥឡូវហ្នឹងមានសតិអារម្មណ៍ម៉េច? មិត្តឯងមានសតិអារម្មណ៍ម៉េច?" ចាដល់ពេលហ្នឹងខ្ញុំទាល់ច្រក ខ្ញុំគ្រាន់តែឆ្លើយផ្អែកទៅលើម៉ែ ដោយគាត់គ្រាន់តែបញ្ជាក់ថា "រាល់ថ្ងៃយើងកូនអង្គការ ឬមួយកូនម៉ែ?" ខ្ញុំឆ្លើយថា "ខ្ញុំកូនអង្គការ" "បើកូនអង្គការ អង្គការសម្រេចប្ដេជ្ញាយប់ហ្នឹងហើយ"។ គាត់គ្រាន់តែដាក់ពាក្យប៉ុណ្ណឹងទេ ប៉ុន្តែខ្ញុំខ្លាចខ្លួនឯង បើខ្ញុំមិនរៀបការខ្ញុំខ្លាចចាស។

**ស៖** ដូច្នេះការសម្រេចរៀបការនោះ គឺជាអារម្មណ៍ភ័យខ្លាចរបស់អ្នកស្រីគឺចេញពីលោកស្រីផ្ទាល់ គឺអ្នកដែលមកប្រាប់អ្នកស្រីហ្នឹងគឺមិនបានបង្ហាញចំណុចណាមួយដែលធ្វើឲ្យអ្នកស្រីភ័យខ្លាចទេ។ តើអ៊ីចឹងមែនទេបាទ?

**ឆ៖** ចាសចំណុចភ័យខ្លាចហ្នឹង ខ្ញុំខ្លាចត្រង់អាកន្លែងថា "យើងជាកូនអង្គការ" ចាស អ៊ីចឹងយើងអត់មានសិទ្ធិផ្អែកទៅលើម៉ែឪ អ៊ីចឹងយើងជាកូនអង្គការ អ៊ីចឹងសម្រេចទៅលើអង្គការ។ បើកាលណាយើងប្រឆាំងនឹងអង្គការ ហាក់បីដូចជាយើងប្រឆាំងបក្ស កន្លែងហ្នឹងហើយដែលខ្ញុំខ្លាចចាស។

**ស៖** នៅថ្ងៃរៀបការនោះ តើឪពុកម្ដាយរបស់អ្នកស្រីមានដឹងរឿងហ្នឹង ឬក៏បានចូលរួមក្នុងពិធីហ្នឹងឬទេ?

**ឆ៖** ពេលថ្ងៃដែលខ្ញុំរៀបការហ្នឹង នៅថ្ងៃកម្មវិធីហ្នឹង ឪពុកម្ដាយខ្ញុំអត់ដឹងទេ។ ពេលថ្ងៃចូលរៀបការហ្នឹងខ្ញុំអង្គុយកៅអីហើយ ប៉ុន្តែហ្នឹងគេហៅនីរសារឲ្យទៅហៅម៉ែខ្ញុំ និងយាយខ្ញុំព្រោះអីឪពុកខ្ញុំស្លាប់ហើយ។ ម៉ែខ្ញុំ និងយាយខ្ញុំមកពីរនាក់ចាស បានគាត់ដឹងៗនៅពេលហ្នឹង តែពេលពីមុនមកដែលគេកោះហៅមករៀបការហ្នឹង វាអត់មានបានព្រាងទុកដឹងពីមុនទេ អត់ម៉ែខ្ញុំ យាយខ្ញុំក៏អត់ដឹងដែរ។ ដឹងដល់ពេលមកផ្ដាច់អាសម្រេចៗប្ដេជ្ញាចុងក្រោយហ្នឹងចាស។

[១៥:៣០:១៨]

**ស៖** សូមអរគុណ។ នៅពេលដែលរៀបការ តើមានគូស្រករផ្សេងទៀតរៀបការជាមួយអ្នកស្រីហ្នឹងទេ នៅពេលនោះ? ឬក៏អ្នកស្រីតែម្នាក់ឯងទេ មួយគូទេបាទ?

**ឆ៖** ចាស តែមួយគូទេចាស តែខ្ញុំហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរទៅប្រធានបទថ្មីមួយទៀត គឺប្រធានបទចុងក្រោយទាក់ទងទៅនឹងការសម្លាប់ជនជាតិវៀតណាម។ កាលពីព្រឹកមិញ អ្នកស្រីបានលើកឡើងថានៅក្នុងសហគមន៍របស់អ្នកស្រីហាក់ដូចជាមិនមានជនជាតិវៀតណាមអីច្បាស់លាស់ទេ។ ប៉ុន្តែអ្នកដែលមិនមានជាជនជាតិវៀតណាម នៅពេលគេប្រកាសជ្រើសឲ្យបញ្ជូនវៀតណាមទៅស្រុកវិញនោះ គឺមានប្រជាជនខ្មែរយើងមួយចំនួនស្ម័គ្រចិត្តទៅ ថាជនជាតិវៀតណាម។ តើអ្វីដែលខ្ញុំយល់ហ្នឹងតើខុសឬក៏ត្រូវ បើខ្ញុំមិនច្រឡំទេបាទ?

**ឆ៖** សូមទោស ស្តាប់មិនសូវបាន។ ចាស ស្តាប់សំណួរមិនសូវបានចាស។

**ស៖** បាទ ខ្ញុំសួរឡើងវិញបាទ។ កាលពីព្រឹកមិញ អ្នកស្រីបានលើកឡើងថាមាន -- មិនមានជនជាតិវៀតណាមពិតប្រាកដនៅក្នុងសហគមន៍របស់អ្នកស្រីទេ។ ប៉ុន្តែនៅពេលដែលគេប្រកាសបញ្ជូនជនជាតិវៀតណាមទៅវិញ ប្រជាជនខ្មែរយើងមួយចំនួនគឺគាត់ស្ម័គ្រចិត្ត ថាគាត់ជាជនជាតិវៀតណាម ហើយក៏ចុះឈ្មោះទៅ។ តើនេះជាការយល់ត្រឹមត្រូវរបស់ខ្ញុំឬទេ? ឬក៏អ្នកស្រីបាននិយាយរបៀបហ្នឹង ឬក៏និយាយផ្សេងពីនេះ?

[១៥:៣២:០៧]

**ឆ៖** ចាស វាៗពិតណាលោកប្រធាន។ វាមើលទៅ វានៅក្នុងឃុំនាងខ្ញុំហ្នឹង វាដូចថាជាជនបទស្រុកស្រែមួយ វាមិនសូវមានជនជាតិអីផ្សេងៗទេ មានៗដែរ វាដូចថាវាមានមួយៗ ដូចថាវាសែស្រឡាយហ្នឹងវាឆ្ងាយហើយ។ ប៉ុន្តែ ដល់តែអង្គការស្រាវជ្រាវរកថាជនជាតិវៀតណាមបញ្ជូនទៅបរទេសហ្នឹង ប៉ុនបើកាលណាអ្នកធ្វើការជាមួយខ្ញុំ ខ្ញុំមើលទៅសុទ្ធតែខ្មែរៗ ដល់ហើយមើលទៅវាពិបាកនូវការគាំទ្រនូវពលកម្មពេក ចេះថាវៀតណាមៗដែរទៅ ចង់ថាបញ្ជូនទៅៗប្រទេសវៀតណាម វាស្រណុក វារួចផុតពីពលកម្មនៅៗខ្មែរនេះ ម្ល៉ោះហើយចេះតែឆ្លើយថាអីចឹងទៅចាស។ អ្នកខ្លះក៏មានវៀតណាមខ្លះដែរអីចឹង។ អ្នកខ្លះមិនប្រាដកថាវៀតណាមទេ។

**ស៖** ខ្ញុំចង់បញ្ជាក់ឡើងវិញដែរ តើអ្នកស្រីដែលបានឃើញថា ឬក៏ដឹងថា នៅពេលជនជាតិវៀតណាមចាកចេញទៅនោះ មានជោគវាសនាយ៉ាងម៉េចដែរ?

**ឆ៖** ដែលចាកចេញទៅ ផ្លូវខ្ញុំដឹងថា ផ្លូវទៅវៀតណាម វាជិះឡានទៅផ្លូវផ្សេង។ តែដល់ចំពោះអ្នកទៅវៀតណាមនេះ គឺមិនមែនទៅផ្លូវដែលទៅផ្លូវវៀតណាមផង ទៅផ្លូវភ្នំវិញ។ អីចឹង ខ្ញុំសន្និដ្ឋានថា

មិនមែនទៅវៀតណាមទេ ព្រោះអីទៅវៀតណាម ស្រុកខ្ញុំទៅវៀតណាមទៅផ្លូវតាកែវទៅតានីអ៊ីចឹងទៅ នេះទៅផ្លូវភ្នំទៅតាមផ្លូវទៅភ្នំវិញ ទៅតាមផ្លូវក្រាំងតាចាន់ទៅវិញ។

**ស៖** ដូច្នេះអ្វីដែលអ្នកស្រីសន្និដ្ឋាន គឺមិនបានឃើញដោយផ្ទាល់ទេ គឺគ្រាន់តែនឹកឃើញថា អ្នកគ្រាន់តែបើកឡានទៅទិសដៅផ្សេង គឺសន្និដ្ឋានថាមិនទៅវៀតណាមទេ។ តើអ្នកស្រីចង់និយាយរបៀបហ្នឹង ឬយ៉ាងម៉េចបាទ?

[១៥:៣៥:០០]

**ឆ៖** ចំពោះខ្លួនខ្ញុំឃើញទៅផ្លូវផ្សេង ចំពោះអ្នកខ្លះ គេថាអត់ទៅវៀតណាមផង ទៅផ្លូវក្រាំងតាចាន់ ហើយកន្លែងក្រាំងតាចាន់ ទៅកន្លែងសម្លាប់មនុស្ស។ ស្វាយ ប្រជាពលរដ្ឋខ្លះ គេនៅជិតៗខាងហ្នឹង គេចេះតែខ្សឹបខ្សៀវគ្នាថា អាណិតណាស់ ពេលឡើងឡានទៅសុទ្ធតែរាដៃលាហើយ លាហើយ សើចញញឹមញញែម អាណិតគ្នា។ ឡើងឡានទៅ លាហើយៗ! មិនដឹងថា ទៅកន្លែងណាមួយ ដល់តែពេលប្រជាជនចេះតែខ្សឹបខ្សៀវហើយ ឃើញអាចងដៃទៅក្រោយក៏ទៅផ្លូវហ្នឹង ដល់តែទៅវៀតណាមក៏ផ្លូវហ្នឹង អ៊ីចឹងសន្មតថា ទៅផ្លូវហ្នឹងតែមួយគ្នាហើយ។

**ស៖** បាទ សូមអរគុណ។ សរុបមកវិញ គឺថាអ្នកស្រីគ្រាន់តែឮគេថា ឬក៏ការបើកឡានទៅតាមផ្លូវផ្សេង ដូច្នេះប្រហែលជាវាសនាមិនល្អទេ ក្នុងន័យគ្រាន់តែសន្និដ្ឋានតែប៉ុណ្ណឹងទាំងអស់។ តែប៉ុណ្ណឹង បាទ នេះជាសេចក្តី -- អ្វីដែលអ្នកស្រីចង់និយាយ អ៊ីចឹងមែនទេ បាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន។

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ការខ្ញុំយល់ឃើញ ចិត្តខ្ញុំស្មានទៅនឹង១០០ភាគរយហើយ ព្រោះអីវាមានឃើញអ្នកផ្សេងៗសុទ្ធតែទៅផ្លូវហ្នឹងទាំងអស់ ហើយគ្មានវិលត្រឡប់មកវិញ។ ហើយចំពោះបងប្អូនវៀតណាមហ្នឹង សាមុនឃើញទៅ ទៅដែរ ទៅផ្លូវផ្សេង ផ្លូវទៅតានី ផ្លូវតាកែវអីអ៊ីចឹងទៅ។ តែចំពោះចុងក្រោយនេះ ទៅផ្លូវផ្សេង ផ្លូវខុសគ្នា។

**លោក សួន វិសាល៖**

បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយលោកចៅក្រម ហើយខ្ញុំផ្តល់តួនាទីឲ្យសហការីរបស់ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្លួរបន្ត បាទ។ សូមអរគុណ។

[១៥:៣៧:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមានសំណួរពីរបីដើម្បីសួរបន្តទៀត។ អ្នកស្រីបានផ្តល់សក្ខីកម្មកន្លងមកថា អ្នកស្រីបាន<គិតថា>ប្តីរបស់អ្នកស្រីស្រឡាញ់នារីផ្សេង។ ហើយអ្នកស្រីបានផ្តល់សក្ខីកម្មថា អ្នកស្រីនៅតែ<>សម្រេចរៀបការជាមួយប្តីរបស់អ្នកស្រី តើ<បញ្ហាទាំងពីរនេះ>ត្រឹមត្រូវដែរឬទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ត្រឹមត្រូវ។

[១៥:៣៨:១៥]

**ស៖** អ៊ីចឹងអ្នកស្រីចង់និយាយថា អ្នកស្រីពេញចិត្តនឹងរៀបការ ឬក៏អ្នកស្រីរីករាយនឹងរៀបការជាមួយនឹងប្តីរបស់អ្នកស្រី រហូតមកដល់ឥឡូវហ្នឹងដែរឬទេ?

**ឆ៖** ចាស ពេលមុននឹងរៀបការ គឺចិត្តខ្ញុំអត់មានពេញចិត្តនឹងការរៀបការ ព្រោះអីខ្ញុំអត់ពេញចិត្តនឹងបុរសហ្នឹង ប៉ុន្តែចិត្តខ្ញុំមិនហ៊ានប្រឆាំងជាមួយនឹងអង្គការ។ ម្ល៉ោះហើយការ--

**ស៖** សូមទោសអ្នកស្រី ខ្ញុំត្រូវកាត់អ្នកស្រី ដោយសារតែខ្ញុំអត់មានពេល។ ប៉ុន្តែឥឡូវខ្ញុំចង់សួរថាឥឡូវក្នុងពេលបច្ចុប្បន្នហ្នឹង អ្នកស្រីរីករាយនឹងជីវិតអាពាហ៍ពិពាហ៍ហ្នឹងដែរឬទេ?

**ឆ៖** ចាស ក្នុងពេលបច្ចុប្បន្ននេះ គឺខ្ញុំរស់នៅជាមួយក្រុមគ្រួសារ គឺខ្ញុំមានសេចក្តីសុខ មិនមានបញ្ហាអ្វីកើតឡើងទេ រហូតដល់តាំងពីអាយុ២៤ រហូតមកដល់ចំណាស់នេះហើយ គឺខ្ញុំវាអត់មានបញ្ហាអីកើតឡើងទេ ចាស។ មិនពេញចិត្ត ក៏--

**ស៖** សូមអរគុណអ្នកស្រី តើអ្នកស្រីធ្លាប់ឮប្តីរបស់អ្នកស្រីធ្លាប់ផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេត

របស់តុលាការខ្មែរក្រហមនេះ ឬក៏ផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេតមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីបទពិសោធន៍របស់គាត់នៅក្នុងរបប<កម្ពុជាប្រជាធិបតេយ្យ>ដែរឬទេ?

**ឆ៖** ចាស ចង់សួរថា ប្តីខ្ញុំបានដឹង បានឮអង្គការស៊ើបអង្កេតដែរ ឬមួយយ៉ាងម៉េចអ្នំ?

[១៥:៤០:១៧]

**ស៖** ខ្ញុំចង់សួរអ្នកស្រីថា លោកប្រធានបានសួរអ្នកស្រី ហើយអ្នកស្រីថា អ្នកស្រីធ្លាប់ឆ្លើយជាមួយអ្នកស៊ើបអង្កេតពីរនាក់ ប៉ុន្តែខ្ញុំចង់ដឹងថា តើប្តីរបស់អ្នកស្រីធ្លាប់ផ្តល់ចម្លើយដល់អ្នកស៊ើបអង្កេតរបស់តុលាការនេះ ឬអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារដែរឬទេ? គឺខ្ញុំចង់សួរថា ប្តីរបស់អ្នកស្រីធ្លាប់ចម្លើយដែរឬទេ?

**ឆ៖** ពេលហ្នឹង ការស៊ើបអង្កេតហ្នឹង ការចម្លើយរបស់ខ្ញុំ ពេលហ្នឹងប្តីនៅជិតហ្នឹង គាត់ចូលរួមស្តាប់ដែរ ចាស។

**ប្រធានអង្គជំនុំ៖**

សំណួរមិនអ៊ីចឹងទេ សំណួរសួរថា តើលោកស្រីដឹងថា ប្តីរបស់លោកស្រីហ្នឹងធ្លាប់បានផ្តល់សក្ខីកម្មទៅឲ្យអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ជាមួយនឹងមន្ត្រីបុគ្គលទៅពីមជ្ឈមណ្ឌលឯកសារកកម្ពុជាដែរឬទេ?

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាសប្តីរបស់ខ្ញុំមិនបានចូលរួមផ្តល់មតិអីជាមួយ គាត់គ្រាន់តែបានចូលរួមស្តាប់តែប៉ុណ្ណឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកស្រី <>ថាតើប្តីរបស់អ្នកស្រីមានវត្តមាននៅក្នុងអគារសាលសវនាការនេះ ដែរឬទេនៅថ្ងៃនេះ?

**ឆ៖** ចាស អត់មាន ចាស គាត់នៅផ្ទះ។

[១៥:៤២:០៦]

**ស៖** តើអ្នកស្រីអាចប្រាប់បានដែរឬទេ ថាតើអ្នកស្រីបានដឹងថា ប្តីរបស់អ្នកស្រីធ្លាប់មានបទពិសោធន៍ ឬក៏ធ្លាប់ជួបប្រទះអំពីហេតុការណ៍ ថាតើប្តីរបស់អ្នកស្រីមានបង្ខំអ្នកស្រីក្នុងការរួមដំណេកដែរឬទេ? ខ្ញុំដឹងថា ខ្ញុំមិននេះទេ ប៉ុន្តែខ្ញុំមានពេលតែ២០នាទី ដូច្នេះហើយទើបខ្ញុំសួរសំណួរបែបនេះ ដើម្បីទទួលបានចម្លើយឆាប់រហ័ស។ <> ខ្ញុំសួរថា <តើសាក្សីនេះដឹងអំពីបទពិសោធន៍របស់ប្តីគាត់ទេ?> តើ

ប្តីរបស់គាត់ហ្នឹងនិយាយយ៉ាងម៉េចដែរ ថាមានការបង្ខំអីដែរឬទេ?

**លោក ខេល លីសាក់៖**

លោកប្រធាន ប្រសិនបើសំណួរនេះ គឺជាការសន្ទនាថាតើប្តីហ្នឹងគាត់និយាយយ៉ាងម៉េច ខ្ញុំមិនជំទាស់ទេ ប៉ុន្តែគាត់<សួរឱ្យសាក្សី>ទាយស្មានអំពីមតិ<> ឬក៏ការយល់ឃើញរបស់ប្តីរបស់អ្នកស្រីនោះ។ ដូច្នេះខ្ញុំសូមជំទាស់។ ដូច្នេះ ខ្ញុំចង់ឲ្យបញ្ជាក់ឲ្យច្បាស់ <ថាគាត់សួរ>អំពីការសន្ទនា<។> ប្រសិនបើការសន្ទនា<ខ្ញុំមិនជំទាស់ទេ>។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ឥឡូវ ខ្ញុំសួរឡើងវិញអ្នកស្រី តើអ្នកស្រីមានបានពិភាក្សាអំពីបញ្ហានេះ ជាមួយប្តីអ្នកស្រីនៅពេលក្រោយដែរឬទេ? ហើយគាត់ធ្លាប់និយាយថា គាត់ក៏ចាត់ទុកថាការរៀបការហ្នឹង ឬក៏រួមដំណេកហ្នឹង គឺជាការរួមដំណេកដោយបង្ខំដែរឬទេ? តើអ្នកស្រីធ្លាប់ពិភាក្សាជាមួយប្តីពីបញ្ហានេះទេ?

[១៥:៤៣:៤០]

**លោកស្រី ជាំង ស្រីមុំ៖**

**ឆ៖** ចាស ការរួមដំណេក គាត់អត់មានបង្ខំយើងទេ ប៉ុន្តែគាត់គ្រាន់តែនិយាយជាពាក្យសម្តីណែនាំយើងពីតួនាទីប្តីប្រពន្ធ ចាស។ យើងជៀសមិនផុតពីប្តីប្រពន្ធ។ គ្រាន់តែគាត់ណែនាំប៉ុណ្ណឹងទេ ថាអនាគតទៅយើងជៀសមិនផុតពីប្តីប្រពន្ធ។ អ៊ីចឹង គាត់គ្រាន់តែណែនាំ ឬមួយពាក្យលួងលោមយើងតែប៉ុណ្ណឹងទេ គាត់ បើគាត់បង្ខំចិត្តយើង ឬមួយគាត់បំពានលើយើង គាត់អត់ទេ។

**ស៖** តើគាត់មានប្រាប់អ្នកស្រីដែរឬទេ ថានៅយប់នោះ ឬក៏អាចថានៅពេលមុន ឬក៏ពេលក្រោយដែលអ្នកស្រីឮពួកឈ្លបលួចស្តាប់នោះ តើគាត់មាននិយាយអីជាមួយអ្នកស្រីដែរទេ?

**ឆ៖** ចាស អត់មាននិយាយអីទេ សម្ងំរៀងៗខ្លួន។ គ្រាន់តែវារនាបផ្ទះហ្នឹង វាមានប្រហោងគ្រាន់តែលួចអើតមើលប៉ុណ្ណឹង ប៉ុន្តែយើងចេះតែសំងំរៀងៗខ្លួនអ៊ីចឹងទៅ ដោយភ័យខ្លាចឡើងត្រជាក់សាច់អស់ហើយ។ ចេះតែមានការខ្លាចប៉ុណ្ណឹង។ អត់មានប៉ាននិយាយអី អត់មានប៉ានជំនុំគ្នាទេ សម្ងំតែម្តង។

[១៥:៤៥:២០]

**ស៖** ខ្ញុំប្រហែលជាត្រូវសួរឡើងវិញ។ តើប្តីរបស់អ្នកស្រីគិតថា វត្តមានរបស់ឈ្លបហ្នឹង គឺជាការជំរុញឲ្យអ្នកស្រី ឬក៏បង្ខំឲ្យអ្នកស្រីរួមដំណេកជាមួយគាត់ដែលឬទេ? តើគាត់ដែលគិតថាការដែល

មានឈ្លបនេះ ជាការជំរុញឲ្យអ្នកស្រីរួមដំណេកជាមួយគាត់ដែលឬទេ?

**ឆ៖** ចាស កាលឈ្លបមកហ្នឹង គឺគេមកលបមើលហ្នឹង គេលបស្ដាប់គ្រាន់ថាក្រែងយើងហ្នឹងមិនចុះដំណេកជាមួយគ្នា។ អ៊ីចឹងយើង សកម្មភាពអីយើងសម្ងំអត់មានធ្វើអីទាំងអស់ យើងខ្លាច យើងចេះតែសម្ងំទៅ។ ខ្លាច -- ម្យ៉ាងខ្លាច -- ចេះតែធ្វើពុតលក់ទៅ និយាយទៅខ្លាចហ្មង ខ្លាចចាប់ចំណុចអីមួយអ៊ីចឹង ព្រោះអីក្រុមគ្រួសារខ្ញុំមានខ្លួនអ៊ីចឹងចេះតែខ្លាច។ ដល់ឃើញឈ្លបមកលបទៀត មិនដឹងជាលបហ្នឹងមើល -- លបមូលហេតុថា គេមកមើលយើងផ្សំដំណេក ឬមួយគេមកលបតាមដានក្រែងយើងនិយាយពាក្យអាថ៌កំបាំងអីមួយប៉ះពាល់នឹងអង្គការក៏មិនដឹង។ ម្ល៉ោះហើយយើងខ្លាចចេះតែសម្ងំទៅ អត់ហ៊ាននិយាយអី។

[១៥:៤៦:៥២]

**ស៖** ខ្ញុំមានសំណួរបន្ថែមទៀត ប៉ុន្តែខ្ញុំសូមបន្តទៅប្រធានបទផ្សេងចុះ ទាក់ទងទៅនឹងចំណុចបន្ត។ មានប្រហែលជាស្ត្រីបីរយទៅបួនរយនាក់នៅក្នុងឃុំ<ញ៉ែងញ៉ង>នោះ គឺក្នុងចន្លោះឆ្នាំ៧៥-៧៦ ដែរឬទេ?

**ឆ៖** ចាស ស្ត្រីហ្នឹង និយាយទៅខ្ញុំជាសមាជិកវាអត់ដឹង -- វាអត់ -- វាគ្មានតួនាទីអីអ៊ីចឹង វាអត់ដឹងហើយ។ អត់ដឹងថាចំនួនមនុស្សហ្នឹងវាមានប៉ុន្មាន ស្ត្រីមួយក្រុមៗមានប៉ុន្មានអត់ដឹង អត់នេះទេ ដឹងតែធ្វើការ ជាមួយគេតែម្ដង ដឹងបែកជាក្រុមនោះៗអីអត់ដឹងទេ វាមិនដឹងថាមានស្ត្រីក្នុងភូមិហ្នឹងមានប៉ុន្មានអត់ដឹង។

**ស៖** សូមអរគុណ អ្នកស្រី។ តើអ្នកស្រីធ្លាប់ឮឈ្មោះ <> បងស្រីធឿន ហើយនិងបងស្រីហានដែរឬទេ?

**ឆ៖** ចាស អត់ដែលៗឮ និយាយអត់ដែលឮផង។

**ស៖** ខ្ញុំសូមអានឈ្មោះបន្ថែមទៀត។ លោកប្រធានខ្ញុំពិនិត្យមើលទៅលើឯកសារ D232/01 ឯកសារមានលេខ ERN 00413908, ខ្មែរមានលេខ 00408326។ ខ្ញុំនឹងបង្ហាញឈ្មោះរបស់ប្ដីប្រពន្ធមួយចំនួនដែលបានរៀបការដោយការបង្ខំ ប្រហែលជានៅក្នុងពេលជាមួយគ្នា ឬក៏ក្នុងអំឡុងពេលប្រហែលគ្នាជាមួយអ្នកស្រី។ ហើយខ្ញុំចង់ឲ្យអ្នកស្រីប្រាប់ថា អ្នកស្រីស្គាល់ឈ្មោះទាំងអស់នោះដែរឬទេ? ប្រពន្ធឈ្មោះ ស៊ុំ ប្ដីឈ្មោះ វ៉ាប រស់នៅឃុំជ្រៃគ្នោត<។> ប្ដីឈ្មោះ<វាន់> ប្រពន្ធឈ្មោះ <ធឿន> ឥឡូវរស់នៅឃុំជ្រៃគ្នោត។ ប្ដីឈ្មោះ ចេម ប្រពន្ធឈ្មោះ ជា រស់នៅ<ភូមិ>ទឹកថ្លា។ ប្ដីឈ្មោះ ជិន

ប្រពន្ធឈ្មោះ ប៉ុន រស់នៅភូមិទឹកថ្លា។ ប្ដីឈ្មោះ ចម ប្រពន្ធឈ្មោះ យ៉ាត រស់នៅ<ភូមិស្រម៉>។ ហើយប្ដីឈ្មោះ សុន ប្រពន្ធឈ្មោះ ប៉ាច រស់នៅភូមិទឹកថ្លា។ តើអ្នកស្រីអាចប្រាប់ថា អ្នកស្រីធ្លាប់ស្គាល់ ឬក៏ធ្លាប់ឮឈ្មោះនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់កាត់ទេ ក៏ប៉ុន្តែខ្ញុំឃើញថា គាត់កំពុងតែលើកឡើងនូវឯកសារមួយដែលអត់មានដាក់នៅក្នុង*អ៊ីទធីហ្វេស*របស់យើងទេ។ ដូច្នេះ យើងអត់ដឹងថា ឯកសារដែលគាត់ប្រើហ្នឹងជាឯកសារអីទេ។ ដូច្នេះខ្ញុំចង់ឲ្យបញ្ជាក់ថា តើឯកសារហ្នឹងពិតជាមានដាក់នៅក្នុង*អ៊ីទធីហ្វេស*របស់តុលាការ ឬក៏អត់? <ដូច្នេះ ទើបយើងអាចតាមទាន់ការតាំងសំណួររបស់គាត់។>

[១៥:៥០:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

វាគឺឯកសារលេខ៧១។ តើខ្ញុំអាចបន្តទៅមុខទៀតបានដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<សូមអរគុណលោកប្រធាន។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើអ្នកស្រីសាក្សីស្គាល់ឈ្មោះ ឬក៏ធ្លាប់ឮឈ្មោះនេះដែរឬទេ?

**លោកស្រី ជាំង ស្រីម៉ុំ៖**

**ឆ៖** ចាស ឈ្មោះអស់ទាំងនេះខ្ញុំធ្លាប់ឮ ហើយស្គាល់ទៀតចាស។

**ស៖** តើអ្នកស្រីស្គាល់ទាំងប្រាំមួយគូហ្នឹងដែរឬទេ? តើអ្នកស្រីស្គាល់ទាំងអស់ហ្នឹងមែនទេ?

**ឆ៖** ចាស ស្គាល់ៗទាំងអស់។

**ស៖** តើអ្នកស្រីដឹងដែរឬទេ ថាពួកគេរៀបការដោយបង្ខំ ឬក៏ដោយការស្ម័គ្រចិត្ត?

**ឆ៖** ចាស ខ្ញុំអត់ដឹងរឿងផងគេដែរ ខ្ញុំអត់ដឹង។

**ស៖** ខ្ញុំយល់ថាអ្នកស្រីមិនដឹងព័ត៌មានលម្អិតអំពីការរៀបការ ប៉ុន្តែសំណួរសំខាន់ គឺថាតើគេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រៀបការហ្នឹងរៀបការដោយបង្ខំ ឬក៏អត់ទេ? តើអ្នកស្រីអាចប្រាប់បានដែរឬទេអំពីបញ្ហានេះ?

[១៥:៥២:១១]

**ឆ៖** ចាស ការរៀបការនេះគឺខ្ញុំអត់ដឹងទាំងអស់ទេ ដឹងឮ គ្រាន់តែឮថាប្ដេជ្ញា គូនេះគូនោះតែប៉ុណ្ណឹង ប៉ុន្តែការបង្ខំក៏ខ្ញុំអត់ដឹង បង្ខំចិត្តក៏ខ្ញុំអត់ដឹងដែរ ព្រោះអី ខ្ញុំវានៅដូចថាសហករណ៍ វានៅកន្លែងតាមរៀង១ខ្លួន ដល់តែពេលរៀបចំប្ដេជ្ញាអីចឹង គេមិនមែនអំពាវនាវឲ្យយើងចូលរួមទាំងអស់គ្នាទេ។ វាមានដូចថាមានតែប្រធានក្រុម ឬមួយអ្នកមានតួនាទីទេដែលចូលរួម។ អ៊ីចឹងអាការរៀបការហ្នឹង ខ្ញុំអត់ដឹង ឬមួយគេបង្ខំចិត្ត ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំវាអត់ដឹងតែម្តង និយាយការពិត។

**ស៖** ខ្ញុំចង់បញ្ជាក់ប្រាប់អ្នកស្រីថាហេតុអ្វីបានជាខ្ញុំលើកឈ្មោះប្ដីប្រពន្ធទាំងប្រាំមួយគូនេះ ព្រោះថាប្រហែលជាពួកគាត់អាចទាំងប្រាំមួយគូហ្នឹង រៀបការដោយប្រធានកងរបស់អ្នកស្រី គឺឈ្មោះ អុល ដូចគ្នានឹងអ្វីដែលអ្នកស្រីបានផ្តល់នៅក្នុងសក្ខីកម្មរបស់អ្នកស្រីផងដែរ។ ហើយខ្ញុំចង់អានឲ្យអ្នកស្រីស្តាប់ ហើយនិងបង្ហាញចំពោះអ្នកស្រីនូវឃ្លាមួយចំនួននៃសក្ខីកម្មរបស់គាត់ដែលផ្តល់ជាមួយអ្នកស៊ើបអង្កេត។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតចាប់ផ្ដើមជាមួយ ERN មានលេខ <00413906> *(ស៊ុក)* គឺចម្លើយទៅនឹងសំណួរលេខ១៧ ខ្មែរមានលេខ 00408325។ ហើយគាត់ផ្តល់ភស្តុតាងទៅដល់អ្នកស៊ើបអង្កេត ដោយនិយាយថា ខ្ញុំដកស្រង់ទាំងស្រុង “សំណួរ៖ គឺឆ្នាំ៧៥-៧៩ ថាតើមានបុរសណាមក<កងនារីដើម្បី>ស្នើសុំរៀបការជាមួយនារីដែរទេ? ចម្លើយ៖ ថាអត់ដែលមានទេ ប៉ុន្តែនៅពេលដែលឃុំឃើញស្ត្រីហ្នឹង គេជ្រើសរើសគូឲ្យស្ត្រីនោះ ហើយភាគច្រើននៃស្ត្រីដែលគេជ្រើសរើសនោះគឺចន្លោះអាយុចន្លោះ<>២៥<ឆ្នាំ ឬលើសនេះ> ហើយបុរសប្រហែលជា២៨ទៅ២៩ឆ្នាំ។ ខាងឃុំជ្រើសរើសគូឲ្យពួកគេ ហើយប្រសិនបើភាគីទាំងពីរយល់ស្របពួកគេរៀបការ គឺមិនមានការបង្ខំនៅក្នុងក្រុមខ្ញុំទេ។” ហើយបន្តមកទៀតគឺចម្លើយទៅនឹងសំណួរ៣១ គាត់ឆ្លើយតបថា៖ “យើងបានសម្ភាសអ្នកដែលបានរៀបការនៅពេលនោះ ពួកគេបានប្រាប់ថា ការរៀបការរបស់ពួកគេ រៀបការដោយបង្ខំ <តើត្រឹមត្រូវទេ?>”។ ចម្លើយគាត់ឆ្លើយថា៖ “នៅពេលដែលខ្ញុំ<គ្រប់គ្រង>នារីនៅឃុំញ៉ែងញ៉ង គឺមិនមានបង្ខំរៀបការឡើយ។ ក្រោយការរៀបការពួកគេភាគច្រើនមានកូនជាមួយគ្នា ហើយរស់នៅជាមួយគ្នា<រហូតដល់សព្វថ្ងៃនេះ>។ ហើយក្រោយមកទៀត<ក្នុងឆ្នាំ៧៨> ខ្ញុំត្រូវបានគេផ្ទេរទៅបាត់ដំបង ហើយខ្ញុំមិនដឹងថាមានអ្វីកើតឡើងនោះទេ។” តើអ្នកស្រីអាចឆ្លើយតបបានដែរឬទេ ចំពោះអ្វីដែលប្រធានក្រុមអ្នកស្រីបានឆ្លើយតប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះ បានផ្ដល់ជាភស្ដុតាងនោះ?

[១៥:៥៥:៣៧]

**ឆ៖** ចាស ការរៀបការនេះ បើកាលណាយើងមិនពេញចិត្តក៏ត្រូវតែរៀបការដែរ។ ចាសនិយាយប៉ុណ្ណឹង មួយម៉ាត់ប៉ុណ្ណឹង។ ព្រោះអីម្នាក់ៗប្ដេជ្ញា មុននឹងធ្វើការរៀបការសុទ្ធតែមានអង្គប្រជុំប្ដេជ្ញាហើយម្នាក់ៗប្រគល់ខ្លួនជូនអង្គការ។ អ៊ីចឹងអង្គការសម្រេចធ្វើអ្វីត្រូវធ្វើតាមទាំងអស់ យើងអត់មានប្រឆាំងបានទេ ទោះបីចិត្តយើងថាមិនពេញចិត្តរៀបការ ក៏ត្រូវតែរៀបការដែរ មិនមានក្នុងពេលហ្នឹងមិនមែនបង្ខំមែនពិត ប៉ុន្តែចិត្តអត់មានត្រូវប្រឆាំងបានទេ គឺសម្រេចម្នាក់ៗប្ដេជ្ញាជូនអង្គការហើយ។

**ស៖** ដើម្បីឲ្យច្បាស់ តើអ្នកស្រីមិនយល់ស្របទៅតាមអ្វីដែលគាត់និយាយដែរឬទេ? គឺនៅពេលដែលគាត់និយាយក្នុងសក្ខីកម្មរបស់គាត់ថាមិនមានរៀបការដោយបង្ខំ តើអ្នកស្រីចង់និយាយថា អ្នកស្រីមិនឯកភាពអ៊ីចឹងមែនទេ?

**ឆ៖** បើចិត្តខ្ញុំនៅក្នុងសង្គមបច្ចុប្បន្ននេះ ការរៀបការកាលពីសង្គមនោះ គឺខ្ញុំត្រូវ -- បើត្រូវប្រៀបធៀបពីសង្គមនេះខ្ញុំមិនពេញចិត្ត គឺខ្ញុំអាចប្រឆាំងចិត្តបានហើយ។ តែនៅក្នុងសង្គមនោះមិនមានគាបសង្កត់នៅពេលហ្នឹងមែនពិត ប៉ុន្តែអត់ហ៊ានរើបម្រះអត់ហ៊ានមានមតិតវ៉ាទេ ព្រោះអីគឺកំណត់អ៊ីចឹងហើយ។ គ្រាន់តែយើងផ្អែកទៅលើថា ស្រេចទៅលើម៉ែឪ គេដាក់ចំណុចមកថា ក្រែងយើងកូនអង្គការហើយ។ អ៊ីចឹងសម្ដីយើងពីមុនមក សុទ្ធតែម្នាក់ៗប្ដេជ្ញាជូនអង្គការអស់មួយជីវិត អ៊ីចឹងយើងត្រូវតែសម្រេចតាម។ ហើយបើកាលណាពេលនោះយើងត្រូវតែរៀបការ ឥឡូវកោះមកហៅហើយអង្គការប្រាប់ថាឥឡូវរៀបចំទៅប្ដេជ្ញាយប់ហ្នឹងហើយ ខ្ញុំម៉េចនឹងហ៊ានថា អ្ហេ!ទេអត់ប្ដេជ្ញាទេ អ៊ីចឹងសម្ដីពេលហ្នឹងក៏ត្រូវមានទោសនៅពេលហ្នឹងដែរ។

[១៥:៥៧:៥៨]

**ស៖** អ្នកស្រី ថាតើម្ដាយរបស់អ្នកស្រីជំទាស់ទៅនឹងការរៀបការដែរឬទេ? ហើយបើគាត់ជំទាស់ តើគាត់មានប្រាប់ដល់បងប្អូនប្រុសស្រីរបស់អ្នកស្រីដែរឬទេអំពីបញ្ហានេះ?

**ឆ៖** និយាយទៅចំពោះម៉ែឪក៏អត់ហ៊ានជំទាស់ដែរ ព្រោះអីគាត់ដឹងថាគាត់គ្រាន់តែបានបង្កើតទេតែៗកូនអង្គការ អ៊ីចឹងស្រេចៗតែលើអង្គការរៀបចំ ចំពោះគាត់អត់មានសិទ្ធិតវ៉ាទេ ឬមួយគាត់មិនពេញចិត្តក៏គាត់អត់មាននិយាយ ឬមួយគាត់មិនពេញចិត្ត ក៏អត់មាននិយាយអីឲ្យដឹងដែរ ព្រោះអីការចូលរួមមកកម្មវិធីការហ្នឹង គេទៅហៅៗមកគាត់ចូលរួមប៉ុណ្ណឹង ប៉ុន្តែគាត់ជំទាស់អីក៏គាត់អត់មានជំទាស់ក្នុង

ហ្នឹង អត់មានជំទាស់ទេ ព្រោះអីគាត់ដឹងច្បាស់ហើយថាម្នាក់ៗសុទ្ធតែកូនអង្គការហើយ។

**ស៖** តើម្ដាយរបស់អ្នកស្រី ឬក៏បងប្អូនអ្នកស្រីមាននិយាយ<ជាមួយអ្នកស្រី>អំពីការរៀបការ<>ដែរទេ <>នៅក្រោយឆ្នាំ៧៩ <នៅពេលដែលលែងមានការភ័យខ្លាចអង្គការទៀតហើយនោះ? តើក្រោយពីនោះមក ម្ដាយរបស់អ្នកស្រីមានប្រាប់បងប្អូនរបស់អ្នកស្រីថា គាត់ប្រឆាំងនឹងការរៀបការនោះដែរឬទេ?>

**ឆ៖** ចាស អត់មានការហួសទៅហើយអត់មានបងប្អូនអីមានការនិយាយអីទេ អត់មានការនិយាយ គិតថាក្រុមគ្រួសារតែមួយទៅ អត់មាននិយាយកើតមានបញ្ហាអី អត់មានទេ។

[១៥:៥៩:៥៥]

**ស៖** អ្នកស្រី តើអ្នកស្រីអាច<>ផ្ដល់ឈ្មោះរបស់បុគ្គលណាម្នាក់ ដែលអាចគាំទ្រដល់ការអះអាងរបស់អ្នកស្រី ឬក៏គាំទ្រដល់សក្ខីកម្មរបស់អ្នកស្រីអំពីការរៀបការដោយបង្ខំឬទេ? តើអាចមានអ្នកណាម្នាក់ ដែលយើងអាចសួរអំពីហេតុការណ៍នៅថ្ងៃរៀបការហ្នឹង <ថាមានអ្វីកើតឡើង>នៅ<មុន>ពេល<និង>ក្រោយ<ពេលរៀបការនោះ>?

**ឆ៖** ចាស ខ្ញុំផ្ដល់ឈ្មោះបាន ដូចថាឈ្មោះ អុល អ៊ីចឹង។ គាត់ក្នុងនោះគាត់អត់មានបង្ខំយើងទេ ប៉ុនគាត់គ្រាន់តែហៅយើងមកអ៊ីចឹង មកជួបគ្រាន់ៗគាត់ប្រាប់ថាឥឡូវរៀបចំទៅ ប្ដេជ្ញាយប់ហ្នឹងហើយ។ បើរឿងបង្ខំ គឺគាត់អត់មានបង្ខំទេ ប៉ុន្តែគាត់គ្រាន់តែបញ្ជាក់ថារៀបចំទៅៗថ្ងៃហ្នឹង យប់ហ្នឹងរៀបចំទៅប្ដេជ្ញាយប់ហ្នឹងហើយ។ អ៊ីចឹង គាត់ជាអ្នកដឹកនាំ ខ្ញុំម៉េចប៊ានប្រឆាំងគាត់ អត់ប៊ានប្រឆាំងប្រកែកទេព្រោះអីគ្រាន់តែថាដល់ពេលខ្ញុំនៅស្ងៀមស្ងាត់ទៅ គាត់គ្រាន់តែសួរថាម៉េចឥឡូវហ្នឹង សម្រេចចិត្តម៉េចវិញ? ខ្ញុំៗវាទាល់ច្រកមិនប៊ានឆ្លើយដាក់ដោយខ្លួនឯង ខ្ញុំថាឥឡូវខ្ញុំសម្រេចទៅលើម៉ែឪ ដល់អ៊ីចឹងគាត់ថា អ៊ីចឹងយើងកូនម៉ែឪឬមួយកូនអង្គការ? អ៊ីចេះ។ ដល់តែពេលថាកូនអង្គការអ៊ីចឹង ខ្ញុំ -- ដល់កូនអង្គការ --

**ស៖** ខ្ញុំសូមទោសអ្នកស្រី ខ្ញុំសូមកាត់បន្តិច ហើយសូមអភ័យទោសផង។ យើងបានពិភាក្សារួចហើយអំពីខ្លឹមសារនៃសក្ខីកម្មរបស់ អុល ព្រោះ អុល បាននិយាយថាអត់មានការបង្ខំឱ្យរៀបការនោះទេ។ ប៉ុន្តែខ្ញុំចង់សួរថាតើអ្នកស្រីអាចមានអ្នកដទៃណាម្នាក់នៅក្នុងៗពេលនុ៎ង ឬក៏នៅក្រោយឆ្នាំ៧៩ ដែលអាចបញ្ជាក់ថា<> ការរៀបការរបស់អ្នកស្រីគឺជាការរៀបការដោយបង្ខំ។ តើអ្នកស្រីអាចរកអ្នកណាមកជួយអះអាងបានដែរឬទេ?

[១៦:០២:១០]

**ឆ៖** ចាស គ្មានអ្នកណាគេអះអាងទេ។ មានតែខ្លួនខ្ញុំម្នាក់ តែប៉ុណ្ណឹង។

**ស៖** ចុះប្ដីរបស់អ្នកស្រីវិញ? អូខេ ប៉ុន្តែអត់អីទេ ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។ ឥឡូវនេះម៉ោងបួនទៅហើយ តើខ្ញុំ --

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកនៅពេលល្ងាចហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សីរូបនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ដើមសប្ដាហ៍ក្រោយ។ ហើយនៅដើមសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ជាំង ស្រីមុំ បន្តបញ្ចប់។ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីមួយរូបទៀតដែលមានរហស្សនាម 2-TCW-964។ ហើយអង្គជំនុំជម្រះសូមអរគុណលោកស្រី ជាំង ស្រីមុំ ហើយដំណើរការស្ដាប់សក្ខីកម្មរបស់លោកស្រីនៅពេលនេះ នៅមិនទាន់បានបញ្ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឱ្យមកបន្តផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃចន្ទ ទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់លោកស្រីវិញបាន។ ហើយនិងមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោកស្រី ជាំង ស្រីមុំ វិលត្រឡប់ទៅកាន់ទីស្នាក់នៅរបស់គាត់វិញ និងឱ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទ ទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*